ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត




- ពាក្យស្លោកដើម្បីអប់រំពីអំពើប្រល័យពូជសាសន៍
- ប្រាសាទព្រះវិហារ : ទីគោរពសក្ការៈ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៥០ ខែមិថុនា ឆ្នាំ២០១២

# ស្វែងរកការពិត

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៥០ ខែមិថុនា ឆ្នាំ២០១២

## មាតិកា

◆ពាក្យស្លោកដើម្បីអប់រំពីអំពើប្រល័យពូជសាសន៍ ................................ ១

**ផ្នែកឯកសារ**

◆ចម្លើយសារភាពរបស់ កាក់ ធឹក ហៅ ផល្លី ........................................... ៧

◆ចម្លើយសារភាពរបស់ ដឹម វីល្យ៉ាម ក្លាក ........................................... ៨

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆សក្ខីកម្មរបស់ សាឡុត បាន ក្មួយប្រុស ប៉ុល ពត ................................ ១០

◆សក្ខីកម្ម នី កន : ប្អូនប្រុសរបស់ សុន សេន ..................................... ១៩

◆ខ្ញុំមិនជឿនូវអ្វីដែលមេដឹកនាំខ្មែរក្រហមនិយាយក្នុងសវនាការទេ ....... ២៣

◆នួន ជា ត្រូវតែទទួលស្គាល់ការពិត ............................................... ២៦

◆ជួបជាមួយអតីតកម្មាភិបាលខ្មែរក្រហមនៅអន្លង់វែង ..................... ២៨

**ផ្នែកច្បាប់**

◆ការពារការសម្ងាត់របស់ដំណើរការស៊ើបអង្កេត ............................ ៣៣

**វេទិកាពិភាក្សាសាធារណៈ**

◆ប្រាសាទព្រះវិហារ : ទីគោរពសក្ការៈ .......................................... ៤០

**ធំព័រស្រាវជ្រាវរកក្រួសារ**

◆សេវាថែទាំសុខភាពជាសំណាងដ៏ប្រពៃ ....................................... ៥២

◆ពូខ្ញុំត្រូវបានដុតចោលនៅមន្ទីរស-២១ .................................... ៥៥

◆សំណល់ជីវិត ..................................................................... ៥៦



ប្រាសាទព្រះវិហារ

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយ ដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម.៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ :** ម៉ម សុវណ្ណ, គ្រីស្តា ណោលសាន់, នង គីមលាង, ចូហ្ស៊ូ វ៉ាហ្សឆាល, ម៉ី មុនីរ័ត្ន **អ្នកនិពន្ធនិងស្រាវជ្រាវ :** ទាវ សារៈមុនិន្ទ, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែ :** ទែន សុខស្រីនិត **និពន្ធនាយកទូទៅ :** ឆាំង យុ **ជំនួយការនិពន្ធនាយក :** ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រ :** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ :** ឆេង វើង

Email: dccam@online.com.kh, Homepage: www.dccam.org

# ពាក្យស្លោកដើម្បីអប់រំពីអំពើប្រល័យពូជសាសន៍

មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងរៀបចំតម្លើងផ្ទាំងពាក្យស្លោកដើម្បីអប់រំពីអំពើប្រល័យពូជសាសន៍ទូទាំងប្រទេសដោយមានកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ។

ការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យគឺជាមធ្យោបាយដ៏មានឥទ្ធិពលមួយសម្រាប់ការបង្រៀនអំពីសិទ្ធិមនុស្ស គុណធម៌ពលរដ្ឋ និងគោលការណ៍ជាមូលដ្ឋាននៃប្រជាធិបតេយ្យប្រកបដោយឥទ្ធិពលនៅក្នុងប្រទេសក្រោយជម្លោះមួយ ។ ផ្ទាំងពាក្យស្លោកប្រឆាំងនឹងអំពើប្រល័យពូជសាសន៍នេះបម្រើតួនាទីដ៏មានសារៈសំខាន់មួយនៅក្នុងការសម្របសម្រួលការអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យតាមរយៈការលើកទឹកចិត្តឲ្យមានការចាប់អារម្មណ៍ពីសំណាក់សាធារណជន ចំពោះការសិក្សាពីប្រវត្តិសាស្ត្រ និងជាពិសេសជាងនេះទៅទៀតអំពីរឿងរ៉ាវនិងមូលហេតុដែលរឿងរ៉ាវទាំងនោះបានកើតឡើងនៅក្នុងរយៈកាលនៃរបបខ្មែរក្រហម ។

ផ្ទាំងពាក្យស្លោកមិនត្រឹមតែអំពាវនាវឲ្យមានការចាប់អារម្មណ៍ចំពោះតម្រូវការចាំបាច់សម្រាប់កិច្ចសន្ទនាអំពីរឿងរ៉ាវនិងមូលហេតុដែលរឿងរ៉ាវទាំងនោះបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអំពីសារសំខាន់នៃការអប់រំនៅក្នុងការកសាង ការផ្សះផ្សាជាតិ និងទស្សនៈវិស័យសម្រាប់អនាគតរបស់សហគមន៍ ។

ការបញ្ចូលការអប់រំពីអំពើប្រល័យពូជសាសន៍ទៅក្នុងសាលារដ្ឋគឺជាជំហានមួយនៅក្នុងដំណើរការនៃការបង្កើតឲ្យមានកិច្ចសន្ទនានិងការផ្សះផ្សានៅក្នុងសហគមន៍ ។ វាក៏មានសារសំខាន់ដូចគ្នាដែរនៅក្នុងការបង្កើតសេចក្ដីរីករាយនិងចំណាប់អារម្មណ៍ទៅលើប្រវត្តិរឿងរ៉ាវរបស់សមាជិកទាំងឡាយនៅក្នុងសហគមន៍ ។ សមាជិករបស់សហគមន៍គឺជាតួអង្គដ៏មានសារសំខាន់នៅក្នុងគម្រោងស្ដីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដោយហេតុថាសមាជិកទាំងនេះតម្រង់ទិសដល់កម្មវិធីសិក្សាថ្នាក់ជាតិមួយដើម្បីឲ្យសមស្របទៅនឹងតម្រូវការនិងចំណាប់អារម្មណ៍របស់សហគមន៍ ។ សមាជិកសហគមន៍គឺជាឧបករណ៍តម្រង់ដែលទស្សនៈ និងការចាប់អារម្មណ៍ថ្នាក់ជាតិទៅលើប្រវត្តិសាស្ត្រអាចត្រូវបានចម្រាញ់ដើម្បីឲ្យមានលក្ខណៈសមស្របទៅនឹងតម្រូវការនិងស្ថានភាពរស់នៅតាមមូលដ្ឋាន ។



លោក ឆាំង យុ (ឆ្វេង) និងលោកជំទាវ ទន់ សាអ៊ីម ក្នុងពិធីសម្ពោធពាក្យស្លោកប្រឆាំងអំពើប្រល័យពូជសាសន៍កាលពីឆ្នាំមុន

នៅក្នុងន័យនេះ ផ្ទាំងពាក្យស្លោកដែលរៀបរៀងឡើងលោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា បានថែងថា ៖ «និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឲ្យអត់ឱនអធ្យាស្រ័យគ្នា» និង «រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យគឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍» ។ **ឆាំង យុ**

# ចម្លើយសារភាព កាក់ ធឹក ហៅ ផល្លី

***អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាពរបស់កម្ពុជាប្រជាធិបតេយ្យ លេខ J០០៦១៧***

នៅក្នុងចម្លើយសារភាពដែលមានចំនួនដប់ពីរទំព័របាន បញ្ជាក់ថា កាក់ ធឹក ហៅ ផល្លី ត្រូវបានអង្គការចាប់ពីកងពល៧០៣ មកដាក់នៅមន្ទីរស-២១ ហើយបានលួចរត់រួចជាមួយនឹងមនុស្ស ប្រាំបីអ្នកផ្សេងទៀត តែដប់មួយថ្ងៃក្រោយមក ក៏ត្រូវអង្គការចាប់ខ្លួនបានមកវិញ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ។ ខាងក្រោមនេះជាចម្លើយសារភាពពីសកម្មភាពរបស់ កាក់ ធឹក ហៅ ផល្លី បន្ទាប់ពីបានរត់រួចពីមន្ទីរស-២១ ។ នៅពីរទំព័រចុងក្រោយជាកំណត់ហេតុដោយខ្មែក និងមានហត្ថលេខារបស់ ឌុច ទាក់ទងនឹងឈ្មោះ ចាយ ចេវ ។

នៅថ្ងៃទី២ ខែសីហា ឆ្នាំ១៩៧៧ អង្គការដក កាក់ ធឹក ហៅ ផល្លី ចេញពីកងពល៧០៣ ទៅនៅមន្ទីរស-២១ ។ រហូតដល់ថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៧ ផល្លី ត្រូវអង្គការចាប់យកមកដាក់នៅផ្ទះឈើមួយខ្នងនៅជិតផ្លូវពីរោងចក្រកែវទៅលិច ។ នៅលើផ្ទះនោះ អ្នកជាប់ចំណងមានប្រាំបីនាក់ ។ ម៉ោងដប់ពីរយប់ ឈ្មោះ ផុស និង ដេម បានស្រាយចំណងរួចវាយអ្នកយាមពីរនាក់ដែលយាមងោក រួចក៏ផ្អើលរត់ចុះមកដីទាំងអស់គ្នា ។ ផល្លី និង ម៉ុម ចំណងជាប់គ្នាក៏រត់មកជាមួយគ្នា ។ រត់ហួសផ្ទះចម្ងាយ ៦០ម៉ែត្រ ម៉ុម និងផល្លី ក៏ស្រាយចំណងឲ្យគ្នារួចហើយក៏រត់មកមាត់បឹងជើងឯកខាងត្បូងសំដៅមកព្រែកហូរ ។ មកដល់ព្រែកហូរ ផល្លី និង ម៉ុម ហែលឆ្លងស្ទឹងទៅពួននៅក្នុងចេតិយ ត្រើយម្ខាងទល់មុខពេទ្យ “ព-៩៨” នៅភូមិព្រែកហូរ ។ លុះដល់ម៉ោងប្រាំមួយកន្លះព្រឹក ផល្លី ប្រាប់ ម៉ុម ថា គាត់ទៅរកបាយហូបនៅកន្លែងក្មួយឈ្មោះ គី (យុទ្ធនារីសេដ្ឋកិច្ច ៩៨) ឲ្យ ម៉ុម ចាំនៅត្រង់ហ្នឹង ។ ម៉ុម មិនព្រមក៏ទៅទាំងអស់គ្នា ឆ្លងទឹកទៅកន្លែងពេទ្យ “ព-៩៨” ។ ទៅដល់មាត់ទឹក ផល្លី ជួបក្មួយស្រីកំពុងលាងឆ្នាំង ។ នារី គី សួរថា ទៅណា? ផល្លី ប្រាប់ថា រត់មកពីមន្ទីរស-២១ អង្គការចាប់ ។ នារី គី ក៏នាំ ផល្លី ចូលទៅផ្ទះសេដ្ឋកិច្ចជួបនឹងនារី ហ៊ិន ជាសេដ្ឋកិច្ចអនុសេនាធំ ពេទ្យ “ព-៩៨” ។ នារី ហ៊ិន សួរថាមកពីណា? ផល្លី ប្រាប់ថារត់មកពីមន្ទីរស-២១ អង្គការចាប់ ហើយឥឡូវប្រុងរត់ទៅស្រុកយួន តែអត់អីហូប ។ នារី ហ៊ិន ក៏ឲ្យនារី គី ខ្ចប់បាយកកពីរចានឲ្យ ផល្លី និងបាយក្រៀមចំនួនពីរគីឡូកន្លះឲ្យ ផល្លី សម្រាប់ធ្វើស្បៀង ។ ផល្លី ប្រាប់ នារី ហ៊ិន ខំបន្តធ្វើសកម្មភាពបំផុសបំផុលឲ្យខ្លាំង ។ និយាយត្រឹមនេះ នារី គី យកបាយមកឲ្យ ផល្លី ខ្លាចគេទាន់ក៏ហៅ ម៉ុម ហែលទឹកមកកន្លែងចេតិយវិញ ។ ម៉ុម កាលនោះ នៅមាត់ច្រាំងចម្ងាយ២០ម៉ែត្រ ពីផល្លី ។ (បញ្ជាក់) នារី ហ៊ិន នេះមានការពាក់ព័ន្ធសីលធម៌ជាមួយ ផល្លី តាំងពីឆ្នាំ១៩៧៣ និងក្បត់តាមរយៈនារី សាវី នៅឆ្នាំ១៩៧៤ ។ អង្គភាពវរសេនាតូច៧០៦របស់ ផល្លី ក៏មាននៅខាងត្បូងពេទ្យ “ព-៩៨” មួយកងហាដែរ ។

ដល់ម៉ោងប្រហែលប្រាំមួយកន្លះ ផល្លី ឃើញឈ្មោះ កឹង មេបញ្ជាការអនុសេនាតូច៧០៦ ដើរចេញមកពីកន្លែងធ្វើការម្នាក់ឯង ផល្លី ក៏ហែលទឹកទៅជួបហើយ កឹង សួរថា ចុះក្រែងទៅស-២១ ម៉េចក៏មកដល់នេះហើយ ផល្លី ឆ្លើយថា“រត់មកឥឡូវគិតរត់ទៅស្រុកយួនទៀត រួចខ្ញុំសុំបាយហូបជាមួយអំបិល” ។ កឹង ក៏ទៅលួចបាយបានមួយកញ្ចប់មកទៀតឲ្យ រួច ផល្លី ហែលឆ្លងមកត្រើយម្ខាងវិញ ។ ដល់ម៉ោងប្រហែលដប់យប់ ផល្លី នាំ ម៉ុម ទៅយកទូកនៅជិតស្ពានតាខ្មៅគឺទូកចាស់របស់វរៈ៧០៦ ។ ពេលទៅដល់ខាងលិចស្ពានតាខ្មៅ ផល្លី ទុកឲ្យ ម៉ុម នៅត្រើយម្ខាងរួច ផល្លី ហែលទៅលួចទូកនៅត្រើយខាងជើង ពេលស្រាយទូកបានមួយ ផល្លី ឡើងទៅជួបមិត្តម្នាក់ឈ្មោះ យ៉យ នៅកងធំវរសេនាតូច៧០៦ដើម្បីប្រាប់ពីបំណងរត់ហើយនិងសុំស្បៀងធ្វើដំណើរទៅវៀតណាម ពេលនោះ យ៉យ ក្តាប់សេចក្តីរាយការណ៍ពីផល្លី ហើយក៏ចាត់ឲ្យឈ្មោះ រុន មេក្រុមវរសេនាតូច៧០៦ ម៉ៃ នាទីយុទ្ធជនកងធំទី៣ វរសេនាតូច៧០៦ និង មឿង តួនាទីជាសមាជិកកងហាវរសេនាតូច៧០៦ដែលជាបក្សពួកខ្លួនឲ្យយកអង្ករពីរោងម៉ាស៊ីនស្រូវវរសេនាតូច៧០៦

ចំនួនប្រាំបីបារ៉ គ្រឿងៀតប្រហែលដប់គីឡូ និងដែកកេះមួយឆ្នាំងលេខ ១០ចំនួនមួយ រួចណែនាំឲ្យប្រយ័ត្ន ប្រសិនបើអង្គការចាប់បានកុំឆ្លើយដាក់គ្នា ទន្ទឹមនេះ ផល្លី ជញ្ជូនសម្ភារដាក់ទូកជាមួយ រុន, ម៉ៃ និង មឿង ហើយចែវសំដៅជិតស្ពានមកយក ម៉ុម ដែលនៅទីនោះបាន យកទូកទៅតាមទន្លេមួយគ្រឿងទៀតដោយក្នុងទូកនេះមានកំសួលមង ក្រណាត់ប៉ារ៉ាតង់ និងសម្ភារដែល យ៉យ ឲ្យ ទៅដល់ខាងក្រោមវត្តព្រែកសំរោង ផល្លី ក៏និយាយប្រាប់ ម៉ុម អំពីអ្នកជួយផ្តល់ស្បៀង ។

ដល់ម៉ោងបួនជាង ផល្លី និងម៉ុម ចូលសម្រាកនៅកៀនប្រាំងក្បែរមាត់ទន្លេមុខសិតត្បូ ពេលនោះ ផល្លី បានឡើងទាក់ទងមិត្តម្នាក់ឈ្មោះ ឃឹម គណៈឃុំសិតត្បូ ស្រុក២០ ដែលជាកម្លាំងធ្លាប់រួមសកម្មភាពជាមួយខ្លួន និង សាយ តាំងពីក្នុងសង្គ្រាមមកម្ល៉េះ ។ ពេលទៅជួបនោះ ឃឹម បានឲ្យបាយនិងចេកហូបនៅក្នុងផ្ទះ ឃឹម បានណែនាំ ផល្លី ឲ្យប្រុងប្រយ័ត្នឲ្យខ្ពស់ប្រយ័ត្នអង្គការចាប់បាន ។ បន្ទាប់មក ផល្លី ត្រលប់មកកន្លែងទូកចតរហូតម៉ោងបួនកន្លះល្ងាច ផល្លី និងម៉ុម នាំគ្នាចែវទូករហូតមកដល់ទឹកវិល ភូមិព្រែកពោធិ៍ ផល្លី ចូលលេងផ្ទះម្តាយក្មេក ពេលនោះម្តាយក្មេកឲ្យបាយកកបន្តិចនិងថ្នាំជក់បីខាំ ។ បន្តិចក្រោយមក ពីរនាក់នោះក៏ចែវទូកតទៅទៀតរហូតដល់មុខវត្តត្រពាំងជ្រៃ ឃុំឈើខ្មៅ ស្រុកកោះធំ ពេលនោះឈ្លបឃុំនៅមុខវត្តត្រពាំងជ្រៃឃាត់ ផល្លី និងម៉ុម មិនព្រមឲ្យចូល ។ អ្នកទាំងពីរបាននាំគ្នាចែវទូកគេចមកលិច រួចចងទូករត់មកចុងព្រែកសំពៅពូនទៅដេកនៅចុងព្រែកសំពៅពូនទល់ភ្លឺ រួចដើរឡើងមកលើវិញត្រង់ម្តុំព្រែកពោធិ៍ឃ្លួន ។ ផល្លី និង ម៉ុម ដេកទល់ម៉ោងបីរសៀល ក៏នាំគ្នាដើរមកព្រែកបិដល់ព្រលប់ទើបត្រឡប់មកទន្លេវិញពេលនោះប្រជាជនឆោឡោរក ។ ផល្លី និង ម៉ុម ដេកនៅគុម្ពដំឡូងឈើនៅម៉ោងដប់យប់ នាំគ្នាហែលទឹកសំដៅមកកោះឈើខ្មៅ ដេកនៅចម្ការបានមួយយប់មួយថ្ងៃដល់ម៉ោងបួនល្ងាចបានដើរតាមព្រៃពោតមកក្រោមវិញ ។ ពេលមកដល់ចុងកោះ អ្នកទាំងពីរបានលួចទូកប្រជាជនបានមួយឆ្លងទៅខាងកើតវត្តឈើខ្មៅ ពេលនោះឈ្លបចង់ឆែកឆេរ តែ ផល្លី និងម៉ុម មិនព្រម រួចក៏នាំគ្នារត់ទៅព្រៃនៅចុងកោះឈើខ្មៅ ហើយសម្រាកទីនោះបានជិតមួយយប់ ផល្លី រត់រួចមកលើវិញគឺព្រែកកណ្តាលវិញ ។


I.-
-1968
II.-
-1969
18.3.70
III.-
14. 8. 77

ចំណាររបស់ ឌុច នៅលើចម្លើយសារភាពរបស់ ផល្លី

ម៉ោងប្រាំពីរយប់ អ្នកទាំងពីរនាំគ្នាដើរចុះមកក្រោមវិញតាមទួលដូនសរដល់ចុងទួលថ្ម ក្នុងសង្កាត់ព្រែកទន្លេ ស្រុក១៨ ហើយសម្រាកបានមួយយប់នៅទួលថ្ម ព្រឹកឡើងឈ្មោះ តូម៉ា ឃើញក៏រាយការណ៍ឲ្យឈ្លប រួច ផល្លី ត្រូវចាប់ខ្លួនតាំងពីថ្ងៃនោះមកនៅម៉ោងដប់មួយព្រឹក ។ **ផាន សារៈមុនិន្ទ**

# ចម្លើយសារភាពរបស់ ជីម វីល្យ៉ាម ក្លាក

***អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាពរបស់កម្ពុជាប្រជាធិបតេយ្យ លេខ D0៧១៣៧***

ជីម វីល្យ៉ាម ក្លាក កើតថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៤៣ នៅក្រុងមីណេអាប៉ូលីស រដ្ឋមីណេសូតា សហរដ្ឋអាមេរិក ត្រូវបានអង្គការចាប់បញ្ជូនមកមន្ទីរស-២១ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៨ នៅពេលដែលគាត់និងមិត្តរបស់គាត់ម្នាក់ទៀតកំពុងតែថតយករូបភាពក្នុងដែនសមុទ្ររបស់កម្ពុជា ។

យោងទៅតាមឯកសារចម្លើយសារភាព ជីម វីល្យ៉ាម ក្លាក បានរៀបរាប់ថា គាត់មានឪពុកឈ្មោះ វីល្យ៉ាម ស៊ុលប៉ៃ ក្លាក ជាវេជ្ជបណ្ឌិតនៅមន្ទីរពេទ្យយោធា រដ្ឋកាលីហ្វ័រញ៉ា និងម្តាយឈ្មោះ លុី គ័រនើ ជាជំនួយការពេទ្យធ្មេញនៅរដ្ឋកាលីហ្វ័រញ៉ា ។ ឆ្នាំ១៩៦៧ ជីម វីល្យ៉ាម ក្លាក ធ្វើជាគ្រូបង្រៀនភាសាអង់គ្លេសនៅវិទ្យាល័យឡូសព្រឹគូស រដ្ឋកាលីហ្វ័រញ៉ា ។

ក្នុងឆ្នាំដដែល រដ្ឋាភិបាលសហរដ្ឋអាមេរិកបានចេញអាជ្ញាបង្ខំឲ្យគាត់ចូលបម្រើកងទ័ពចំនួនដប់លើក ប៉ុន្តែគាត់មិនព្រមធ្វើតាមអាជ្ញារបស់រដ្ឋាភិបាលទេ ។ មកដល់ឆ្នាំ១៩៦៩ ជីម វីល្យ៉ាម ក្លាក ត្រូវបានរដ្ឋាភិបាលអាមេរិកកាត់ទោសឲ្យជាប់គុកអស់រយៈពីរឆ្នាំនៅក្នុងគុកឡមប៉ុក ។ អំឡុងពេលដែលជាប់ក្នុងគុក ជីម វីល្យ៉ាម ក្លាក បានស្គាល់មនុស្សម្នាក់ឈ្មោះ ថម ម៉េដិន និងបានរាប់គ្នាជាមិត្តតាំងពីពេលនោះមក ។ ខែកញ្ញា ឆ្នាំ១៩៧១ ជីម វីល្យ៉ាម ក្លាក ត្រូវបានដោះលែងឲ្យចេញពីគុក ។ គាត់បានត្រឡប់ទៅរស់នៅក្រុងសាន់តាបាបារ៉ា រដ្ឋកាលីហ្វ័រញ៉ា ដោយប្រកបមុខរបរធ្វើទូកក្តោងម៉ាស៊ីនវិញជាមួយនឹងអតីតមិត្តរួមថ្នាក់ឈ្មោះ កាទីហុលឡើ ដែលបានជួយផ្គត់ផ្គង់លុយកាក់ខ្លះដល់គាត់ ។ នៅខែសីហា ឆ្នាំ១៩៧៤ ថម ម៉េដិន ដែលធ្លាប់ជាប់គុកជាមួយគ្នាបាននាំឲ្យលោក ប៊ិល ខុតបើសុន និង ស៊ុតនីឡុក មកឲ្យ ជីម វីល្យ៉ាមក្លាក



យោធាខ្មែរក្រហមកំពុងហាត់យុទ្ធសាស្រ្តទ័ពក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ស្គាល់នៅកន្លែងធ្វើទូកនៅក្រុងសាន់តាបាបារ៉ា ។ នៅពេលជួបគ្នា លោក ប៊ិល ខុតបើសុន ក៏បានលើកយកបញ្ហាមួយចំនួនទាក់ទង អំពីការធ្វើភ្នាក់ងារសម្ងាត់សេ.អ៊ី.អា ដោយប្រាប់ថានេះគឺជាមធ្យោបាយដែលរកលុយបានច្រើន។ ជីម វីល្យ៉ាម ក្វាក បាន សម្រេចស្ម័គ្រចិត្តចូលធ្វើជាភ្នាក់ងារសម្ងាត់របស់សេ.អ៊ី.អាតាមការណែនាំរបស់លោក ប៊ិល ខុតបើសុន។ ក្រោយមក ប៊ិល ខុតបើសុន និងស៊ីតនី បានមកជួបជាមួយ ជីម វីល្យ៉ាម ក្វាក ម្តងទៀតនិងបាន ប្រគល់ប្រាក់ឲ្យគាត់ចំនួន៥០០០ដុល្លារ ព្រមទាំងបានប្រាប់ថា ប៉ូល ហិនដែរសិន ជាអ្នកធ្វើការនៅក្រុមហ៊ុនធានារ៉ាប់រងជីវិតនៅឡូអេនជីឡេស រដ្ឋកាលីហ្វ័រញ៉ា បានដាក់លេខសម្គាល់១៤៩៧ ឲ្យគាត់ជាភ្នាក់ងារសម្ងាត់របស់សេ.អ៊ី.អា ។ ពេលនោះ ប៊ិលខុតបើសុន បានប្រាប់ ជីម វីល្យ៉ាមក្វាក ថា អ្នកត្រូវទៅធ្វើការនៅប្រទេសម៉ិចស៊ិកូ ។ ប៊ិល ខុតបើសុន ក៏បានលើកពីសភាពការណ៍នៅទីនោះនិងផែនការរបស់ភ្នាក់ងារសេ.អ៊ី.អាឲ្យគាត់ក្តាប់និងដឹងខ្លះជាមុន។ ប៊ិល និយាយថា ក្រុមម៉ាហ្វីយ៉ានៅម៉ិចស៊ិកបានរត់ពន្ធគ្រឿងញៀនចូលមកសហរដ្ឋអាមេរិកជាច្រើនឆ្នាំមកហើយ ។ សហរដ្ឋអាមេរិកមានផែនការបំបាត់ការរត់ពន្ធបែបនេះ ហើយស្នើឲ្យរដ្ឋាភិបាលម៉ិចស៊ិកូឲ្យទប់កុំឲ្យពួកម៉ាហ្វីយ៉ារត់ពន្ធគ្រឿងញៀននេះតទៅទៀត ។ តែសំណូមពរនេះមិនមានប្រសិទ្ធភាពអ្វីទាល់តែសោះ ។ ទន្ទឹមនឹងសភាពការណ៍នេះ នៅម៉ិចស៊ិកមានជនជាតិភាគតិចម៉ិចស៊ិកូឥណ្ឌីយ៉ានប្រឆាំងជាមួយនឹងក្រុមម៉ាហ្វីយ៉ាដែរ ។ ហេតុនេះ អង្គការសេ.អ៊ី.អាប្រគល់ភារកិច្ចឲ្យ ជីម វីល្យ៉ាម ក្វាក ទៅទាក់ទងនឹងក្រុមឥណ្ឌីយ៉ានទាំងនោះនាពេលខាងមុខនេះ ។ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៧៥ ប៊ិល បានយកប្រាក់២០០០ដុល្លារមកឲ្យ ជីម វីល្យ៉ាម ក្វាក ទៀត។ ជីម និង ស៊ីតនី បានចេញដំណើរទៅប្រទេសម៉ិចស៊ិកូនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៥ តាមទូកក្តោង ។ នៅប្រទេសម៉ិចស៊ិកូ ជីម បានសម្រាកនៅម៉ង់សានីយូបានរយៈពេលប្រាំថ្ងៃ ។ បន្ទាប់មក ទើបទៅដល់ប៉ុនតូឡាសូវ៉ូ ។ នៅកន្លែងនេះ ជីម បានជួបជាមួយប្រធានមេដឹកនាំឥណ្ឌីយ៉ានឈ្មោះ ហែលណិន ហ៊ែរណង់ដូ ។ ក្នុងការជួបលើកនេះ ប៊ិល គ្រាន់តែប្រាប់ឲ្យ ជីម និង ហែលណិន ហ៊ែរណង់ដូ ស្គាល់គ្នាដើម្បីទាក់ទងគ្នានៅលើកក្រោយ ព្រោះ ប៊ិល និង ស៊ីតនី អស់មានភារកិច្ចមកទាក់ទងជាមួយនឹង ហែលណិន ទៀត ហើយដាក់ផែនការឲ្យក្រុម ហែលណិន ចាប់ផ្តើមដុតចម្ការថ្នាំញៀនរបស់ក្រុមម៉ាហ្វីយ៉ា ។ ជាមួយគ្នានោះ ហែលណិន សុំឲ្យក្រុមសេ.អ៊ី.អាជួយខ្លួនជាអាវុធស្វ័យប្រវត្តិ និងថ្នាំពេទ្យ ។ តែក្រុមសេ.អ៊ី.អា នេះថាមិនអាចជួយបានទេ ប៉ុន្តែមានលទ្ធភាពអាចជួយបានត្រឹមតែលុយកាក់តែប៉ុណ្ណោះ ។ ខែសីហា ឆ្នាំ១៩៧៦ ប៉ូល ហិនដែរសិន បានបញ្ជាឲ្យ ជីម ទៅជួសជុលកប៉ាល់របស់សេ.អ៊ី.អា មួយគ្រឿងនៅក្រុងសាន់ហ្វ្រង់ស៊ីស្កូវិញ ។ ពេលនោះ ជីម ក៏បានជួប ឡែន ម៉ាក់ណាម៉ារ៉ា ដែលជាជាងជួសជុលម៉ាស៊ីននិងជាអ្នកដែលពូកែរកផ្សារលក់គ្រឿងញៀន។ ក្រោយពីបានជួសជុលរួច ជីម ក៏បានទទួលបញ្ជាពី ប៉ូល ហិនដែរសិន ឲ្យទៅទាក់ទងជាមួយនឹងក្រុម ហែលណិន ជាលើកទីពីរ ។ ក្នុងពេលនោះ ជីម បានទៅជាមួយ ឡែន ជួបនឹង ហែលណិន នៅកេអេរ៉ូ ដែលជារដ្ឋសហព័ន្ធម៉ិចស៊ិកូវិញ ព្រមទាំងបានប្រគល់ប្រាក់ឲ្យទៅ ហែលណិន ទៀតផង ។ ហែលណិន បានរាយការណ៍ប្រាប់ ជីម ថា «នៅពេលនេះ ក្រុមរបស់ខ្លួនបានដុតបំផ្លាញចម្ការរបស់ពួកម៉ាហ្វីយ៉ាអស់ចំនួន២០ភាគរយ» និងបានកម្ទេចក្រុមម៉ាហ្វីយ៉ានិង អ្នកដែលរស់នៅជាក្រុមតូចៗថែមទៀតផង ។ ទោះជាយ៉ាងណា ក្រុមម៉ាហ្វីយ៉ាក៏ធ្វើការវាយបកខ្លាំងណាស់ដែរ ។ ជីម រាយការណ៍ព័ត៌មានទាំងនេះទៅឲ្យ ប៉ូលហែន ដែរសិន នៅក្រុងសាន់ហ្វ្រង់ស៊ីស្កូវិញ ។

នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៧ ជីម ផ្លាស់ចេញពីសាំងតាបាបារ៉ា ជាមួយ ឡែន និង ហង់រី ម៉ារិន ទៅកាន់ម៉ិចស៊ីកូម្តងទៀត តាមការណែនាំរបស់ ប៉ូល ហិនដែរសិន។ នៅក្នុងខែកក្កដា ឆ្នាំ១៩៧៧ ប៉ូល ហែនដែរសិន បានមកជួបជាមួយនឹង ជីម នៅហូណូលូលូវិញ ។ នៅពេលនោះ ប៉ូល ហែនដែរសិន បានប្រាប់ ជីម អំពីសភាពការណ៍នៅអាស៊ីអាគ្នេយ៍វិញ ។ តាម ប៉ូល ហែនដែរសិន កម្ពុជានឹងក្លាយជាប្រទេសមួយដ៏ខ្លាំងក្លាក្នុងពេលប៉ុន្មានឆ្នាំខាងមុខនេះ ។ សហរដ្ឋអាមេរិកចង់ដឹងយ៉ាងខ្លាំងពីបញ្ហាប្រទេសកម្ពុជា ។ តើសភាពការណ៍ជាក់ស្តែងនៅកម្ពុជាយ៉ាងណា? ហេតុអ្វីបានជាកម្ពុជាមានការលូតលាស់ខ្លាំងក្លាយ៉ាងនេះ? សហរដ្ឋអាមេរិកចង់តាមដានឲ្យបានជាក់ស្តែងនូវការវិវឌ្ឍរីកចម្រើនរបស់ប្រទេសកុម្មុយនីស្តមួយចំនួនរួមមានដូចជានៅប្រទេសថៃ ប្រទេសម៉ាឡេស៊ី ប្រទេសឥណ្ឌូនេស៊ី ជាពិសេស

សកម្មភាពរបស់កុម្មុយនីស្តកម្ពុជាតែម្តង ។ ជាចុងក្រោយ ប៉ូល ហែនដែរសិន ក៏បានប្រាប់ភារកិច្ចឲ្យ ដឹម ទៅកាន់ប្រទេសថៃ និង ទៅយកការណ៍នៅសមុទ្រកម្ពុជាមានថតរូបជាដើម ។

ថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧ ដឹម និង ឡែនម៉ាក់ណាម៉ារ៉ា ចេញដំណើរពីហូណូលូលូទៅកោះតាងដោយជិះទូកក្តោងម៉ាស៊ីន ។ នៅកោះតាង ដឹម បានជួបជាមួយនឹង ហ៊ីលីព ហើយ ហ៊ីលីព បាន សួរបញ្ជាក់អំពីភារកិច្ចរបស់ខ្លួន ។ បន្ទាប់មក ដឹម បានប្រាប់វិញថា គាត់បានក្តាប់សកម្មភាពទាំងអស់ ។ ចំណែក ហ៊ីលីព ណែនាំឲ្យ ដឹម ត្រូវតែថតរូបនៅកម្ពុជាឲ្យច្បាស់ល្អមែនទែន ។ចាប់តាំងពីនោះមក ដឹម និង ឡែន បានធ្វើដំណើរទៅសិង្ហបុរីដោយចំណាយពេលអស់បី សប្តាហ៍ ។ នៅទីនោះ ដឹម ក៏បានជួបជាមួយ ដានីញ៉ែល ហើយបាន ទទួលសំបុត្រមួយដែល ប៉ូល ហែរដែរសិន បានផ្ញើមក ។ នៅក្នុង សំបុត្រនោះ ប៉ូល ហែនដែរសិន បានណែនាំឲ្យ ដឹម ស្គាល់ ដានីញ៉ែល និង អូទី ថែមទៀត និងឲ្យ ដឹម បំពេញបេសកកម្មនៅដែនសមុទ្រ កម្ពុជាដោយប្រុងប្រយ័ត្នបំផុត ។ ក្រោយមក ដានីញ៉ែល បានណែ នាំឲ្យ ដឹម ក្តាប់នូវភារកិច្ចស៊ើបការណ៍ឲ្យជាប់ ។ លើសពីនេះទៅ ទៀត ដានីញ៉ែល បានជូនដំណឹងឲ្យ ដឹម យ៉ាងលម្អិតទាក់ទងអំពី ចំណុចសំខាន់ៗដែលត្រូវថតរូបឲ្យបានគឺនៅផ្នែកកណ្តាលនៃសមុទ្រ កម្ពុជា និងសមុទ្រកម្ពុជាដែលនៅជាប់ព្រំដែនវៀតណាម ។ បន្ទាប់ មក ដានីញ៉ែល បាននិយាយបន្តទៀតថា ប្រសិនបើមានសង្គ្រាម រវាងថៃនិងកម្ពុជា សហរដ្ឋអាមេរិកនឹងជួយថៃរហូតដល់បញ្ចប់ជា មិនខាន ។ដូចនេះ អាមេរិកកាំងបានបញ្ជូនកប៉ាល់ចំនួនបីគ្រឿងនិង កងទ័ពចំនួន៧៥០០នាក់ទៅសុំចតនៅប្រទេសថៃដើម្បីលើក ទឹកចិត្តថៃដោយកប៉ាល់ទាំងនោះមានផ្ទុកយន្តហោះឈ្មោះអាំង តែប្រាយមួយកប៉ាល់ និងកប៉ាល់ប្រយុទ្ធមួយគ្រឿង ។ មួយរយៈ ក្រោយមក ដានីញ៉ែល បានឲ្យ ដឹម ចេញទៅប្រទេសថៃដើម្បីឲ្យ ទាន់ពេលកប៉ាល់និងទ័ពរបស់អាមេរិកបានចតនៅទីនោះ ។ ក្រោយ មក ដឹម និងអូទី ក៏បានពិភាក្សាអំពីចលនាកុម្មុយនីស្តវាយកាន់កាប់ ពិសេសខាងឈៀងម៉ៃហើយនៅតាមព្រំដែនកម្ពុជា-ថៃ មានការ ប៉ះទង្គិចរវាងទ័ពកម្ពុជា និងទ័ពថៃកើតមានឡើងជាបន្តបន្ទាប់ ។ មួយរយៈក្រោយមក ហិនដែរសិន បានបញ្ជាឲ្យ ដឹម ត្រឡប់ទៅ ប្រទេសសិង្ហបូរីវិញឲ្យឆាប់បំផុតតាមដែលអាចធ្វើទៅបាន ។

នៅពាក់កណ្តាលខែកញ្ញា ឆ្នាំ១៩៧៧ ដឹម បានទទួល សំបុត្រមួយច្បាប់ពី ហិនដែរសិន ដោយនៅក្នុងសំបុត្របានបញ្ជាក់ ថាឲ្យ ដឹម ចេញដំណើរនៅក្នុងពេលឆាប់នេះឆ្ពោះទៅកាន់ប្រទេស អេស្ប៉ាញដើម្បីទៅជួយរៀបចំទូករបស់ភ្នាក់ងារសម្ងាត់សេ.អ៊ី.អា ផ្សេងទៀត ។ ក្នុងឆ្នាំដដែលនោះ ដឹម បានធ្វើដំណើរទៅកាន់ ប្រទេសអេស្ប៉ាញ ដើម្បីទាក់ទងជាមួយខ្សែបណ្តាញម្នាក់ឈ្មោះ ម៉ៃឃើល ហេនដុន ។ មួយអាទិត្យក្រោយមក អ្នកទាំងពីរក៏បាន នាំគ្នាមកមើលទូកនិងរៀបចំនោះឲ្យបានច្រើន រួចទើបចេញពី ប្រទេសអេស្ប៉ាញទៅរត់ពន្ធកញ្ឆាជាមួយ ហេនដុន នៅប្រទេស ម៉ារ៉ុកវិញ ។ នៅទីនោះ ហេនដុន ទទួលរ៉ាប់រងខាងរត់ពន្ធកញ្ឆា ។ ចំណែក ដឹម ត្រូវទទួលបន្ទុកខាងទូក ។

នៅខែធ្នូ ឆ្នាំ១៩៧៧ ដឹម និង ឡែន បាននាំទូកទៅ ហូណូលូលូ ដើម្បីធ្វើដំណើរទៅប្រទេសសិង្ហបុរីវិញ ។ ឆ្លៀតឱកាស នោះ ដឹម ក៏បានជួបជាមួយ ហិនដែរសិន ម្តងទៀតនៅហូណូលូលូ ដើម្បីពិភាក្សាឲ្យបានលម្អិតអំពីផែនការធ្វើដំណើរនិងអំពីមនុស្ស ដែលត្រូវបានជួបនៅតាមផ្លូវ ។ មួយរយៈក្រោយមក ប៉ូល ហែនដែរសិន បានមកជួប ដឹម នៅហូណូលូលូ និងបានប្រាប់ឲ្យ ដឹម ត្រៀមខ្លួនដើម្បីចេញដំណើរមកបំពេញបេសកកម្មនៅថៃនិង កម្ពុជា ។ ក្រោយមក ដឹម បានជួបជាមួយ ហ៊ីលីព ដានីញ៉ែល និង អូទី នៅកោះតាង ប្រទេសថៃ ។ជាមួយគ្នានោះ ប៉ូល ហែនដែរសិន បានប្រាប់ថា អូទី នឹងមកជួបជាមួយ ដឹម នៅហូណូលូលូ មុនចាក ចេញទៅកាន់អាស៊ីអាគ្នេយ៍ ។ វីល្យ៉ាមក្លាក បានទទួលបញ្ជាពី ប៉ូល ហែនដែរសិន ដើម្បីស៊ើបការណ៍នៅកម្ពុជារួមមានៈ ១) ថត កប៉ាល់ចាប់ត្រីកម្ពុជាទាំងអស់តើលាបពណ៌អ្វីខ្លះ? តើមានល្បឿន យ៉ាងម៉េច? ២) ពិនិត្យមើលកប៉ាល់ចម្បាំង តើមានធុនអ្វីខ្លះហើយ មានតាំងភ្លើងអ្វីខ្លះ? ៣) ពិនិត្យសភាពការណ៍សមុទ្រកម្ពុជាឲ្យល្អិត ហើយថតយកកោះតូចៗមាត់សមុទ្រកម្ពុជាឲ្យបាន និង ៤) ពិនិត្យ និងរកមើលកន្លែងអង់តែនវិទ្យុ និងកន្លែងរ៉ាដាកម្ពុជាឲ្យច្បាស់ ។

នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៧៨ ដឹម ក៏បានជួបជាមួយ អូទី នៅលើទូកនៅហូណូលូលូ ។ ដឹម បាននិយាយ ថាគាត់ចាប់អារម្មណ៍ ទៅលើពួកកុម្មុយនីស្តថៃហាក់បីដូចជារីកខ្លាំងក្លា ។ ចំណែក អូទី បាននិយាយប្រាប់ ដឹម ថា គាត់ប្រហែលជាទៅប្រទេសឡាវវិញ

ដោយសារតែសភាពការណ៍នៅទីនោះងាយស្រួលធ្វើការ ។ លើសពីនេះទៅទៀត អូទី បានប្រាប់ដំណឹងដល់ ដឹម ថា “អំពីសកម្មភាពមេចោរថៃមួយរូបដែលមានឥទ្ធិពលបំផុតនិងមានកូនចៅចំនួនមួយម៉ឺននាក់ព្រមទាំងអាវុធជាច្រើនដោយបញ្ជាក់ថា ក្រុមចោរព្រៃនេះដាំអាភៀននិងធ្វើអាភៀនចម្រាញ់លក់នៅខាងលិចប្រទេសថៃ។ មួយរយៈក្រោយមក ដឹម ក៏បានជួប អូទីស ម្តងទៀតនៅសិង្ហបុរី ។ នៅទីនោះ អូទី ក៏បានប្រាប់នៅលើផែនទីពីទីតាំងដែល ដឹម ត្រូវនាំទូកទៅជួបគាត់នៅកំពង់ផែប៉ាតាយ៉ាប្រទេសថៃ ។ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៧៨ ឡែន និង ដឹម បានចាកចេញពីហូណូលូលូសំដៅមកកោះតាងវិញ ។ ក្នុងដំណើរអស់ពេលជិតកន្លះខែ អ្នកទាំងពីរក៏បានមកដល់កោះតាង ហើយក៏បានជួបជាមួយ ហ៊ីលីព ដែលជាភ្នាក់ងារសេ.អ៊ី.អានៅទីនោះ ។ ហ៊ីលីព បានណែនាំឲ្យ ដឹម ទៅរកទិញស្បៀង ប្រេងឥន្ធនៈ និងអំពីបច្ចេកទេសថតរូបកប៉ាល់ធុនតូចនៅកម្ពុជា ។ មូលហេតុដោយសារតែសហរដ្ឋអាមេរិកគិត ថាកោះតាងជាមូលដ្ឋានយន្តហោះបេ-៥២ នៅមហាសមុទ្រប៉ាស៊ីហ្វិក ហើយនិងជាមូលដ្ឋាននាវាមុជទឹកនៅភាគប៉ាស៊ីហ្វិកខាងលិច ។ ដូច្នេះសហរដ្ឋអាមេរិកមិនចង់ចេញពីកោះនោះទេ ។ ក្នុងឆ្នាំដដែល ដឹម និង ឡែន ចេញទៅសិង្ហបុរីម្តងទៀត ។ រស់នៅទីនោះប្រហែលបីអាទិត្យក៏បានជួបជាមួយ ដានីញ៉ែល ដែលជាសេ.អ៊ី.អា មួយរូបធ្វើការនៅក្រុមហ៊ុនធានារ៉ាប់រងកប៉ាល់សិង្ហបុរី ។ ដានីញ៉ែល បានឲ្យ ដឹម នូវសំបុត្រមួយច្បាប់ដែល ប៉ូល ហែនដែរសិន បានផ្ញើមក ។ នៅក្នុងសបុត្រនោះ ប៉ូល ហែនដែរសិន ណែនាំឲ្យ ដឹម ស្គាល់ ដានីញ៉ែល និង អូទី ថែមទៀត និងផ្តាំឲ្យ ដឹម បំពេញបេសកកម្មនៅកម្ពុជាដោយប្រុងប្រយ័ត្នបំផុត ។ ដានីញ៉ែល បានណែនាំឲ្យ ដឹម ក្តាប់ភារកិច្ចស៊ើបការណ៍នេះឲ្យជាប់ដោយបានបញ្ជាក់ថាកប៉ាល់កម្ពុជាមានធុនអ្វី? មានល្បឿនយ៉ាងណា? លាបពណ៌អ្វីខ្លះ ។ ទាំងនេះដើម្បីមានវិធានការវាយតបនឹងកប៉ាល់ទាំងនោះ ។ ម្យ៉ាងវិញទៀត ដានីញ៉ែល បានប្រាប់ចំណុចសំខាន់ដែលត្រូវថតយកឲ្យបាននិងឲ្យច្បាស់គឺផ្នែកកណ្តាលនៃសមុទ្រកម្ពុជាដែលនៅជិតព្រំដែនវៀតណាម ។ តាមសម្តីរបស់ ដានីញ៉ែល អាមេរិកមានការព្រួយបារម្ភខ្លាំងចំពោះអាស៊ីអាគ្នេយ៍ ព្រោះនៅភូមិភាគនេះចលនាកុម្មុយនីស្តរីកដុះដាលយ៉ាងខ្លាំង ។ ដោយមានការភ័យខ្លាចបែបនេះ បានជាសហរដ្ឋអាមេរិកឲ្យខ្លួន (ដានីញ៉ែល) ពិនិត្យនិងតាមដានប្រទេសកម្ពុជា ។ ជាចុងក្រោយ អ្នកទាំងពីរនាំគ្នាជជែកអំពីប្រដាប់ថតឈ្មោះ នីកូណូសទីបីដែលមានកែវថតមានទំហំ៣៥ម.មនិង៨០.ម.ម ។ នេះគឺប្រដាប់ថតមួយពិសេសដែលអាចថតនៅក្នុងទឹកក៏បាននៅលើទឹកក៏បាននៅក្នុងធាតុអាកាសសើមស្លួត ។ បន្ទាប់ពីជួបនិងទទួលផែនការពី ដានីញ៉ែល រួចមក ឡែន និង ដឹម បានចាកចេញពីសិង្ហបុរីឆ្ពោះទៅកាន់ប៉ាតាយ៉ា ។ រយៈពេលប្រាំថ្ងៃក្រោយមក អ្នកទាំងពីរក៏បានមកដល់កំពង់ផែប៉ាតាយ៉ានៅពេលរសៀល ។ ដឹម និង ឡែន បានចាកចេញពីប៉ាតាយ៉ានៅពេលយប់ហើយបើកទូកតម្រង់មកប្រទេសកម្ពុជា ។ ពីរថ្ងៃក្រោយមកទូករបស់ ដឹម និងឡែន បានមកដល់ភាគកណ្តាលនៃកម្ពុជាជិតកោះវៃ ។ ដឹម បានថតកោះនោះពីចម្ងាយស្រាប់តែមាននាវាចម្បាំងកម្ពុជាប្រដាប់នូវអាវុធកាំភ្លើង២០មីលីម៉ែត្រមួយគ្រឿងបានមកជិតហើយក៏បានបាញ់មកលើទូករបស់ ដឹម និង ឡែន ។ ចំណែក ដឹម នឹកស្មានថាជាចោរប្លន់ ។ ដូច្នោះហើយ ដឹម និងឡែន បានបាញ់តបតទៅវិញអស់ចំនួន១៥គ្រាប់ដោយសង្ឃឹមថានឹងអាចរត់គេចចេញបាន ប៉ុន្តែនាវារបស់យោធាខ្មែរក្រហមកម្ពុជាបានបាញ់កាំភ្លើងធំ២០ម.ម មកលើទូករបស់ ដឹម ។ ក្រោយពីទូករបស់ខ្លួនត្រូវគ្រាប់ ដឹម បានបញ្ឈប់ទូកហើយក៏ត្រូវយោធាខ្មែរក្រហមចាប់បានដែលស្ថិតនៅចម្ងាយ៣២គីឡូម៉ែត្រ ភាគនិរតីនៃកោះវៃ ។

នៅក្នុងចម្លើយសារភាពនេះ ដឹម បានបញ្ជាក់ថា ខ្លួន និងឡែន បានចូលមកដែនសមុទ្រកម្ពុជា អ្នកទាំងពីរថតរូបបានតែ២២ប៉ុស្ប៉ុណ្ណោះ ហើយចំពោះរង្វាន់ដែលទទួលបានបន្ទាប់ពីបេសកម្មនេះបានសម្រេចគឺទទួលជាប្រាក់សាមសិបភាគរយនៃការលក់កញ្ឆាដែលមាននៅក្នុងទូក និងបែងចែកទៅ ឡែន មួយភាគ ។ ដូច្នេះ ដឹម ត្រូវបានប្រាក់ចិតសិបម៉ឺនដុល្លារ និង ឡែន ទទួលបានសែសិបម៉ឺនដុល្លារ ។ ដឹម បានបញ្ជាក់ថា រង្វាន់ជាប្រាក់នេះគឺច្រើនល្មមដែលទាញឲ្យរូបលោកឲ្យមកបំពេញបេសកកម្មចារកម្មនៅកម្ពុជានិងសរសេរទៀតថាចំពោះកម្ពុជា សេ.អ៊ី.អា និងបញ្ជូនភ្នាក់ងាររបស់ខ្លួនគ្រប់ប្រភេទឲ្យមកស៊ើបការណ៍ជាបន្តបន្ទាប់ទៀត ។

**ស៊ិន សុធីតា**

# ពិធីសម្ពោធពាក្យស្លោកនៅវិទ្យាល័យក្រុងទេពនិមិ











# ត្តប៉ៃលិន ខេត្តប៉ៃលិន ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២










# សក្ខីកម្មរបស់ សាឡុត បាន ក្មួយប្រុស ប៉ុល ពត

*នៅថ្ងៃច័ន្ទ ទី២៣ ខែមេសា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបន្តដំណើរការនីតិវិធីរបស់ខ្លួនដោយកោះហៅសាក្សីសំខាន់ៗជាបន្តបន្ទាប់មកធ្វើសក្ខីកម្មដើម្បីទាញយកព័ត៌មានដែលគួរឲ្យជឿទុកចិត្តពាក់ព័ន្ធនឹងកិច្ចការរដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា តួនាទីនិងការទទួលខុសត្រូវរបស់ជនជាប់ចោទទាំងបីរូបគឺ នួន ជា, អៀង សារី និងខៀវ សំផន ព្រមទាំងការធ្វើទំនាក់ទំនងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អង្គជំនុំជម្រះសាលាដំបូងបានកោះហៅសាក្សីសំខាន់ជិតស្និទ្ធនឹងលេខាបក្សកុម្មុយនីស្តកម្ពុជាបំផុតគឺ សាឡុត បាន ដែលត្រូវជាក្មួយប្រុសបង្កើតរបស់ ប៉ុល ពត (សាឡុត ស) ។*

### *សក្ខីកម្មថ្ងៃទីមួយ (ថ្ងៃច័ន្ទ ទី២៣ ខែមេសា ឆ្នាំ២០១២)*

#### *សវនាការពេលព្រឹក*

*ជាកិច្ចចាប់ផ្តើមនៃដំណើរការនីតិវិធីសម្រាប់ថ្ងៃនេះ លោកប្រធានចៅក្រម និល ណុន បានបង្គាប់ឲ្យសាក្សីស្បថចំពោះមុខអង្គជំនុំជម្រះ និងបញ្ជាក់ពីសិទ្ធិរបស់សាក្សីក្នុងការផ្តល់សក្ខីកម្ម ។ បន្ទាប់មកទៀត ចៅក្រមបានផ្តល់វេទិកាសួរសាក្សីទៅឲ្យព្រះរាជអាជ្ញា ។ ជំនួយការព្រះរាជអាជ្ញាជាតិ ចាន់ តារាវស្ម៉ី បានចោទសួរសាក្សី សាឡុត បាន ដូចតទៅ ។ ដំបូង សាឡុត បាន ប្រាប់ថាគាត់មានអាយុ៦៧ឆ្នាំ ជាអតីតទាហាន និងកូនចំនួនប្រាំនាក់ ។ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់មានតំណែងជាអគ្គលេខា*



*ប៉ុល ពត ឬ សាឡុត ស*



*សាឡុត បាន កំពុងផ្តល់សក្ខីកម្មនៅសាលាក្តីខ្មែរក្រហម*

ធិការនៃក្រសួងការបរទេស ។ គាត់ជាក្មួយរបស់ ប៉ុល ពត ។ គាត់មានបងប្អូនចំនួនប្រាំបួននាក់ ។ ឪពុកម្តាយជាកសិករ ដូច្នេះក្រុមគ្រួសាររបស់គាត់ត្រូវបានចាត់ទុកក្នុងវណ្ណៈកសិករនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សាឡុត បាន បានអះអាងថា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់គឺជានិរសារ ចុងភៅ និងពេទ្យ ព្រមទាំងបានបញ្ជាក់ថាគាត់មិនមានជំនាញឬចំណេះដឹងអ្វីទាក់ទងនឹងខាងពេទ្យទេ ប៉ុន្តែពេលខ្លះក៏ត្រូវបានបង្គាប់ឲ្យចាក់ថ្នាំអ្នកជំងឺ ។ ទាក់ទងនឹងប្រវត្តិការងារបម្រើឲ្យបដិវត្តន៍ សាឡុត បាន និយាយថាការងារដំបូងរបស់គាត់គឺធ្វើជាអ្នកយាមតាមមន្ទីរជាច្រើនកន្លែង ។ នៅឆ្នាំ ១៩៦៧ គាត់ទទួលការងារមួយចំនួននៅទីក្រុងភ្នំពេញ ដូចជាកម្មករសំណង់ និងអ្នកធាក់ស៊ីក្លូជាដើម ។ គាត់បានបន្តទៀតថា នៅឆ្នាំដដែល គាត់បានភៀសខ្លួនចេញពីទីក្រុងភ្នំពេញទៅរស់នៅខេត្តក្រចេះដោយសារត្រូវបានគេចោទប្រកាន់ថាជាជនក្បត់ ។ សាឡុត បាន បន្ថែមទៀតថា ក្រោយមក គាត់បានទៅដល់ខេត្តរតនគិរី ហើយបានជួប សុន សេន, អៀង សារី, អៀង ធីរិទ្ធ និងមនុស្សជាច្រើននាក់ទៀត ។ នៅទីនោះ សាឡុត បាន បានឮឈ្មោះមន្ទីរ១០០ និងមន្ទីរ១០២ ប៉ុន្តែមិនដឹងថាមន្ទីរនោះមានទីតាំងពិតប្រាកដនៅទីណាទេ ។ គាត់បានជួប នួន ជា នៅពេលដែល សាឡុត បាន បម្រើការងារឲ្យមន្ទីរ១០០ វាយប្រយុទ្ធប្រឆាំងនឹង «ពួកចក្រពត្តិអាមេរិក» ។ សាឡុត បាន បញ្ជាក់ទៀតថា នៅឆ្នាំ១៩៦៨ គាត់បានចូលបម្រើបដិវត្តន៍ពេញសិទ្ធិដោយគ្មានលក្ខខណ្ឌអ្វីឡើយ គាត់បានសម្រេចចិត្តចូលបម្រើបដិវត្តន៍ដើម្បីរំដោះប្រទេសជាតិចេញពីការឈ្លានពានរបស់ពួកចក្រពត្តិនិយមអាមេរិក ។

ភាគីព្រះរាជអាជ្ញាជាតិបានសួរថាតើគាត់ទទួលបានមនោគមន៍វិជ្ជាខាងនយោបាយដែរឬទេនៅក្នុងអំឡុងរស់នៅខេត្តរតនគិរី? សាឡុត បាន ឆ្លើយតបថា នៅអំឡុងពេលនោះ គាត់មិនដឹងថាអ្វីទៅដែលហៅថាមនោគមន៍វិជ្ជាទេ ប៉ុន្តែគាត់បានកត់សម្គាល់ថាកាលណោះ គាត់ទទួលបានវគ្គបណ្តុះបណ្តាលជាច្រើនពីឯកសារសំខាន់ៗមួយចំនួនដូចជាភាពតស៊ូស្មោះត្រង់របស់បងប្អូនជនជាតិភាគតិច ។ ឯកសារទាំងអស់នោះពិតជាមានសារៈសំខាន់ពីព្រោះបក្សកុម្មុយនីស្តកម្ពុជាមានចេតនាពង្រីកភាពតស៊ូស្មោះត្រង់របស់បងប្អូនជនជាតិភាគតិចដើម្បីប្រមូលកម្លាំងរំដោះប្រទេសជាតិ ។ ខណៈពេលដែលភាគីព្រះរាជអាជ្ញាជាតិបានចោទសួរពីគោលការណ៍មាគ៌ាបក្សកុម្មុយនីស្តកម្ពុជា សាឡុត បាន និយាយថា គាត់មិនដឹងទេពីព្រោះគាត់មិនមែនជាស្ថាបនិកបង្កើតបក្សនេះឡើងទេ ។ ដោយគាត់មិនសូវចាំពីគោលការណ៍បក្សច្រើនទេ ប៉ុន្តែគ្រាន់តែចាំថាមានគោលការណ៍សីលធម៌ចំនួនដប់ពីរ ។ គាត់ក៏មិនដឹងពីគោលការណ៍ដាក់ទណ្ឌកម្មចំពោះការរំលោភគោលការណ៍បក្សស៊ីទេ ។ តមកទៀត ភាគីព្រះរាជអាជ្ញាជាតិបានចោទសួរ សាឡុត បាន ថាតើគាត់បានជូនដំណើរ ប៉ុល ពត ទៅប្រទេសចិននាអំឡុងឆ្នាំ១៩៦៩និង១៩៧០ដែរឬទេ? សាឡុត បាន អះអាងថា គាត់មិនដឹងថា ប៉ុល ពត ទៅប្រទេសចិននៅពេលណាទេ ហើយក៏មិនដឹងថាអ្នកណាជាអ្នកចេញសេចក្តីសម្រេចក្នុងការបញ្ជាទ័ពនៅពេលដែល ប៉ុល ពត មិននៅដែរ ។

ឆ្លើយតបនឹងសំណួររបស់ភាគីព្រះរាជអាជ្ញាជាតិ សាឡុត បាន បានបញ្ជាក់ថា គាត់មិនបានដឹងពីមូលហេតុនៃការផ្លាស់ការិយាល័យកណ្តាលរបស់បក្សកុម្មុយនីស្តកម្ពុជាទៅខេត្តរតនគិរីឡើយពីព្រោះរាល់សេចក្តីសម្រេចរបស់បក្សគឺជាការសម្ងាត់ ហើយថាគាត់គ្រាន់តែជាយុទ្ធជនធម្មតាម្នាក់តែប៉ុណ្ណោះ ។ ការិយាល័យនោះឋិតនៅក្នុងព្រៃជ្រៅងាយស្រួលនឹងបំពេញការងារ ហើយថ្នាក់ដឹកនាំរបស់បក្សស្នាក់នៅក្នុងខ្ទមដាច់ដោយឡែកពីគ្នា ។ ខណៈពេលដែលភាគីព្រះរាជអាជ្ញាជាតិបានសួរ សាឡុត បាន ថាតើនៅឆ្នាំ១៩៧០ គាត់បានឃើញ ខៀវ សំផន នៅខេត្តរតនគិរី ជាមួយនឹងមេដឹកនាំផ្សេងទៀតដែរឬទេ? សាឡុត បាន អះអាងថា កាលណោះគាត់មិនឃើញវត្តមានរបស់ ខៀវ សំផន នៅឡើយទេ ។ នៅក្នុងព្រៃថ្នាក់ ដឹកនាំបក្សតែងតែប្រជុំជានិច្ច ។ គាត់ស្គាល់មុខសមាជិករបស់ការិយាល័យកណ្តាលរបស់បក្ស និងសមាជិកគណៈអចិន្ត្រៃយ៍ទាំងអស់ ប៉ុន្តែមិនបានដឹងថានរណាទទួលបន្ទុកកិច្ចការអ្វីឲ្យលម្អិតបានទេ ។

បន្ទាប់មកទៀត ភាគីព្រះរាជអាជ្ញាជាតិបានដាក់បង្ហាញរូបថតមួយចំនួនដើម្បីសួរសាក្សីពីមនុស្សនៅក្នុងរូបថតទាំងនោះ ។ ប៉ុន្តែ សាឡុត បាន និយាយថាមិនស្គាល់នរណាម្នាក់ទេក្នុងរូបថតនោះលើកលែងតែ ប៉ុល ពត ។ រូបថតនោះត្រូវបានថតក្រោយពេលអង្គសមាជសភាឆ្នាំ១៩៧១ ប៉ុន្តែ សាឡុត បាន អះអាងថាគាត់មិន




អៀង សារី (រូបខាងស្តាំ) ព្រមទាំងកម្មាភិបាលខ្មែរក្រហមដទៃទៀតកំពុងរាដៃលាគណៈប្រតិភូមកពីទីម័រខាងកើត ។ ទីតាំងក្នុងរូបថតនេះ គឺជាមន្ទីរប-១ ឬក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលសម័យក្រោយមក អគារនេះត្រូវបានប្រើប្រាស់ជាទីស្តីការគណៈរដ្ឋមន្ត្រី រហូតដល់ឆ្នាំ២០០៦ នៅពេលដែលអគារនេះត្រូវបានបំផ្លាញចោលដើម្បីសាងសង់អគារទីស្តីការគណៈរដ្ឋមន្ត្រីថ្មី ក្រោមជំនួយរបស់រដ្ឋាភិបាលចិន ។

បានចូលរួមអង្គប្រជុំនោះទេ ។ ឆ្លើយតបនឹងសំណួររបស់ភាគីព្រះរាជអាជ្ញាជាតិ សាឡុត បាន រៀបរាប់ថាគាត់បានចំណាយពេលនៅក្បែរ ប៉ុល ពត ច្រើនជាង អៀង សារី បើទោះបីជាគាត់បានធ្វើការនៅក្រសួងការបរទេសជាមួយ អៀង សារី ក៏ដោយ ។

ក្រោយមក ភាគីព្រះរាជអាជ្ញាជាតិបានសួរឲ្យ សាឡុត បាន បកស្រាយគោលការណ៍សីលធម៌ទាំងដប់ពីររបស់បក្ស ប៉ុន្តែ សាឡុត បាន អះអាងថាគាត់មិនចាំទេ ហើយគ្រាន់តែដឹងច្បាស់ថា ក្នុងរបបនោះសូម្បីតែម្ទេសមួយក៏លួចមិនបានដែរ ។ ខណៈពេលដែលភាគីព្រះរាជអាជ្ញាជាតិបានចោទសួរថាតើខ្មាំងមាននៅឯណាខ្លះ? សាឡុត បាន ឆ្លើយថាគាត់មិនដឹងទេ ប៉ុន្តែអាចបញ្ជាក់ថាខ្មាំងភាគច្រើនមានបង្កប់ក្នុងក្រុមពួកវណ្ណៈដែលបំផ្លាញជាតិ ។ ទាក់ទងនឹងបញ្ហាសាសនា សាឡុត បាន បានឲ្យដឹងថា គាត់បានឮថាសាសនាព្រះពុទ្ធគឺជាសាសនារបស់រដ្ឋ ប៉ុន្តែបានអះអាងថាអ្នកដឹកនាំសាសនាដូចជាព្រះសង្ឃមិនត្រូវបានចាត់ទុកថាជាខ្មាំងឡើយ ។ សាឡុត បាន បន្ថែមទៀតថា ពេលនោះអ្នកស្លៀកសម្លៀកបំពាក់ពណ៌ឆើតត្រូវបានបាញ់សម្លាប់ចោល អាស្រ័យហេតុនេះព្រះសង្ឃបានសឹកដោយខ្លួនឯង ។ ទាក់ទងនឹងជនជាតិចាម សាឡុត បាន អះអាងថា គាត់មិនបានឮថ្នាក់ដឹកនាំចេញគោលការណ៍អ្វីប្រឆាំងនឹងជនជាតិចាមទេ ។

ក្រោយពីឈប់សម្រាកពេលព្រឹក ជំនួយការព្រះរាជអាជ្ញាជាតិលោក តាភរស្មី បានបន្តសួរសាក្សីពីព្រឹត្តិការណ៍នៅរវាងចន្លោះឆ្នាំ១៩៧៣ និង១៩៧៥ ។ ភាគីព្រះរាជអាជ្ញាជាតិបានសួរ សាឡុត បាន ពីបញ្ហាហិរញ្ញវត្ថុ ។ ក្នុងអំឡុងពេលនោះ បក្សកុម្មុយនីស្តកម្ពុជាមានគម្រោងបោះពុម្ពក្រដាសប្រាក់ថ្មី ប៉ុន្តែនៅចន្លោះឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៣ ក្រដាសប្រាក់បោះពុម្ពក្នុងរបបគ្រប់គ្រង លន់ នល់ នៅតែបន្តចាយវាយក្នុងទីផ្សារនៅឡើយទេ ។ រហូតមកដល់ឆ្នាំ១៩៧៣ ការចាយវាយក្រដាសប្រាក់បានកាត់បន្ថយ ហើយត្រូវបំផ្លាញចោលទាំងស្រុងនៅឆ្នាំ១៩៧៥ ។ ឆ្លើយតបនឹងសំណួរទាក់ទងនឹងការបំផ្លាញកម្មសិទ្ធិឯកជន សាឡុត បាន អះអាងថា ការបំផ្លាញកម្មសិទ្ធិឯកជននេះមិនមែនជាមហិច្ឆតាទេ ប៉ុន្តែការអនុវត្តបែបនេះគឺជាគោលដៅសម្រាប់របបសមូហភាពមួយ ដើម្បីផ្តួលរំលំខ្មាំង ។ របបសមូហភាពគឺជារបបដែលប្រកាន់យក «លទ្ធិប្រជាធិបតេយ្យបែបមជ្ឈការ» ។ នៅពេលដែលភាគីព្រះរាជអាជ្ញាជាតិសួរថាតើបានដឹងពីការចាប់គូឲ្យរៀបការជាប្តីប្រពន្ធក្នុងអំឡុងរបបខ្មែរក្រហមដែរឬទេ? សាឡុត បាន បាននិយាយថា គាត់មិនបានដឹងពីបញ្ហានេះទេ ។ បន្ទាប់មកទៀតភាគីព្រះរាជអាជ្ញាជាតិបានសួរ សាឡុត បាន ថាតើគាត់តែងតែនៅក្បែរ ប៉ុល ពត នៅពេលដែល ប៉ុល ពត ធ្វើការនៅអមលាំងមែនដែរឬទេ? សាឡុត បាន ឆ្លើយថាគាត់គ្រាន់តែជាយុទ្ធជនសាមញ្ញម្នាក់ដែលតាមបម្រើ ប៉ុល ពត តែប៉ុណ្ណោះ ហើយថា មានយុទ្ធជនច្រើនណាស់ ដែលបានបម្រើជាអ្នកយាមឲ្យប៉ុល ពត ។ នៅអំឡុងពេលជម្លៀសប្រជាជន សាឡុត បាន បញ្ជាក់ថាគាត់នៅយាមខ្ទមរបស់ថ្នាក់ដឹកនាំនៅក្នុងព្រៃ ។ ភាគីព្រះរាជអាជ្ញាបានសួរថាតើ សាឡុត បាន ដឹងថា អៀង សារី នៅឯណាក្នុងចន្លោះឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៥ដែរឬទេ? សាឡុត បាន បញ្ជាក់ថា ក្នុងអំឡុងពេលនោះគាត់មិនដឹងថា អៀង សារី មានវត្តមាននៅទីណាទេ ប៉ុន្តែបាននិយាយថាក្រោយថ្ងៃរំដោះគាត់បានអមដំណើរ អៀង សារី ទៅទីក្រុងប៉េកាំងប្រទេសចិនដើម្បីជួបប្រជុំជាមួយនឹងអង្គការសហប្រជាជាតិជាមួយនឹងបុគ្គលិកក្រសួងការបរទេសមួយចំនួនទៀត ។

ភាគីព្រះរាជអាជ្ញាជាតិបាននិយាយថា សាឡុត បាន មានទំនាក់ទំនងជិតស្និទ្ធណាស់ជាមួយនឹង ប៉ុល ពត ហេតុដូច្នេះព្រះរាជអាជ្ញាបានសួរថាតើដឹងពីការជួបប្រជុំរវាង ប៉ុល ពត ជាមួយនឹងថ្នាក់ដឹកនាំផ្សេងទៀតដែរឬទេ ។ សាឡុត បាន អះអាងថា ព័ត៌មានទាក់ទងនឹងការប្រជុំធំៗមិនត្រូវបានផ្សព្វផ្សាយឲ្យអ្នកនៅក្រោមបង្គាប់ដឹងទេ ហើយថាគាត់បានត្រឹមតែប្រឹងប្រែងធ្វើតាមបញ្ជារបស់ ប៉ុល ពត បំពេញការងារគ្រប់បែបយ៉ាងដើម្បីការពារនិងធានាសុវត្ថិភាពជូន ប៉ុល ពត ។ សាឡុត បាន បន្តទៀតថាគាត់ក្លាយជាអ្នកការពារ ប៉ុល ពត តាំងពីឆ្នាំ១៩៧០រហូតមក ដូច្នេះគាត់នៅស្និទ្ធ ប៉ុល ពត ជាងគេ ហើយបន្ទាប់មកគឺ អៀង សារី ។ ឆ្លើយតបនឹងសំណួររបស់ភាគីព្រះរាជអាជ្ញាជាតិថាតើ ប៉ុល ពត និងអៀង សារី ធ្លាប់បានចុះទៅត្រួតពិនិត្យតំបន់រំដោះជាមួយគ្នាដែរឬយ៉ាងណា? សាឡុត បាន បដិសេធថា គាត់មិនដែលការពារ អៀង សារី នៅពេលដែល អៀង សារី ធ្វើដំណើរតាមតំបន់ទេ ប៉ុន្តែគាត់ទទួលស្គាល់ថា ប៉ុល ពត និងអៀង សារី ធ្លាប់ចុះទៅត្រួតពិនិត្យ

តាមតំបន់ជាមួយគ្នាម្តងពីរដងដែរ ហើយថា ប៉ុល ពត ធ្វើដំណើរទៅរាងតំបន់នៅពេលដែលមានការបើកវគ្គបណ្តុះបណ្តាលដល់សមាជិកបក្សតែប៉ុណ្ណោះ ។

ខណៈពេលនេះ វេទិកាសួរសាក្សីត្រូវបានប្រគល់ទៅឲ្យជំនួយការព្រះរាជអាជ្ញាអន្តរជាតិលោក ដឺ វីលដ៍ ។ លោកបានបញ្ជាក់ថាលោកនឹងផ្តោតលើព្រឹត្តិការណ៍ក្នុងចន្លោះឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩ ។ ប៉ុន្តែមុននឹងឈានដល់ការចោទសួរពីព្រឹត្តិការណ៍អស់ទាំងនោះ ព្រះរាជអាជ្ញាអន្តរជាតិបានសួរសំណួរដើម្បីបញ្ជាក់លើចំណុចខ្លះៗដែលសាក្សីបានឆ្លើយកន្លងមក ។ ឆ្លើយតបនឹងសំណួររបស់ព្រះរាជអាជ្ញា សាឡុត បាន និយាយថា គាត់បានចាកចេញពីឪពុកម្តាយរបស់គាត់នៅពេលដែលគាត់មានអាយុ៧ឆ្នាំ ។ គាត់បានទៅរស់នៅជាមួយនឹងឪពុកមារបស់គាត់ដែលត្រូវជាបងប្រុសរបស់ ប៉ុល ពត ហើយនៅពេល គាត់មានអាយុ១៥និង១៦ឆ្នាំទើបគាត់ទៅរស់នៅជាមួយនឹង ប៉ុល ពត ។ នៅអំឡុងពេលនោះ ប៉ុល ពត បានក្លាយជាអាណាព្យាបាលរបស់គាត់ ។ ព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងពីបទសម្ភាសចំនួនប្រាំដែល សាឡុត បាន ធ្វើជាមួយនឹងសហចៅក្រមស៊ើបអង្កេត ។ ក្នុងបទសម្ភាសមួយនោះ សាឡុត បាន និយាយថា "ខ្ញុំបានរស់នៅជាមួយនឹង អៀង សារី ចាប់តាំងពីខ្ញុំមានអាយុ១៣ឆ្នាំមកម្ល៉េះ ។ ដោយសារតែខ្ញុំរស់នៅជាមួយនឹងពូរបស់ខ្ញុំ (ប៉ុល ពត) ហើយ អៀង សារី ក៏រស់នៅក្នុងផ្ទះតែមួយជាមួយនឹងពូខ្ញុំ ខ្ញុំក៏បានរស់នៅជាលក្ខណៈគ្រួសារជាមួយនឹង អៀង សារី ដែរ ។ ខ្ញុំគោរព និងស្រឡាញ់ អៀង សារី ដូចពូរបស់ខ្ញុំដែរ" ។ ជាការឆ្លើយតបនឹងអំណះអំណាងខាងលើ សាឡុត បាន ទទួលស្គាល់ថាគាត់ពិតជាបាននិយាយដូច្នេះមែន ហើយថារឿងនេះគឺជាការពិត ។ បន្ថែមលើនេះ សាឡុត បាន ក៏បានសុំទោសចំពោះការប្រាប់អាយុច្រលំនៅពេលដែលគាត់ចាប់ផ្តើមរស់នៅជាមួយនឹងពូរបស់គាត់ ។

### សវនាការពេលរសៀល

ក្រោយពីឈប់សម្រាកអាហារថ្ងៃត្រង់ អង្គជំនុំជម្រះសាលាដំបូងបានបន្តដំណើរការនីតិវិធីរបស់ខ្លួនដោយភាគីព្រះរាជអាជ្ញាធ្វើការសាកសួរទៅសាក្សី សាឡុត បាន ។ ព្រះរាជអាជ្ញាអន្តរជាតិបានសួរថាតើគាត់ធ្វើការនៅឯណាក្រោយថ្ងៃជ័យជម្នះ ១៧ មេសា ឆ្នាំ១៩៧៥ ។ សាឡុត បាន បញ្ជាក់ថា គាត់ធ្វើការនៅក្រសួងការពារជាតិបានរយៈពេលមួយខែនៅពេលដែលគាត់បានមកដល់ទីក្រុងភ្នំពេញលើកដំបូង ។ ក្រោយមកទៀត គាត់បានក្លាយជាអ្នកសម្អាតនៅក្រសួងការបរទេស បន្ទាប់ពី ឈឹម សំអោក បានចាត់តាំងកិច្ចការនេះឲ្យគាត់ ។ ប៉ុន្តែ ក្រោយពេលដែល អៀង សារី ត្រឡប់មកពីបរទេសវិញ គាត់ត្រូវចាត់តាំងឲ្យមើលការខុសត្រូវផ្នែកសតិអារម្មណ៍របស់មនុស្សនៅក្នុងក្រសួងការបរទេសទាំងអស់ ។ ព្រះរាជអាជ្ញាអន្តរជាតិបានសួរថាតើ អៀង សារី មានមុខតំណែង




ជាអ្វីក្រោយពេលដែលគាត់ត្រឡប់មកពីបរទេសវិញ? សាឡុត បាន ឆ្លើយតបថាមុខតំណែងរបស់ អៀង សារី គឺជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកផ្នែកកិច្ចការបរទេស ។ បន្ថែមលើនេះ សាឡុត បាន ក៏បាននិយាយថាគាត់ធ្លាប់បានឮថា អៀង សារី គឺជាសមាជិករបស់គណៈមជ្ឈិម ប៉ុន្តែការអះអាងបែបនេះមិនច្បាស់លាស់ទេ ។

នៅក្នុងបទសម្ភាសមួយទៀត សាឡុត បាន និយាយថា ខៀវ សំផន មិនមែនជាសមាជិករបស់គណៈអចិន្ត្រៃយ៍ទេ ។ សាឡុត បាន បញ្ជាក់ថាគាត់គ្រាន់តែឮតៗគ្នាទេ ។ ព្រះរាជអាជ្ញាអន្តរជាតិ

បានសួរថាតើបុគ្គលអាចចេញសេចក្តីសម្រេចដោយខ្លួនឯងបានទេ ។ សាឡុត បាន និយាយថា គាត់មិនសូវច្បាស់ពីគោលការណ៍នេះប៉ុន្មានទេ ប៉ុន្តែបានអះអាងថាតាមគោលការណ៍ទូទៅរាល់សេចក្តីសម្រេចត្រូវធ្វើឡើងដោយសមូហភាព ។

បន្ទាប់មកទៀត ព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងពីបទសម្ភាសថ្មីមួយដែល សាឡុត បាន រៀបរាប់ថាគាត់បានឃើញសមាជិកក្នុងជួរដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាតែងតែជួបប្រជុំនៅមន្ទីរក-១ ។ សាឡុត បាន ឆ្លើយតបថានេះគឺជាការពិត




ហើយ បានពន្យល់បន្ថែមថា មន្ទីរក-១ នេះគឺជាកន្លែងដែលមេដឹកនាំធំៗជួបប្រជុំគ្នា ។ ឆ្លើយតបនឹងសំណួររបស់ព្រះរាជអាជ្ញាអន្តរជាតិថាតើគាត់ធ្លាប់ចូលរួមក្នុងអង្គប្រជុំជាមួយនឹងថ្នាក់ដឹកនាំដែរឬទេ? សាឡុត បាន បញ្ជាក់ថា គាត់មិនដែលបានចូលប្រជុំអ្វីទេ ហើយកាលដែលគាត់ទៅមន្ទីរក-១ ដោយសារតែប្រពន្ធរបស់គាត់គឺជាចុងភៅនៅទីនោះ ។ ទាក់ទងនឹងមន្ទីរ៨៧០ សាឡុត បាន បានរៀបរាប់ថាមន្ទីរ៨៧០ នេះមិនមានទីតាំងច្បាស់លាស់ទេ ហើយតែងតែចល័តតាមសភាពការណ៍ ។ មន្ទីរ៨៧០ នេះគឺជាការិយាល័យរបស់គណៈអចិន្ត្រៃយ៍ ។

ខណៈពេលដែលព្រះរាជអាជ្ញាសួរថាតើខៀវ សំផន បានទៅក្រសួងការបរទេសដែរឬយ៉ាងណា? សាឡុត បាន អះអាងថា ខៀវ សំផន ធ្លាប់ទៅក្រសួងការបរទេសចំនួនពីរបីដងដែរដើម្បីពិភាក្សាពីបញ្ហាសំបុត្រយន្តហោះ ។ ដោយឡែកព្រះរាជអាជ្ញាអន្តរជាតិបានចាប់ផ្តើមសួរទាក់ទងនឹងរចនាសម្ព័ន្ធនៃក្រសួងការបរទេស និងតួនាទីផ្ទាល់របស់សាឡុត បាន ។ គាត់ និយាយថា គាត់មិនចេះភាសាបរទេសទេអាស្រ័យហេតុនេះគាត់មិនចង់ទទួលយកកិច្ចការនៅក្រសួងការបរទេសឡើយ ។ ប៉ុន្តែ អៀង សារី បាននិយាយប្រាប់ គាត់ឲ្យមកជួយកិច្ចការរបស់ អៀង សារី ដូច្នេះហើយទើប អៀង សារី បានតែងតាំងគាត់ជាអគ្គលេខាធិការនៃក្រសួងការបរទេស ។ ទោះជាយ៉ាងណាក្តី សាឡុត បាន មិនដឹងថា អៀង សារី មានមុខតំណែងអ្វីទេ ប៉ុន្តែគ្រាន់តែដឹងថាកិច្ចការរបស់ អៀង សារី គឺធ្វើយ៉ាងណាឲ្យអ្នករាល់គ្នាយល់ស្របគ្នាលើបញ្ហាណាមួយ ។

ព្រះរាជអាជ្ញាអន្តរជាតិបានសន្មតថា អៀង សារី បានតែងតាំងសាឡុត បាន ជាអគ្គលេខាធិការក្រសួងការបរទេសដោយសារតែការជឿទុកចិត្ត ហើយក៏បានសួរថាតើ សាឡុត បាន សប្បាយចិត្តនឹងការបម្រើការងារអស់រយៈពេលបីឆ្នាំនៅក្រសួងការបរទេសនោះដែរឬទេ? សាឡុត បាន បានអះអាងថាគាត់ពិតជារីករាយនឹងបម្រើការងារនៅទីនោះ ។ ឆ្លើយតបនឹងសំណួររបស់ព្រះរាជអាជ្ញាអន្តរជាតិរាល់ផ្នែកផ្សេងៗគ្នានៅឯក្រសួងការបរទេស សាឡុត បាន រៀបរាប់ថាមានផ្នែកចំនួនពីរខុសៗគ្នានៅក្រសួងការបរទេស ៖ ១) ផ្នែកកិច្ចការបរទេស ៖ រួមមានអ្នកបញ្ញវន្តដែលចេះភាសាបរទេស និង ២) ផ្នែកបញ្ហាសតិអារម្មណ៍និងសេដ្ឋកិច្ច ។ សាឡុត បាន ជាអ្នកទទួលបន្ទុកផ្នែកបញ្ហាសតិអារម្មណ៍និងសេដ្ឋកិច្ច ។ ព្រះរាជអាជ្ញាអន្តរជាតិបានសួរ សាឡុត បាន ទាក់ទងនឹងមន្ទីរប-១ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេស ។ សាឡុត បាន បានអះអាងថាគ្មានមន្ទីរណាមួយដែលស្ថិតនៅក្រៅក្រសួងការបរទេសទេ មានតែផ្ទះវីឡាថ្មីមួយតែប៉ុណ្ណោះ ។ រាល់ពេលដែលមានភ្ញៀវ អ្នកសម្អាតតែងតែសម្អាតផ្ទះនោះដើម្បីឲ្យភ្ញៀវស្នាក់នៅ ។ បន្ថែមលើនេះព្រះរាជអាជ្ញាអន្តរជាតិ

បានសួរ សាឡុត បាន ថាតើ“បញ្ហាសតិអារម្មណ៍” នេះមានន័យដូចម្តេច ។ សាឡុត បាន បាននិយាយថា “បញ្ហាសតិអារម្មណ៍” រួមបញ្ចូលកត្តាជាច្រើនដើម្បីធ្វើឲ្យប្រជាជនរស់នៅដោយមានសីលធម៌ ក្លាយជាអ្នកស្នេហាជាតិ ការពារ និងកសាងប្រទេសជាតិ ។

ព្រះរាជអាជ្ញាបានបន្តសួរថាតើធ្លាប់បង្រៀន “មនោគមន៍វិជ្ជា” ដល់កម្មាភិបាលដែរឬទេ? សាឡុត បាន ឆ្លើយតបថា គាត់មិនដឹងថាមនោគមន៍វិជ្ជានេះ មានន័យយ៉ាងដូចម្តេចទេ ប៉ុន្តែបាននិយាយថាគាត់បានផ្តល់វគ្គបណ្តុះបណ្តាលលើបញ្ហាសតិអារម្មណ៍ដល់កម្មាភិបាលនៅក្រសួងការបរទេសដើម្បីជំរុញឲ្យកម្មាភិបាលទាំងអស់នេះការពារ និងកសាងប្រទេសជាតិ ។ សាឡុត បាន ក៏បានបដិសេធថា គាត់មិនដែលធ្វើការជាមួយនឹងបញ្ញវន្តផ្សេងៗនៅក្រសួងការបរទេសឡើយ ហើយគាត់ក៏គ្មានការទទួលខុសត្រូវលើបញ្ញវន្តក្នុងក្រសួង និងបញ្ញវន្តក្រៅក្រសួងឡើយ ពីព្រោះថា អៀង សារី គឺជាអ្នកទទួលបន្ទុកខាងលើនេះ ។ សាឡុត បាន បន្ថែមទៀតថានៅក្រសួងការបរទេសមានបែងចែកជាពីរផ្នែកទៀតគឺមួយផ្នែកសម្រាប់បញ្ញវន្តនិងមួយផ្នែកទៀតសម្រាប់កសិករ ។ លើសពីនេះ អៀង សារី គឺជាអ្នកគ្រប់គ្រងធំបំផុតនៅក្រសួងការបរទេសនេះ ហើយគាត់ត្រូវតែទទួលការអនុញ្ញាតពីអៀង សារី មុននឹងបំពេញកិច្ចការណាមួយ ។ ប៉ុន្តែ ក្នុងករណីដែល អៀង សារី មិននៅ ប៉ង់ អាចចេញសេចក្តីសម្រេចបានដោយឯករាជ្យដោយមិនចាំបាច់ជម្រាបដល់ អៀង សារី ឡើយ ។

ទាក់ទងបន្ថែមនឹងកិច្ចការរបស់ សាឡុត បាន គាត់បញ្ជាក់ថា គាត់ត្រូវរាយការណ៍ឲ្យ អៀង សារី រួមទាំងកិច្ចការសន្តិសុខដែរ ។ សាឡុត បាន និយាយថាការរាយការណ៍នេះគឺធ្វើឡើងផ្ទាល់មាត់ មិនចាំបាច់សរសេរអ្វីទេ ។ បន្ថែមលើនេះ រាល់ពេលប្រជុំម្តងៗ អៀង សារី តែងតែណែនាំពីបញ្ហាបច្ចេកទេសការងារ និងការត្រួតពិនិត្យមើលការងារខ្លួនឯង ហើយជួនកាលក៏មាននិយាយពីបញ្ហាខ្មាំង ។ នៅក្នុងអង្គប្រជុំទិតៀនម្តងៗកម្មាភិបាលម្នាក់ៗតែងតែលើកឡើងពីចំណុចខ្សោយរបស់ខ្លួន ។ ប្រសិនបើមិនធ្វើដូច្នេះទេ កម្មាភិបាលនោះនឹងក្លាយជាសារធាតុអាក្រក់បំផ្លាញប្រទេសជាតិ ។ បើមិនដែលលើកពីចំណុចខ្សោយរបស់ខ្លួន ហើយប្រព្រឹត្តកំហុសទៀត កម្មាភិបាលនោះត្រូវតែកែប្រែខ្លួនឲ្យបានឆាប់ បើមិនដូច្នោះទេ កម្មាភិបាលនោះនឹងត្រូវដូរទៅរស់នៅផ្ទះថ្មីជាមិនខាន ។

**សក្ខីកម្មរបស់ សាឡុត បាន (នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២)**

នៅថ្ងៃទីពីរនេះ សាឡុត បាន រៀបរាប់ថា នៅពេល អៀង សារី ចេញទៅក្រៅប្រទេស គាត់ជាដឹកនាំប្រជុំការងាររបស់ក្រសួងការបរទេសតាមការណែនាំពី ឈឹម សំអោក ហៅ ប៉ង់ មកពីមន្ទីរមជ្ឈិមអំពីការបង្ការមិនឲ្យមានទំនាស់ និងការរក្សាសន្តិសុខ ។ ប៉ុន្តែ សាឡុត បាន បានបញ្ជាក់ថា គាត់មិនមានសិទ្ធិសម្រេចកិច្ចការរបស់ក្រសួងនោះទេ ។ ប្រសិនបើគាត់មានភារកិច្ចទៅក្រៅប្រទេសជាមួយ អៀង សារី ដែរនោះ គឺមាន ចៀម, នី (នីកន) ,ទិក សាគុណ និង ពេជ្រ ប៊ុណ្ណារ៉េត ដឹកនាំកិច្ចការនៅក្នុងក្រសួងជំនួសដែលមានតែការងារជីវភាពប៉ុណ្ណោះ ។

សាឡុត បាន ឲ្យដឹងថានៅក្នុងក្រសួងការបរទេសមិនទាន់មានរៀបចំជាការិយាល័យពិធីការទេគឺបុគ្គលិកត្រូវធ្វើការតាមជំនាញរៀងៗខ្លួន និងតាមការចាត់តាំងដោយមាន ដួង ប្រាសិទ្ធិ និង គាត ឈន់ ធ្វើកិច្ចការនេះ ។ រីឯ ភ្ញៀវបរទេស និងបញ្ញវន្តដែលមកស្រុកខ្មែរ ក្រសួងការបរទេសមិនទទួលបន្ទុកទេ គឺខាង ប៉ង់ ទៅទទួលនៅព្រលានយន្តហោះ លើកលែងតែស្ថានទូត និងបុគ្គលិកទូតនៅបរទេសប៉ុណ្ណោះ ។ ចំពោះការទាក់ទងព័ត៌មានទៅក្រសួងការបរទេសនៅក្រៅប្រទេសធ្វើឡើងតាមរយៈក្រសួងការបរទេសតែម្តង ប៉ុន្តែ គាត់មិនបានដឹងថាជាព័ត៌មានអ្វីនោះទេគឺគាត់ដឹងតែការងាររបស់គាត់ខាងផ្នែកជីវភាពប៉ុណ្ណោះ ។

ចំណែកឯផ្សាររដ្ឋ (ផ្សារធំថ្មី) នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេសដែលជាកន្លែងប្រមូលផ្តុំផលិតផលដែលក្រសួងការបរទេសដាំដុះបាន និងប្រមូលពីក្រសួងមន្ទីរផ្សេងៗដើម្បីចែកជូនទៅភ្ញៀវបរទេស ដោយមានបុគ្គលិកប្រមាណពី១៥០ ទៅ៣០០នាក់ធ្វើការនៅផ្សាររដ្ឋនេះរួមមានផ្នែកដាំដុះ និងដឹកជញ្ជូន ។

សាឡុត បាន អះអាងថា ប៉ង់ អ្នកជាជ្រើសរើសបុគ្គលិកនៅមន្ទីរប-១ (ក្រសួងការបរទេស) ហើយគាត់ក៏មានសិទ្ធិសម្រេចកិច្ចការខ្លះនៅពេល អៀង សារី អវត្តមានដែរ ។ គាត់បន្តថា ប៉ង់ ក៏បានបញ្ជូនបងថ្លៃរបស់គាត់ឈ្មោះ ហុង ហៅ ឃឹម នៅភូមិភាគឧត្តរមកក្រសួងការបរទេសដែរ ហើយក្រោយមកត្រូវបានចាប់ខ្លួន ។

មិនមានឯកសារ និងការប្រកាសជាផ្លូវការ ពីតួនាទីរបស់ ប៉ង់ ទេ ប៉ុន្តែ បាន ឲ្យដឹងថា ប៉ង់ ជាសមាជិករបស់មជ្ឈិម ។

គាត់និយាយថា អៀង សារី ក៏បានផ្តាំគាត់ដែរថាពេល ប៉ង់ មកក្រសួងការបរទេស ប៉ង់ អាចមានសិទ្ធិសម្រេចលើការងារមួយចំនួនបាន ។ សាឡុត បាន បន្តថា ប៉ង់ បានជិះម៉ូតូមកជួបនឹងគាត់ និង ជួប ចៀម នៅក្រសួងការបរទេសដើម្បីយកបុគ្គលិកក្រសួងដែលមកពីបរទេសចេញទៅខាងក្រៅ ហើយពេលខ្លះ ប៉ង់ គ្រាន់តែសរសេរសំបុត្រផ្ញើមកឲ្យយកមនុស្សចេញប៉ុណ្ណោះ ។ បាន បន្ថែមថា គាត់មិនដែលឃើញបុគ្គលិកដែលយកពីក្រសួងត្រឡប់មកវិញទេ ហើយអ្នកដែលបាត់ខ្លួននោះមាន ជា ហួន ហៅ វ៉ាញ គណៈភូមិភាគពាយ័ព្យ, មាឃ ទូច ហៅ កែម (បញ្ញវន្ត) , តូច ភឿន, តូច ខាំឌឿន និង អ៊ិន សូកាន ។

សាឡុត បាន រៀបរាប់ថា ប៉ង់ បានយកកម្មាភិបាលមួយចំនួនពីខេត្តមកផ្ញើនៅក្នុងក្រសួងការបរទេសព្រោះកន្លែងនេះពុំមានអាវុធម្យ៉ាងទៀតកម្មាភិបាលទាំងនោះគិតថានឹងទទួលបានភាពកក់ក្តៅពីគាត់ដែលជាអ្នកទទួលខុសត្រូវ ។ កម្មាភិបាលទាំងនោះត្រូវជួយការងារសរសេរ និងការងារផ្សេងៗទៀតតាមការចាត់តាំងមុននឹងចាប់ខ្លួន ហើយក្នុងចំណោមនោះគាត់ស្គាល់ឈ្មោះ ណាត នៅខាងយោធាដែរ ។

មានចម្លើយសារភាពមួយបានផ្ញើមកក្រសួងការបរទេសដោយមួយចំនួន សួង ស៊ីគឿន បានរក្សាទុក ។ ចម្លើយសារភាពដែលបានឃើញនៅក្នុងក្រសួងគឺចម្លើយសារភាពរបស់ កុយ ធួន ។ អៀង សារី បានយកចម្លើយសារភាពនេះ មកអានឲ្យកម្មាភិបាលថ្នាក់លើ និងថ្នាក់កណ្តាលស្តាប់នៅក្នុងអង្គប្រជុំ ។ បន្ទាប់ពីអានរួច សាឡុត បាន មានការភិតភ័យដោយគិតថា ថ្ងៃណាមួយនឹងដល់វេនគាត់មិនខាន ។

ពេលនោះ មានចម្លើយសារភាពជាច្រើនក៏បានឆ្លើយដាក់ គាត ឈន់ និង ជួន ប្រាសិទ្ធិ ប៉ុន្តែ អៀង សារី បានប្រាប់ ប៉ុល ពត ថា ប្រសិនបើចាប់បុគ្គលទាំងពីរនាក់នេះនឹងត្រូវលុបក្រសួងការបរទេសចោលតែម្តង ហើយ ប៉ុល ពត បានឯកភាពពីការមិនចាប់ខ្លួននេះដែរ ។

សាឡុត បាន បន្ថែមថានៅពេលបាត់មនុស្សពីក្រសួងច្រើន អៀង សារី និងគាត់បានជួបប្រជុំគ្នានៅមន្ទីរប-១ ។ បន្ទាប់មកគាត់ហៅកម្មាភិបាលក្រសួងការបរទេសនៅប្រាំងចំរេះដែលមកពីភូមិភាគឧត្តរមកប្រជុំធ្វើជីវទស្សនបដិវត្តន៍ ឬប្រជុំអប់រំសតិអារម្មណ៍កុំឲ្យមានការភិតភ័យ និងប្រាប់ឲ្យខំប្រឹងធ្វើការងារថែមទៀត ។ ប្រសិនបើបុគ្គលិកណាជាប់ពាក់ព័ន្ធជាមួយ កុយ ធួន នោះត្រូវឡើងនិយាយឲ្យសមូហភាពស្តាប់រួចហើយទើបគាត់យកទៅរាយការណ៍ឲ្យ អៀង សារី ។ ក្រៅពីប្រជុំ កម្មាភិបាលនៅប្រាំងចំរេះត្រូវសិក្សាពីសីលធម៌១២ប្រការថែមទៀត ។

នៅផ្នែកដែល សាឡុត បាន គ្រប់គ្រងមិនមានកំណត់ហេតុកិច្ចប្រជុំទេ ព្រោះបុគ្គលិកមិនសូវចេះអក្សរ លើកលែងតែកិច្ចប្រជុំផ្នែកបច្ចេកទេសជាមួយបញ្ញវន្តទាក់ទងជាមួយបរទេសទើបមាន ។ ចំណែកការប្រជុំក៏ធ្វើឡើងដាច់ដោយឡែកពីគ្នារវាងបញ្ញវន្ត និងកសិករដែរ ។ បាន បញ្ជាក់ថា គាត់មិនមានសិទ្ធិចាប់ខ្លួនទេ ព្រោះគាត់មិនមែនជាអ្នកបច្ចេកទេសស៊ើបគឺគាត់គ្រាន់តែជាអ្នកធ្វើការលើសតិអារម្មណ៍ដល់បងប្អូនឲ្យឃើញខ្លាំងប៉ុណ្ណោះ ។

## សក្ខីកម្ម សាឡុត បាន ថ្ងៃទីបី (ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២)

នៅសវនាការថ្ងៃទីបីនេះ សាឡុត បាន រៀបរាប់ឲ្យដឹងថា គាត់ធ្លាប់បានចូលរួមសមាជមហាសន្និបាតដោយមាន អៀង សារី ជាអធិបតី ។ សាឡុត បាន និយាយថារាល់ការធ្វើមហាសមាជសន្និបាតនេះមានការប្រព្រឹត្តទៅតាមសភាពការណ៍ដោយមានការកំណត់រយៈពេលប្រហែលមួយខែ ហើយពេលខ្លះប្រហែលជាមួយអាទិត្យ ពីព្រោះសភាពការណ៍មានការប្រែប្រួលជាលំដាប់ ។ បាន បញ្ជាក់ថាគាត់ទៅចូលរួមមហាសន្និបាតក្រសួងការបរទេសនៅចន្លោះពីខែមេសា ឆ្នាំ៧៥-៧៩ បានប្រហែលជាពីរដង ។

នៅខែកក្កដា ឆ្នាំ១៩៧៦ សាឡុត បាន បានដឹងអំពីមនុស្សយ៉ាងច្រើននៅក្នុងក្រសួងការបរទេស ប៉ុន្តែគាត់មិនបានចាំនៅថ្ងៃនោះទេ ។ សាឡុត បាន បានបញ្ជាក់ថាគាត់មិនដឹងអំពីមូលហេតុនៃការចាប់ខ្លួនមនុស្សនៅក្នុងក្រសួងការបរទេស ប៉ុន្តែគាត់បានស្តាប់សភាពការណ៍គឺវៀតណាមបានចូលមកដល់ភ្នំពេញ ។ តាមរយៈអ្នកកាន់ភ័ស្តុភារនៅតាមព្រំដែនដោយបានចូលមកគៀកដោយបានវាយប្រយុទ្ធយ៉ាងខ្លាំងនៅតាមព្រំដែន ។ ក្រោយមកសហព្រះរាជអាជ្ញាបានសួរថាតើលោកធ្លាប់បានដឹងអំពីអៀង សារី និយាយអំពីអ្វីខ្លះ? សាឡុត បាន ឆ្លើយតបថាគាត់មិនដឹងអំពីការនិយាយ

ផ្ទៃក្នុងនោះទេ ប៉ុន្តែគាត់បានត្រឹមតែដឹងពាក្យសម្តីអៀង សារី និយាយថា "ត្រូវប្រុងប្រយ័ត្នបដិវត្តន៍ឲ្យខ្ពស់ កុំឲ្យផ្ទៃក្នុងយើងនេះខូចចិត្តអំពីទស្សនៈស្នេហាជាតិ" បន្ទាប់មកទៀតថា សហព្រះរាជអាជ្ញាបានសួរទៀតថា នៅពេលប្រជុំជីវទស្សន៍ (ស៊័យទិតៀន) តើលោកមានការកត់ត្រាឯកសារទេ? សាឡុត បាន ឆ្លើយតបថា ឯកសារត្រូវបានកត់ត្រា ហើយនៅពេលខ្លះទៀតឯកសារមិនបានកត់ត្រានោះទេ ។ ប្រជុំធំៗផ្សេងនៅក្រសួងការបរទេសមានការកត់ត្រាផ្នែកណាដែលសំខាន់ៗប៉ុណ្ណោះ ។ សហព្រះរាជអាជ្ញាសួរទៀតថាតើលោកបានធ្លាប់ទៅទស្សនកិច្ចមូលដ្ឋាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? សាឡុត បាន ឆ្លើយថាការងាររបស់គាត់គឺមានពេលខ្លះជូនភ្ញៀវខ្លះៗ ភ្ញៀវតូចតាចដូចជាភ្ញៀវអ្នកកាសែតជាដើម ។ នៅក្នុងដំណើរទស្សនកិច្ចនៅប្រទេសកម្ពុជាបានពីរដងក្នុងមួយឆ្នាំរបស់ប្រតិភូបរទេស សាឡុត បាន បានធ្លាប់ជូនដំណើរគណៈប្រតិភូដែលមានអ្នកកាសែតអាមេរិក ជប៉ុន ឡាវ និង ប៊ែលហ្សិកទៀតផង ។

ពេលជូនគណៈប្រតិភូបរទេសចុះទៅទស្សនកិច្ចនៅមូលដ្ឋាន សាឡុត បាន ឃើញប្រជាជននៅទីនោះមានអត់ឃ្លាន ហើយក៏បានរាយការណ៍ជូនទៅ អៀង សារី ក្រោយមក អៀង សារី បន្តរាយការណ៍ជូនទៅថ្នាក់មជ្ឈិម ។ បន្តមក សាឡុត បាន រៀបរាប់ថា ខៀវ សំផន និង ប៉ង់អ្នកធ្វើការនៅមន្ទីរ៨៧០ ។

ទីតាំងមួយដែលឈ្មោះថា ឃុំពាម ដែលស្ថិតនៅខេត្តកណ្តាល សាឡុត បាន បានឃើញ ខៀវ សំផន នៅទីនោះដែរ ។ នៅក្នុងការប្រជុំនោះ គាត់បានឃើញ ខៀវ សំផន ជួយធ្វើបញ្ជីគ្រាប់រំសេវ ។ ក្រៅពីនេះ គាត់បានឃើញ នួន ជា ជួបជាមួយនិង ប៉ុល ពត នៅក្នុងខ្ទមនោះ ។ សហព្រះរាជអាជ្ញាបន្តថាតើនៅក្នុងខ្ទមនោះមានសមាជិកប៉ុន្មាននាក់? ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញា សាឡុត បានបញ្ជាក់ថា នៅក្នុងខ្ទមនោះមានរូបគាត់រស់នៅជាប្រចាំ រួមមានអ្នកដាំបាយម្នាក់ អ្នកការពារពីរនាក់តែប៉ុណ្ណោះ ។ ចំណែកចៀម មានតួនាទីធ្វើជានិរសាររបស់មន្ទីរ៨៧០ ដោយនៅក្នុងនោះចៀម ជាអ្នករកត្រីដើម្បីផ្គត់ផ្គង់អ្នកដែលរស់នៅក្នុងខ្ទមនោះ ។

លើសពីនេះទៅទៀត សាឡុត បាន ឲ្យដឹងថាសារៈសំខាន់ដែលរស់នៅក្នុងខ្ទមនោះជាប្រចាំដោយសារតែនៅក្នុងខ្ទមនោះមានកប់គ្រាប់សម្រាប់ប្រយុទ្ធ និងខ្មាំង ។ សាឡុត បាន ក៏បានរំឭកដល់ការធ្វើទស្សនកិច្ចទៅកាន់សហរដ្ឋអាមេរិកជាមួយ អៀង សារី ដើម្បីប្រជុំសមាជនៅអង្គការសហប្រជាជាតិនិងបន្តដំណើរទៅជួបអ្នកបញ្ញវន្តខ្មែររស់នៅទីក្រុងប៉ារីសទៀត ។ ចំណែកពេលទៅក្រុងប៉ារីស សាឡុត បាន បានបញ្ជាក់ថាគាត់គ្រាន់តែជាអ្នកមើលវ៉ាលីសឲ្យអៀង សារី តែប៉ុណ្ណោះ ។ ពេលមកដល់ក្រុងភ្នំពេញ គាត់បញ្ជាក់ថាគឺ ប៉ង់ ជាអ្នកទទួលខុសត្រូវនៅក្នុងការដឹកនាំបញ្ញវន្តដែលត្រឡប់មកពីបរទេស ។ ចំពោះខាងសម្ភាររបស់ពួកបញ្ញវ័ន្តទាំងនោះ ត្រូវបានប្រមូលយកមកទុកនៅក្នុងក្រសួងការបរទេសទាំងអស់ ។ សាឡុត បាន បញ្ជាក់ថា ចំពោះនិស្សិតបញ្ញវន្តដែលត្រឡប់មកវិញ ត្រូវបានយកទៅដាក់នៅបឹងត្របែកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ហេង អ៊ុន ។ ចំពោះនិស្សិតបញ្ញវន្តដែលដឹកមកបឹងត្របែកមិនបានឆ្លងកាត់នៅក្រសួងការបរទេសទេ ។ សាឡុត បាន អះអាងថា នៅពេលដែលគាត់បានទៅជាមួយ អៀង សារី ចូលបឹងត្របែកប្រហែលជាកន្លះខែមុនវៀតណាមចូលស្រុកដើម្បីផ្តល់ដំណឹងឲ្យជម្លៀសបញ្ញវន្តចេញពីទីនោះ ។

**វ៉ែន សុខស្រីនិត, ស៊ិន សុធីតា**

**និង សោម ប៊ុនថន**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: truthsocheat@dccam.org*
*Home page: www.dccam.org*

# សក្ខីកម្ម នី កន : ប្អូនប្រុសបង្កើតរបស់ សុន សេន

ចាប់ពីថ្ងៃទី២៨ដល់ថ្ងៃ៣០ ខែឧសភា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានកោះហៅសាក្សីឈ្មោះ នី កន ដែលត្រូវជាប្អូនប្រុសរបស់ សុន សេន ឲ្យមកឆ្លើយបំភ្លឺក្នុងនាមជាសាក្សីម្នាក់របស់ដំណាក់កាលទី២ នៃសំណុំរឿង០០២ដែលមានជនជាប់ចោទ នួន ជា, អៀង សារី និងខៀវ សំផន ។

## ប្រវត្តិរូប និងប្រវត្តិការងារសង្ខេប

នី កន មានអាយុ៦៩ឆ្នាំ រស់នៅស្រុកសំពៅលូន ខេត្តបាត់ដំបង ។ សព្វថ្ងៃគាត់ប្រកបមុខរបរជាទីប្រឹក្សារបស់ក្រសួងការពារជាតិ ។ គាត់មានបងប្រុសចំនួនពីរនាក់គឺ សុន សេន និង សុន ឈុំ ។ គាត់បាននិយាយថាបងប្រុសឈ្មោះ សុន ឈុំ មានតួនាទីជាអគ្គរដ្ឋទូតប្រចាំប្រទេសកូរ៉េខាងជើង និងបងប្រុសឈ្មោះ សុន សេន មានតួនាទីដឹកនាំកម្លាំងទ័ពក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នី កន បានបញ្ចប់ការសិក្សាពីវិទ្យាល័យស៊ីសុវត្ថិ នៅទីក្រុងភ្នំពេញ កាលពីឆ្នាំ១៩៦៥ ។ ក្រោយពីបញ្ចប់ការសិក្សា គាត់បានក្លាយជាគ្រូបង្រៀននៅសាលាបឋមសិក្សាមួយនៅខេត្តសៀមរាប ។



នី កន នៅក្នុងបន្ទប់សវនាការ

ក្រោយពីរដ្ឋប្រហារផ្តួលរំលំសម្តេច សីហនុ ដឹកនាំដោយ លន់ នល់ កាលពីឆ្នាំ១៩៧០ នី កន បានសម្រេចចិត្តចូលបម្រើបដិវត្តន៍កុម្មុយនីស្តខ្មែរក្រហម ។ សុន សេន គឺជាអ្នកមានឥទ្ធិពលលើសេចក្តីសម្រេចចិត្តនេះ ។ នី កន ត្រូវបានបញ្ចុះបញ្ចូលថា «ចលនាបដិវត្តន៍នេះគឺធ្វើឡើងដើម្បីកម្ចាត់ខ្មាំងការពារបូរណភាពដែនដីរបស់ប្រទេសកម្ពុជានិងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន» ។ គាត់មានមោទកភាព និងកិត្តិយសជាខ្លាំងដែលបានចូលបម្រើជាតិ ។ គាត់បានក្លាយជាសមាជិករបស់ក្រុមឃោសនា និងក្រុមចលនាមហាជន ។កិច្ចការចម្បងរបស់ក្រុមទាំងពីរនេះគឺបង្កើតកម្លាំងមួយដើម្បីឃោសនាប្រមូលសម្លេងគាំទ្រពីប្រជាជនទូទៅ ។ បន្ថែមលើនេះ ក្នុងអំឡុងបម្រើការងារជាគ្រូបង្រៀននៅខេត្តសៀមរាប នី កន បានផ្លាស់ប្តូរទៅបង្កើតចលនាមួយទៀតនៅតំបន់១៥ ដើម្បីបំផុសបំផុលប្រជាជនឲ្យ «វាយកម្ចាត់ពួកចក្រពត្តិអាមេរិក ។

នី កន បានបំរើឲ្យបដិវត្តន៍កុម្មុយនីស្តខ្មែរក្រហមចាប់តាំងពីឆ្នាំ១៩៧០រហូតដល់ឆ្នាំ១៩៧៤ ទើបបានក្លាយជាសមាជិកពេញសិទ្ធិរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ក្រោយពីបានចូលជាសមាជិកពេញសិទ្ធិ គាត់បានទទួលវគ្គបណ្តុះបណ្តាលផ្នែកនយោបាយដើម្បីអប់រំប្រជាជនឲ្យចេះរស់នៅដោយ «ខ្លួនទីពឹងខ្លួន និងវាយប្រយុទ្ធតាមសមរភូមិប្រឆាំងខ្មាំង» ដែលដឹកនាំដោយសមមិត្ត សាំង ។ ក្រោយថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ នី កន ក៏បានទទួលបន្ទុកផ្នែកឃោសនាប្រចាំនៅទីក្រុងភ្នំពេញដោយសារតែគាត់ចេះសរសេរនិងចេះអាន ។

ប៉ុន្តែមួយរយៈក្រោយមក គាត់ក៏ត្រូវបានផ្លាស់ឲ្យទៅបម្រើការងារនៅក្រសួងការបរទេស ។ គាត់មិនបានដឹងពីមូលហេតុនៃការផ្លាស់ប្តូរតួនាទីរបស់គាត់ពីមុនមកឡើយ ប៉ុន្តែគាត់បាននិយាយថា “គ្រប់ព័ត៌មានទាំងអស់សុទ្ធតែត្រូវបានលាក់ការណ៍ជាសម្ងាត់ ។ អ្វីដែលថ្នាក់លើសម្រេចហើយ គ្មាននរណាម្នាក់ហ៊ានជំទាស់ទេ ។

## ការជម្លៀស សហករណ៍ រចនាសម្ព័ន្ធថ្នាក់តំបន់ និងការទំនាក់ទំនង

ទាក់ទងនឹងការជម្លៀស នី កន បាននិយាយថាក្រោយពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅខេត្តសៀមរាប ប្រជាជនត្រូវបានអនុញ្ញាតឲ្យជ្រើសរើសទីតាំងដែលខ្លួនចង់ទៅរស់នៅដោយសារតែបញ្ហាសុវត្ថិភាព ។ គាត់បានអះអាងថាការជម្លៀសគឺធ្វើឡើងជាលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ ។ កាលណាស្ថានភាពប្រសើរឡើងវិញ ប្រជាជនត្រូវបានបញ្ជូនឲ្យមករស់នៅតាមផ្ទះសម្បែងរបស់ខ្លួនដូចសព្វមួយដងវិញ ។ គាត់បានបន្ថែមទៀតថា របបអាហារមានបរិមាណសមល្មម ប៉ុន្តែដោយសារតែចំនួនប្រជាជនដែលត្រូវបានជម្លៀសមានចំនួនច្រើនរបបអាហារមានចំនួនខ្វះខាតតិចតួចដែរ ។ នៅក្នុងអំឡុងពេលជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ នី កន មានតួនាទីសរសេរបដាប្រាប់ប្រជាជនឲ្យភៀសខ្លួនចេញពីទីក្រុងភ្នំពេញដោយសារការទម្លាក់គ្រាប់បែកដោយគោរពតាមបញ្ជារបស់ថ្នាក់លើ ។ កាលណោះ គាត់បានជឿថា ការជម្លៀសប្រជាជនក្រុងទាំងអស់នេះមានលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ ហើយគាត់ក៏បានជឿថាប្រជាជននឹងអនុញ្ញាតឲ្យវិលត្រឡប់មករស់នៅដូចធម្មតាវិញនៅពេលដែលការទម្លាក់គ្រាប់បែកនោះបានបញ្ចប់ទៅ ។ នី កន បានបន្ថែមទៀតថា ក្នុងអំឡុងពេលនោះ គ្មានក្រុមប្រជាជនណាមួយត្រូវបានចាត់ទុកថាជាខ្មាំងទេ ។ ជាក់ស្តែងប្រជាជនទាំងអស់ត្រូវទទួលបានរបបអាហារគ្រប់គ្រាន់សម្រាប់ការជម្លៀសនោះ ប៉ុន្តែគាត់មិនបានដឹងថា តើគោលការណ៍នេះត្រូវបានអនុវត្តជាក់ស្តែងយ៉ាងណានោះទេ ។ នី កន បានសង្កត់ធ្ងន់ម្តងទៀតថា ការជម្លៀសនេះគឺធ្វើឡើងដើម្បីគេចវេះពីការទម្លាក់គ្រាប់បែករបស់ចក្រពត្តិអាមេរិកហើយថាប្រជាជនទាំងអស់ត្រូវបានអនុញ្ញាតឲ្យជ្រើសរើសទីកន្លែង ឬស្រុកកំណើតដែលខ្លួនចង់ទៅដោយគ្មានការបង្ខិតបង្ខំ ឬគាបសង្កត់អ្វីឡើយ ។

យោងតាមការអះអាងរបស់ នី កន ការបង្កើតសហករណ៍គឺដើម្បីធានាថាប្រជាជនរស់នៅដោយខ្លួនទីពឹងខ្លួនដោយមិនពឹងផ្អែកលើជំនួយបរទេសឡើយ ។ ក្នុងអំឡុងពេលនោះដែរ វត្តអារាមត្រូវបានបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុងដោយសារតែគ្រាប់ផ្លោង និងការទម្លាក់គ្រាប់បែករវាងកងទ័ព លន់ នល់ និងកងទ័ពបដិវត្តន៍របស់ខ្មែរក្រហម ។ អាស្រ័យហេតុនេះ នី កន បានអះអាងថា ព្រះសង្ឃដែលគង់នៅតាមវត្តអារាមទាំងអស់បានបង្ខំចិត្តសឹក ហើយចូលបំរើបដិវត្តន៍ ។ មូលហេតុនេះបានបណ្តាលឲ្យគ្មានការប្រតិបត្តិសាសនានៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នី កន បានបន្ថែមទៀតថា គាត់មិនបានដឹងថាមានការប្រកាសមិនឲ្យប្រតិបត្តិសាសនាជាលក្ខណៈផ្លូវការទេបើទោះបីជាតាមស្ថានភាពជាក់ស្តែងមានការហាមប្រាមក៏ដោយ ។

នី កន បានរៀបរាប់ពីរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់តំបន់នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ គាត់បានអះអាងថាភូមិភាគបស្ចិមមានតំបន់ចំនួនពីរគឺតំបន់៣១ និងតំបន់៣២ ។ តា ប៉ាល់ ជាអ្នកគ្រប់គ្រងតំបន់ ៣១ ហើយចំណែកឯតា សារ៉ុន ជាអ្នកគ្រប់គ្រងតំបន់៣២ ។ ក្នុងអំឡុងពេល នី កន ត្រូវបានផ្លាស់ទៅតំបន់ ១៥ គាត់បានចាំថា ចេង អន គឺជាអ្នកទទួលបន្ទុកផ្នែកយោធាប្រចាំតំបន់១៥ ។ បន្ថែមលើនេះ តា ប៉ាល់ គឺជាលេខាតំបន់៣២ដែលមាន ចេង អន នៅក្រោមបន្ទាប់ក្រោយពេលដែលតំបន់១៥ត្រូវបានបញ្ចូលក្នុងតំបន់៣២ ។ ចំណែកឯ តា ស៊ី (ជូរ ជេត) គឺជាលេខាភូមិភាគបស្ចិម ។ ក្រោយពេលដែលតា ប៉ាល់ ត្រូវបានផ្លាស់ចេញ តា រ៉ន បានក្លាយជាអ្នកគ្រប់គ្រងតំបន់៣២នេះ ។ នី កន បានអះអាងថា“តា សារ៉ន ត្រូវបានថ្នាក់លើបញ្ជូនឲ្យមកមើលការខុសត្រូវតំបន់” ។ តាមថ្នាក់តំបន់ការទំនាក់ទំនងគ្នាគឺធ្វើឡើងតាមរយៈទូរលេខដោយមាននិរសារជាអ្នកនាំទូរលេខនោះ ។

## បទសម្ភាសឆ្នាំ២០០៨ជាមួយអ្នកនិពន្ធ ហ៊ីលីព ហ្សត៍

គួររំឭកដែរថា កាលពីឆ្នាំ២០០៨ នី កន បានផ្តល់បទសម្ភាសឲ្យអ្នកនិពន្ធជនជាតិអង់គ្លេសឈ្មោះ ហ៊ីលីព ហ្សត៍ ។ នៅក្នុងបទសម្ភាសនោះ នី កន បាននិយាយថា គាត់បានបោះពុម្ពឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជាមុនរដ្ឋប្រហារឆ្នាំ១៩៧០ ។ នី កន បានអះអាងថាវាជាការពិតដែលថាគាត់បានទទួលបន្ទុកផ្នែកសរសេរឯកសារ ប៉ុន្តែជាក់ស្តែងកិច្ចការនេះគឺគ្រាន់តែបោះពុម្ព

ឯកសារតែប៉ុណ្ណោះ ។ គាត់បាននិយាយថា គាត់មិនដែលបានសរសេរអ្វីឡើយ ហើយថាការងារនេះត្រូវបានប្រគល់ឲ្យសមមិត្តណាដែលសរសេរអក្សរស្អាត ។ ឯកសារទាំងនេះគឺជាឯកសារដែល "ថ្នាក់លើ" បានបង្គាប់ឲ្យបោះពុម្ពដើម្បីផ្សព្វផ្សាយជូនប្រជាជនឲ្យបានជ្រាបច្បាស់ពីចលនាបដិវត្តន៍ និងដើម្បីលើកកម្ពស់ស្មារតីខ្លួនទីពឹងខ្លួនក្នុងចំណោមប្រជាជន ។ លើសពីនេះ យោងតាមបទសម្ភាសនោះបានឲ្យដឹងថា នី កន បានលាក់ខ្លួននៅតំបន់ដាច់ស្រយាលអស់មួយរយៈពេលក្នុងឆ្នាំ១៩៦៨ដោយសារតែភាពចលាចល ។ នី កន បានអះអាងថាការលាក់ខ្លួននេះគឺដើម្បីការពារសុវត្ថិភាពពីព្រោះគាត់គឺជាអ្នកចូលរួមក្នុងចលនាឃោសនារបស់បក្សកុម្មុយនីស្តកម្ពុជា ។ មុនរដ្ឋប្រហារយោធា លន់ នល់ តែងតែព្យាយាមរើករកមុខខ្សែបណ្តាយរបស់បក្សកុម្មុយនីស្ត ។ ដូច្នេះដើម្បីធានាសុវត្ថិភាពគាត់ត្រូវតែលាក់ខ្លួន ។

## គោលការណ៍ ក្បួនវិន័យ និងការប្រជុំជីវភាពរបស់បក្ស

ជាងនេះទៅទៀត ក្នុងបទសម្ភាសនេះ នី កន ក៏បានរៀបរាប់ពីតួនាទីបងប្រុសរបស់គាត់ក្នុងនាមជាអ្នកដឹកនាំកម្លាំងទ័ពរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ផ្ទុយទៅវិញ នាពេលនេះ គាត់បែរជានិយាយថាគាត់ មិនបានដឹងពីតួនាទីគ្រប់គ្រងរបស់ សុន សេន ឲ្យបានច្បាស់លាស់នោះទេ ។ ដោយឡែកទាក់ទងនឹងសម្ព័ន្ធយុវជនកុម្មុយនីស្តកម្ពុជា នី កន បានអះអាងថា សម្ព័ន្ធយុវជននេះមានគោលការណ៍ធំៗពីរគឺៈ ការពារប្រទេសកម្ពុជា និងកសាងប្រទេសជាតិ ។ គាត់បានបកស្រាយគោលការណ៍ធំៗ នេះផ្តោតទៅលើគោលការណ៍វាយកម្ទាត់ពួកចក្រពត្តិនិយម លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន និងការពារបូរណភាពដែនដី ។ ជាមួយគ្នានោះ ការមានប្រវត្តិរូបស្អាតស្អំគឺជាកត្តាសំខាន់បំផុតសម្រាប់សមាជិកបក្សនីមួយៗ ដោយគោរពតាមក្បួនវិន័យរបស់បក្សកុម្មុយនីស្តកម្ពុជាដូចតទៅៈ មិនលួចរបស់គេ មិនកេងប្រវ័ញ្ចអ្នកដទៃ និងមិនសេពគ្រឿងស្រវឹង ។ នី កន បាននិយាយថា នៅភូមិភាគបស្ចិមមានការប្រជុំជីវភាពថ្នាក់តំបន់ធ្វើឡើងរយៈពេលបីថ្ងៃដោយមានការចូលរួមពីកម្មាភិបាលថ្នាក់ភូមិឃុំរួមទាំងលេខាភូមិភាគដែរ ។ ជាពិសេស មានការចូលរួមយ៉ាងច្រើនពីសមាជិកជាន់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជារួមទាំង នួន ជា ។

## តួនាទីរបស់ នី កន និងរចនាសម្ព័ន្ធនៅក្រសួងការបរទេស

គួររំឮកដែរថា នី កន ត្រូវបានផ្លាស់មកភូមិភាគបស្ចិមមុននឹងត្រូវបានផ្ទេរមកក្រសួងការបរទេស ។ ក្នុងចំណោម សេត, កែវ និង ស៊ឹម គាត់បានស្គាល់ត្រឹមតែ កែវ តែប៉ុណ្ណោះ ពីព្រោះ កែវ ជាអ្នកមើលការខុសត្រូវខាងផ្នែករបបអាហារក្នុងតំបន់ ។ អ្វីដែលគួរឲ្យកត់សម្គាល់គឺថាខណៈពេលដែល នី កន ត្រូវបានផ្លាស់មកក្រសួងការបរទេស សេត, កែវ និង ស៊ឹម ត្រូវបានបញ្ជូនទៅមន្ទីរស-២១ ។ គាត់បានបន្ថែមទៀតថាក្រៅពីសមាជិកជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា អ្នកដែលមានសិទ្ធិក្នុងការផ្លាស់ប្តូរមនុស្សគឺគណៈភូមិភាគ ។ ជាក់ស្តែង គាត់បានអះអាងថាគណៈភូមិភាគគឺជាអ្នកផ្លាស់គាត់ចេញពីភូមិភាគបស្ចិមទៅក្រសួងការបរទេស ។

យោងតាមបទសម្ភាសរវាង ស៊ីវ ហេង ជាមួយនឹង អៀង សារី ការផ្លាស់ នី កន មកបម្រើការងារនៅក្រសួងការបរទេសគឺដោយសារតែ នី កន នេះត្រូវបានចោទប្រកាន់ថាមានជាប់ពាក់ព័ន្ធនឹងពួកសេ.អ៊ី.អា ។ ប៉ុន្តែ នី កន បានអះអាងថាមូលហេតុដែលគាត់ត្រូវបានបញ្ជូនមកក្រសួងការបរទេសគឺដោយសារតែគាត់ចេះសរសេរ និងចេះអានអក្សរ ។ នៅក្រសួងការបរទេស នី កន មានតួនាទីជាអ្នកពិធីការឲ្យផ្នែកពិធីការអមដំណើរទស្សនកិច្ចរបស់ភ្ញៀវបរទេសទៅកាន់ប្រាសាទអង្គរវត្តជាដើម ។ ក្រៅពីនេះ គាត់បានបង្រៀនភាសាអង់គ្លេសដល់ក្មេងៗនៅក្រសួងការបរទេសអស់មួយរយៈពេលខ្លីដែរ ។

ទាក់ទងនឹងរចនាសម្ព័ន្ធនៅក្រសួងការបរទេស នី កន បាននិយាយថាប្រធានផ្នែកពិធីការរបស់ក្រសួងការបរទេសគឺជា ចៀម ។ កិច្ចការចម្បងរបស់ ចៀម គឺចាត់តាំងការងារឲ្យអ្នកនៅក្រោមបង្គាប់របស់ខ្លួន និងផ្តល់របបអាហារដល់បុគ្គលិកក្នុងអង្គភាព ។ បន្ថែមលើនេះ នី កន បានស្គាល់ ជួន ប្រាសិទ្ធិ ដែលជាអ្នកបកប្រែឲ្យក្រសួងការបរទេស ប៉ុន្តែគាត់មានវត្តមានតែនៅក្នុងកម្មវិធីពិសេសៗតែប៉ុណ្ណោះ ។ នី កន ក៏បានស្គាល់ ឡុង នរិន្ទ ហៅ រិទ្ធិ ដែរប៉ុន្តែមិនបានដឹងពីតួនាទីរបស់ ឡុង នរិន្ទ នៅក្រសួងការបរទេសទេ ។ នី កន បានរៀបរាប់បន្ថែមទៀតថា នៅផ្នែកពិធីការរបស់ក្រសួងការបរទេសត្រូវបានបែងចែកជាផ្នែកហើយផ្នែកដែលសំខាន់ជាងគេគឺផ្នែកបដិសណ្ឋារកិច្ចស្វាគមន៍ភ្ញៀវបរទេស ។ អ្នកដែល

មានតួនាទីគ្រប់គ្រងផ្នែកនេះគឺជាអ្នកមានចំណេះដឹងទូទៅពីបរទេស និងមានចំណេះដឹងផ្នែកភាសាបរទេសជ្រៅជ្រះ ។ នេះសបញ្ជាក់ឲ្យឃើញថា គាត់មិនមែនជាអ្នកគ្រប់គ្រងផ្នែកពិធីការនេះទេ ។ គាត់ក៏បានបញ្ជាក់ថា អៀង សារី បានអញ្ជើញទៅទទួលភ្ញៀវបរទេសញឹកញាប់ដែរ ។ ដោយឡែក នី កន បានអមដំណើរគណៈប្រតិភូប៉ែលហ្សិកចំនួនបីនាក់ទៅកាន់ខេត្តសៀមរាបដើម្បីទស្សនាប្រាសាទអង្គរវត្ត ។ លើសពីនេះ គាត់ក៏បានដឹកនាំគណៈប្រតិភូជប៉ុនធ្វើដំណើរទស្សនកិច្ចទៅកាន់ខេត្តសៀមរាបដែរ ។

គួរឲ្យកត់សម្គាល់ដែរថា ក្នុងករណីដែល អៀង សារី រដ្ឋមន្ត្រីក្រសួងការបរទេសមិនមានវត្តមាននៅក្រសួង ហុង (សាឡុត បាន) ឬ ចៀម មានសិទ្ធិបំពេញកិច្ចការមួយចំនួនជំនួស អៀង សារី បើយោងតាមការអះអាងរបស់ នី កន ។ គាត់បានបញ្ជាក់ថាក្នុងអំឡុងពេលបម្រើការងារនៅក្រសួងការបរទេស គាត់មិនដែលបានជួប ខៀវ សំផន ទេ ។ លើសពីនេះ ទាក់ទងនឹងការងារផ្ទាល់របស់ នី កន ក្រោយពេលអមដំណើរទស្សនកិច្ចជាមួយនឹងគណៈប្រតិភូបរទេស គាត់ត្រូវតែរាយការណ៍ជូន ចៀម ។ គាត់ក៏បានបញ្ជាក់បន្ថែមទៀតថា បើទោះបីជា សុន សេន ដែលជាបងប្រុសបង្កើតរបស់គាត់គឺជាសមាជិកជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាក៏ដោយ ក៏ នី កន មិនដែលបានចូលរួមប្រជុំឬជួបពិភាក្សាជាមួយនឹងថ្នាក់ដឹកនាំជាន់ខ្ពស់ដូចជា អៀង សារី ឬ នួន ជា ឡើយ ។ គោលការណ៍សម្ងាត់របស់ខ្មែរក្រហមគឺមានឥទ្ធិពលខ្លាំងបំផុតសូម្បីតែក្នុងគ្រួសារក៏ដោយ ។

ដូចដែលបានគូសបញ្ជាក់ខាងដើម នី កន គឺជាប្អូនប្រុសបង្កើតរបស់ សុន សេន ។ ប៉ុន្តែ តាមរយៈការផ្តល់សក្ខីកម្មរយៈពេលបីថ្ងៃកន្លងមកនេះ នី កន ស្ទើរតែមិនបានផ្តល់ព័ត៌មានអ្វីទាល់តែសោះពាក់ព័ន្ធនឹងកិច្ចការ និងតួនាទីរបស់ សុន សេន ក៏ដូចជាមេដឹកនាំជាន់ខ្ពស់ដទៃទៀតរួមមាន នួន ជា ឬ អៀង សារី ជាដើម ។ អ្វីដែល នី កន បានបកស្រាយកន្លងមកនេះគឺគ្រាន់តែជាបទពិសោធការងារ និងការអង្កេតផ្ទាល់ខ្លួនរស់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ ។ **វ៉ែន សុខស្រីនិត**



អៀង សារី និង ខៀវ សំផន នាំគណៈប្រតិភូបរទេសទស្សនាអាងចិញ្ចឹមក្រពើក្នុងខេត្តសៀមរាប

# ខ្ញុំមិនជឿនូវអ្វីដែលមេដឹកនាំខ្មែរក្រហមនិយាយក្នុងសវនាការទេ


វ៉េះ ហឿន

«ខ្ញុំមិនដែលនឹកដល់ថាតុលាការហៅ ឌុច មកធ្វើជាសាក្សីនោះទេ» វ៉េះ ហឿន ជនជាតិចាមម៉ូស្លីម បានថ្លែងដូចនេះ ពេលដែលបានចូលរួមស្តាប់និងមើលការផ្សាយបន្តផ្ទាល់ដំណើរការសវនាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលរៀបចំដោយក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងបរិវេណវិហារឥស្លាមមួយកន្លែងស្ថិតនៅបណ្តោយផ្លូវគីឡូម៉ែត្រលេខ៩ សង្កាត់ច្រាំងចំរេះ ។ វ៉េះ ហឿន និយាយថា ឌុច ចូលមកធ្វើជាសាក្សីនៅពេលនេះគួរតែនិយាយនូវការពិតគ្រប់យ៉ាង មិនមែនមានរឿងដប់ ប្រាប់តែពីរលាក់ប្រាំបីនោះទេ ។ ឌុច ត្រូវតែឆ្លើយឲ្យត្រង់ឲ្យសមទៅនឹងទង្វើដែលធ្លាប់បានធ្វើចំពោះប្រជាជន កុំឲ្យឆ្លើយពន្យារ ឬលាក់បាំង ព្រោះប្រជាជនទូទាំងប្រទេសដឹងអស់ហើយ ចំពោះការធ្វើបាប និងការកាប់សម្លាប់មកលើប្រជាជនកម្ពុជានៅពេលនោះ អ្នកដែលធ្លាប់ឆ្លងកាត់ដឹងរឿងហ្នឹងអស់ហើយ ជាក់ស្តែងមានរូប ហឿន ផ្ទាល់ដែលបានមានជីវិតរស់មកដល់សព្វថ្ងៃជាសាក្សីរស់ ។

ហឿន តែងតែស្រក់ទឹកភ្នែកនៅពេលដែលនឹកឃើញដល់សម័យខ្មែរក្រហម បងប្អូន និងសមាជិកគ្រួសាររបស់គាត់ជាងហាសិបនាក់ត្រូវបានខ្មែរក្រហមសម្លាប់ និងស្លាប់ដោយសារជំងឺ ។ រាល់ថ្ងៃនេះ ហឿន តែងតែតាមដាននូវដំណើរការសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមព្រោះ ហឿន ចង់ដឹងថាមេដឹកនាំទាំងនោះឆ្លើយយ៉ាងណាចំពោះមុខសវនាការពីការស្លាប់របស់ប្រជាជនខ្មែររាប់លាននាក់ ។ តើមេដឹកនាំទាំងនោះបន្ទោសទៅលើនរណាទៀត? បើនៅសម័យនោះអ្នកដែលមានសិទ្ធិអំណាចធំជាងគេគឺជាក្រុមរបស់ខ្លួនហើយនោះ? ការលើកឡើងភាគច្រើនរបស់មេដឹកនាំទាំងនោះគឺផ្ទុយស្រឡះពីការពិតដែល ហឿន បានជួបប្រទះនៅពេលនោះ ជាក់ស្តែង នៅថ្ងៃ១៧ មេសា ឆ្នាំ ១៩៧៥ នៅភូមិរបស់ ហឿន រស់នៅ យោធាខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីផ្ទះដោយប្រាប់ចេញតែពីរបីថ្ងៃទេ ហើយអ្នកណាធ្លាប់ធ្វើការងារជាអ្វីត្រូវស្លៀកឯកសណ្ឋាននោះទៅជាមួយផង ។ ប្រជាជនមួយចំនួនបានធ្វើតាមនូវអ្វីដែលយោធាខ្មែរក្រហមប្រាប់ អ្នកខ្លះពាក់ឯកសណ្ឋានជាពេទ្យ សិស្ស ទាហាន ហើយធ្វើដំណើរចេញទៅ ។ ប៉ុន្មានថ្ងៃក្រោយមកទើបដឹងថា អ្នកទាំងនោះត្រូវបានខ្មែរក្រហមនាំទៅសម្លាប់តាំងពីថ្ងៃជម្លៀសដំបូងមកម្ល៉េះ ។ ហឿន បញ្ជាក់ថាខុសពីអ្វីដែល នួន ជា ធ្លាប់បាននិយាយនៅក្នុងសវនាការថាការជម្លៀសប្រជាជនចេញពីផ្ទះគឺដោយសារខ្លាចអាមេរិកកាំងមកទម្លាក់គ្រាប់បែកឬដោយសារខ្វះមធ្យោបាយដឹកជញ្ជូនស្បៀងមកឲ្យប្រជាជន ។ ហឿន បន្តថា ការជម្លៀសនេះ មិនមែនការពារសុវត្ថិភាពឬបារម្ភពីភាពខ្វះខាតរបស់ប្រជាជននោះទេ គឺជាការនាំប្រជាជនទៅសម្លាប់ទៅវិញទេ ដោយវិធីត្រជាក់បំផុតដោយឲ្យប្រជាជនធ្វើការហួសកម្លាំង ហូបមិនគ្រប់គ្រាន់ និងឲ្យទៅរស់នៅតំបន់ចាញ់ខ្លាំង ភ្នំដាច់ស្រយាល ។ អំឡុងពេល ជម្លៀសនោះ កូនទីពីរអាយុ៣ឆ្នាំរបស់ ហឿន បានស្លាប់ដោយសារលាប់កញ្ច្រិល ទោះបីជា ហឿន ខំប្រមូលរបស់របរទៅដូរថ្នាំពេទ្យពីអ្នកមូលដ្ឋានមកឲ្យកូនលេបក៏មិនបានជួយសង្គ្រោះជីវិតបានដែរ ។ ក្នុងរយៈពេលមិនដល់មួយឆ្នាំផង ហឿន ត្រូវបានបាត់បង់កូនពីរនាក់ម្នាក់ទៀតស្លាប់ ដោយសាររាគមួល ព្រោះនៅពេលនោះមានតែមន្ទីរពេទ្យទេ

តែគ្មានថ្នាំព្យាបាលអ្វីទេ។ ហឿន និយាយថា ដូចអ្វីដែល ឌុច និយាយក្នុងសវនាការអ៊ីចឹង គឺមានតែថ្នាំអាចម៍ទន្សាយ និងទឹកដូងដែលប្រើជំនួសស៊ីរ៉ូមប៉ុណ្ណោះ។

ទាក់ទងទៅនឹងដំណើរសវនាការកន្លងទៅដែលមានទណ្ឌិត ឌុច ជាសាក្សី ហឿន យល់ថា ការលើកឡើងរបស់ ឌុច មួយចំនួននៅក្នុងសវនាការមានចំណុចត្រូវនិងខុសខ្លះដែរ ដូចជា ឌុច បានលើកឡើងពីគោលការណ៍របស់បក្សថា ប្រជាជនដែលធ្វើការនៅសហករណ៍នឹងទទួលបានរបបអង្ករម្នាក់ពីរកំប៉ុងក្នុងមួយថ្ងៃ។ នៅត្រង់ចំនុចនេះ វ៉េះ ហឿន មានអារម្មណ៍ខឹងនឹងអ្វីដែល ឌុច លើកឡើងនិងបាននិយាយថា ឌុច និយាយកុហក ប្រសិនបើក្នុងមួយថ្ងៃ ប្រជាជនទទួលរបបអង្ករពីរកំប៉ុងមែននោះ មិនមានមនុស្សស្លាប់រាប់ម៉ឺននាក់ដោយសារហូបមិនគ្រប់គ្រាន់នោះទេ។ ពេលនោះនៅកងរបស់ ហឿន មានគ្នាចំនួនសែសិបនាក់ហើយក្នុងមួយថ្ងៃ អង្គការចែកតែអង្ករដប់កំប៉ុងប៉ុណ្ណោះ នៅពេលក្រោយៗមកទៀត អង្គការកាត់មកត្រឹមប្រាំមួយកំប៉ុង បន្ទាប់មកបួនកំប៉ុងនិងចុងក្រោយបង្អស់នៅសល់តែពីរកំប៉ុងប៉ុណ្ណោះ។ នៅពេលនោះ បើយើងគ្មានអ្វីដោះដូរដើម្បីហូបទេ ប្រាកដជាស្លាប់មិនខាន។ អ្វីដែលធ្វើឲ្យ ហឿន រំជួលចិត្តបំផុតនោះគឺពេលដែល ឌុច និយាយពីការពង្រាយប្រជាជនខ្មែរ-ឥស្លាមទៅតាមសហករណ៍នីមួយៗដោយរស់នៅជាមួយប្រជាជនមូលដ្ឋានខ្មែរក្នុងគោលបំណងបំបាត់អត្តសញ្ញាណរបស់ជនជាតិខ្មែរ-ឥស្លាម។ ហឿន នៅចាំថានៅភូមិដែលគាត់រស់នៅ កម្មាភិបាលខ្មែរក្រហមធ្វើបាបប្រជាជនខ្មែរ-ឥស្លាមខ្លាំងណាស់។ នៅពេលទៅបើកបបរ បើប្រជាជនខ្មែរធម្មតា ខ្មែរក្រហមដួសឲ្យពីរវែក តែបើប្រជាជនឥស្លាមវិញគឺដួសឲ្យតែមួយវែកប៉ុណ្ណោះ។ លើសពីនេះទៀត ហឿន ធ្លាប់បានខ្មែរក្រហមបង្អត់អាហាររយៈពេលបីថ្ងៃដោយសារតែមិនព្រមហូបសាច់ជ្រូកតាមបញ្ជានិងបានបញ្ជូនឲ្យទៅធ្វើការកន្លែងដែលចាញ់បំផុតជាមួយបងប្អូនខ្មែរ-ឥស្លាមដទៃទៀតនៅក្នុងព្រៃនាមឆ្ងាយៗ។ ហឿន បន្តទៀតថា មានថ្ងៃមួយគាត់និងប្តីទៅធ្វើការនៅសហករណ៍ឈ្លបភូមិបានទៅឆែកឆេរខ្ទមរបស់គាត់ ហើយបានឃើញរូបថតប្តីរបស់គាត់ដែលពាក់ឯកសណ្ឋានជាយុវ័នដោយនៅលើស្មាមានសញ្ញាដូចសក្តិនិងបានយករូបថតនោះទៅជាមួយ។ ពេលត្រលប់មកវិញ មិនឃើញរូបថត ហឿន និងប្តីក៏មិនបានមាត់ក ឬសួររកអ្វីដែរ បន្តិចក្រោយមក ម៉ោងប្រហែលប្រាំពីរយប់ មានកងឈ្លបមកហៅប្តី ពេលនោះ ហឿន សួរថា យកប្តីខ្ញុំទៅណា? កងឈ្លបឆ្លើយថា យកទៅប្រជុំ ប៉ុន្តែពេលដែល ហឿន ក្រឡេកមើលទៅខាងក្រោយខ្នងឈ្លប គាត់ឃើញមនុស្ស



វ៉េះ ហឿន កំពុងអានទស្សនាវដ្តីស្វែងរកការពិត

ជាប់ចំណងមួយជួរ ។ កងឈ្លបទាំងនោះបាននាំចាប់ប្តី ហឿន ចង បណ្តើរទៅជាមួយមនុស្សផ្សេងៗយកទៅសម្លាប់នៅភូមិបាក់រទេះ ។

នៅខែមីនា ឆ្នាំ១៩៧៧ ប្តីរបស់ ហឿន ត្រូវខ្មែរក្រហម ដុតសម្លាប់ទាំងរស់ដោយចងព្យួរឡើងលើ និងដុតភ្លើងពីក្រោម មូលហេតុដោយខ្មែរក្រហមចោទថា ប្តីរបស់គាត់ចេះរបៀន ព្រោះ បាញ់ និងវាយមិនស្លាប់ ។ ហឿន បានដឹងរឿងនេះតាមរយៈអ្នក ដែលខ្មែរក្រហមចាប់ទៅជាមួយប្តីគាត់ ហើយបានរត់រួចមកវិញ ។ រឿង ដែលនឹកស្មានមិនដល់មួយទៀត ប្អូនប្រុសបន្ទាប់របស់ ហឿន ត្រូវខ្មែរក្រហមយកទៅសម្លាប់ ។ ស្រក់ទឹកភ្នែកពេលនឹកដល់ប្អូន ហឿន បានរៀបរាប់ថា ខ្មែរក្រហមបានយកប្អូនប្រុសទៅសម្លាប់ ដោយវាយនឹងក្បាលរទេះ តែមិនស្លាប់ ក៏យកទៅដំពងបន្ថែមទៀត រហូតដល់ស្លាប់យ៉ាងវេទនាជាទីបំផុត ។

ក្រោយពីប្តីរបស់ ហឿន ស្លាប់បានមួយរយៈ ហឿន ត្រូវ បានអង្គការចាប់បង្ខំឲ្យរៀបការជាមួយប្រជាជនមូលដ្ឋានដែលមាន អាយុជិត៦០ឆ្នាំទៅហើយ ។ ហឿន បានបដិសេធនឹងការចាត់តាំង នេះហើយត្រូវបានអង្គការចាប់ចង និងត្រាំក្នុងទឹកមួយយប់ទល់ ភ្លឺ ។ គូស្វាមីដែលទើបរៀបការហើយ នៅពេលយប់គឺមានឈ្លប នៅចាំស្តាប់ក្រោមផ្ទះថាមានអ្នកណាខ្លះមិនរួមដំណេក ។ ហឿន និយាយថា ការលើកឡើងរបស់មេដឹកនាំខ្មែរក្រហមដែលបាន ថ្លែងនៅក្នុងសវនាការថាអង្គការគ្មានពេលឯណាទៅស្តាប់ថានរណា រួមដំណេកឬអត់នោះគឺជាការកុហកមួយដែលប្រាសចាកពីការពិត នៅសម័យនោះ ។ នេះគឺជាការកុហកតុលាការ ជាពិសេសកុហក ប្រជាជនកម្ពុជាដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ។ នារីៗជាច្រើន ត្រូវបានសម្លាប់ និងរំលោភដោយសារតែមិនព្រមរៀបការតាម ការចាត់តាំងរបស់អង្គការ ។

សព្វថ្ងៃនេះ រ៉េះ ហឿន រស់នៅតែពីរនាក់ម្តាយជរា អាយុ ៨៨ឆ្នាំ នៅភូមិ៣ សង្កាត់ប្រាំងចំរេះ១ រាជធានីភ្នំពេញ ។ ហឿន និយាយថាមរតកដែលខ្មែរក្រហមបន្សល់ទុកឲ្យគាត់មកដល់បច្ចុប្បន្ន នេះគឺភាពឈឺចាប់ដែលមិនអាចបំភ្លេចបានចំពោះការបាត់បង់បង ប្អូនញាតិមិត្តជាទីស្រលាញ់ ។ ហេតុនេះ ហឿន សំណូមពរឲ្យ តុលាការកាត់ទោសមេដឹកនាំទាំងនោះឲ្យសមទៅនឹងការឈឺចាប់ របស់ប្រជាជនកម្ពុជា ដែលត្រូវបានសម្លាប់ដោយគ្មានត្រាប្រណី និងសូមឲ្យតុលាការកាត់ទោសឲ្យឃើញស ឃើញខ្មៅ ហើយសាក្សី ដែលមកផ្តល់សក្ខីកម្មសូមឆ្លើយឲ្យត្រង់ទៅកាន់តុលាការ ដើម្បី យុត្តិធម៌ ។

**ឆាយ សារៈមុនិន្ទ**



ចាមមូស្លីមកំពុងមើលឯកសារមុននឹងការផ្សាយបន្តផ្ទាល់ការធ្វើសក្ខីកម្មរបស់ ឌុច

# នួន ជា ត្រូវតែទទួលស្គាល់ការពិត

*កម្ពុជាប្រជាធិបតេយ្យជារបបដែលគួរឲ្យខ្មាសអៀនបំផុតចំពោះសកលលោក ព្រោះជារបបមួយដែលសម្លាប់ជាតិសាសន៍ខ្លួនឯងយ៉ាងព្រៃផ្សៃបំផុត*

នៅពេលសម្រាកបន្ទាប់ពីការចូលរួមស្តាប់ការធ្វើបទបង្ហាញស្តីពីការវិវឌ្ឍន៍របស់តុលាការខ្មែរក្រហមរបស់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានរៀបចំឡើងនៅសាលប្រជុំមួយដែលស្ថិតនៅសកលវិទ្យាល័យការពារជាតិ ។ មន្ត្រីយោធាម្នាក់បានណែនាំខ្លួនថាឈ្មោះ ម៉ី សារុន ដើរសំដៅមកកាន់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាដោយបានសម្តែងនូវសេចក្តីស្វាគមន៍ចំពោះវត្តមានរបស់បុគ្គលិកមជ្ឈមណ្ឌលនិងបានថ្លែងថា



លោក លី សុខឃាង (អាវស) សំណេះសំណាលជាមួយលោក ម៉ី សារុន

លោកពិតជាមានសេចក្តីរីករាយខ្លាំងណាស់ចំពោះក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានមកធ្វើបទបង្ហាញនៅពេលនេះពិសេសការផ្តល់ព័ត៌មានថ្មីៗទាក់ទងនឹងសាលាក្តីខ្មែរក្រហម ។ ព័ត៌មានទាំងនេះពិតជាសំខាន់ណាស់សម្រាប់លោកព្រោះរូបលោកមិនសូវមានពេលតាមដានដំណើរការសវនាការប៉ុន្មានទេ ប៉ុន្តែលោកក៏ធ្លាប់បានតាមដានតាមរយៈទូរទស្សន៍ វិទ្យុ ខ្លះដែរ ។ ទោះជាយ៉ាងណាក៏ដោយ សារុន រីករាយ និងគាំទ្រឲ្យមានតុលាការខ្មែរក្រហមនេះឡើងហើយគាត់ក៏សង្ឃឹមថាប្រជាពលរដ្ឋខ្មែរក៏ដូចជារូបលោកផ្ទាល់នឹងស៊ូក្តីលើករណី០០២ នេះឲ្យបានជោគជ័យតទៅទៀត ។ លោកបានបញ្ជាក់ថាទាំងនេះ មិនមែនជាការសងសឹកនោះទេ តែដើម្បីបញ្ជាក់ឲ្យប្រជាជនកម្ពុជាឃើញថា ប្រជាជនខ្មែរស្លូតត្រង់ជាងពីរលាននាក់ ក៏ដូចជាប្រទេសជាតិទាំងមូលត្រូវបានមនុស្សមួយក្រុមនេះជាអ្នកបំផ្លាញគឺបំផ្លាញតាំងពីអរិយធម៌វប្បធម៌ ឬសីងតែសម្លាប់ផ្តាច់ពូជខ្មែរតែម្តង ។ តែសំណាងដោយមានការសហការពីប្រទេសជាមិត្តមកជួយរំដោះ បើមិនអ៊ីចឹងទេ ទាំងគេ ទាំងគាត់ ប្រហែលជាមិនមានមុខមកនិយាយនៅពេលនេះទេ ។ លើសពីនេះទៅទៀត សារុន បន្តថា ការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យសម្រាប់ក្មេងៗជំនាន់ក្រោយគឺពិតជាល្អណាស់ និងត្រូវតែមានការសិក្សានេះ ព្រោះកាលណាប្រទេសដែលកើតមានព្រឹត្តិការណ៍អ្វីមួយគឺត្រូវតែកត់ត្រាជាឯកសារទុក ហើយឯកសារនេះគឺសម្រាប់ក្មេងៗជំនាន់ក្រោយធ្វើការសិក្សាដើម្បីជាការជៀសវាងកុំឲ្យសម្លាប់មនុស្សឬប្រល័យពូជសាសន៍អ៊ីចឹងទៀត ។ ញញឹមតិចៗ ហើយនិយាយថា "ខ្មាសជាតិសាសន៍ដទៃដែលសម័យនេះ គេលើកថាពិភពលោកតែមួយនោះរឿងអី យើងទៅសម្លាប់ជាតិសាសន៍ឯងទៀត យើងគួរតែរស់សុខសាន្តទាំងអស់គ្នាដើម្បីជោគជ័យទៅថ្ងៃមុខប្រទេសយើងរីកចម្រើនទាំងអស់គ្នា ។

ដោយឡែកលោកវរៈសេនីយ៍មួយរូបក្រោយពីស្តាប់ការធ្វើបទបង្ហាញដែលនិយាយពីការធ្វើការបដិសេធរបស់ នួន ជា

ចំពោះសក្ខីកម្មរបស់ ឌុច បានផ្តល់ជាទស្សនៈថា ការបដិសេធរបស់ នួន ជា នៅសវនាការនៅពេលនេះគឺមិនត្រឹមត្រូវទេ ព្រោះពេលនោះ នួន ជា ពិតជាមេដឹកនាំនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ពិតប្រាកដមែន ។ ចំពោះការកាត់ទោសមេដឹកនាំទាំងនេះគឺអាស្រ័យ ទៅលើការវិនិច្ឆ័យរបស់តុលាការទេហើយលោកសំណូមពរទៅ តុលាការធ្វើយ៉ាងណាកាត់ទោសឲ្យបានឆាប់ជៀសវាងកុំឲ្យជន ជាប់ចោទទាំងនោះស្លាប់មុនការកាត់ទោស ។ លោកវរៈសេនីយ៍ វង្ស ប៊ុនថន នោះទេ គាត់បានផ្តល់ជាយោបល់ចំពោះការបដិសេធ របស់ នួន ជា ថា គាត់ពិតជាមិនជឿនោះទេថា នួន ជា ពិតជាមិន ដឹងរឿងរ៉ាវនូវឧក្រិដ្ឋកម្មក្នុងអំឡុងពេលដែលខ្លួនគ្រប់គ្រងព្រោះ ពេលនោះ នួន ជា គឺជាមេដឹកនាំជាន់ខ្ពស់មួយរូប ហើយនៅក្នុងរបប កម្ពុជាប្រជាធិបតេយ្យ ការដឹកនាំគឺស្មោះត្រង់ ហ្មត់ចត់ គោរពវិន័យ ហេតុនេះ នួន ជា មិនមានហេតុផលណាមួយដែលថា មិនដឹងរឿង ដែលបានកើតឡើងនោះទេ ។ ប៊ុនថន បានឲ្យដឹងថា ការធ្វើពលកម្ម ជាទម្ងន់ ការបង្អត់ អាហារ និងការបាត់បង់សាច់ញាតិ បងប្អូន គឺជារឿងដែលធ្វើឲ្យលោកឈឺចាប់បំផុត នៅពេលដែលរំពុកពីរបប ខ្មែរក្រហម ។ ចំពោះលោកដំណើរការនៃការកាត់ទោសអតីតមេដឹកនាំ ខ្មែរក្រហមទាំងនេះគឺអាស្រ័យទៅលើនីតិវិធីរបស់តុលាការទៅចុះ ។ ដូចគ្នានឹងលោកវរៈសេនីយ៍ ហង្ស សំអុល បានឲ្យដឹងថា គាត់ពិតជា ខឹងនឹង នួន ជា ណាស់ដែលបដិសេធចំពោះសក្ខីកម្មរបស់ ឌុច ។ “នួន ជា មិនសមបដិសេធនឹងទង្វើដែលខ្លួនបានធ្វើមកលើប្រជាជនកម្ពុជា យើង នៅជិតនាន់បីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃនោះទេ ។ នៅលើពិភពលោកនេះ មានតែរបបខ្មែរក្រហមនេះទេដែលឃោរឃៅព្រៃផ្សៃបំផុត” ។ គាត់ ធ្លាប់ឆ្លងកាត់របបខ្មែរក្រហមនិងដឹងរាល់រឿងរ៉ាវទុក្ខវេទនាដែល បានកើតឡើងក្រោមការគ្រប់គ្រងរបស់មេដឹកនាំទាំងនោះ ហេតុនេះ ការបដិសេធរបស់ នួន ជា នៅពេលនេះមិនអាចទទួលយកបានទេ ។

បន្ទាប់ពីបញ្ចប់ការធ្វើបទបង្ហាញពីការវិវឌ្ឍរបស់ដំណើរ ការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមនេះពីសំណាក់ក្រុមឃ្លាំមើល តុលាការខ្មែរក្រហមនិងការផ្សព្វផ្សាយពីគេហទំព័រឃ្លាំមើលតុលាការ ខ្មែរក្រហមរបស់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមាន លឹម ជ័យទត្ត ចាន់ ប្រាថ្នា និង ឌី សុជាតា ជាអ្នកធ្វើបទបង្ហាញ ទន្ទឹមនឹងនោះសកលវិទ្យាល័យការពារជាតិក៏បានស្នើឲ្យអ្នកទាំងអស់ គ្នាមកធ្វើបទបង្ហាញនេះម្តងទៀតសម្រាប់ដំណើរការនីតិវិធីរបស់ តុលាការនៅពេលក្រោយទៀត ។ **ផាន់ សារៈមុនិន្ទ**



កងយោធពលខេមរភូមិន្ទកំពុងអានឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាអំឡុងពេលនៃការចុះទៅផ្សព្វផ្សាយស្តីអំពីដំណើរការវិវឌ្ឍរបស់ សាលាក្តីខ្មែរក្រហមនៅសាកលវិទ្យាល័យការពារជាតិកាលពីខែមេសា កន្លងទៅ

# ជួបជាមួយអតីតកម្មាភិបាលខ្មែរក្រហមនៅអន្លង់វែង

អន្លង់វែងជាតំបន់ដាច់ស្រយាលមួយនៃប្រទេសកម្ពុជា និងមានព្រំប្រទល់ដែនជាប់នឹងប្រទេសថៃ ដោយមាន "ច្រកជាំស្រងាំ" ជាច្រកព្រំដែនអន្តរជាតិរវាងប្រទេសទាំងពីរ ។ មុនឆ្នាំ ២០០១ អន្លង់វែង ជាឃុំមួយស្ថិតក្នុងស្រុកស្វាយលើរបស់ខេត្តសៀមរាប ។ បច្ចុប្បន្ន អន្លង់វែងជាស្រុកមួយក្នុងចំណោមស្រុកទាំងប្រាំរបស់ខេត្តឧត្តរមានជ័យ រួមមានស្រុកសំរោងបន្ទាយអំពិល ចុងកាល់ និងត្រពាំងប្រាសាទ ។ កាលពីមុនផ្លូវធ្វើដំណើរទៅកាន់ស្រុកអន្លង់វែងមានភាពលំបាកជាខ្លាំង ព្រមទាំងចំណាយពេលវេលាយូរក្នុងការធ្វើដំណើរ តែបច្ចុប្បន្នផ្លូវមានភាពងាយស្រួលច្រើនដោយសារមានថ្នល់ក្រាលកៅស៊ូ ដែលភ្ជាប់ពីទីរួមខេត្តសៀមរាប មានចម្ងាយផ្លូវប្រវែង១២៥គីឡូម៉ែត្រ ។ អ្វីដែលជាទីចាប់អារម្មណ៍គឺនៅអមសងខាងផ្លូវលម្អទៅដោយសម្រស់ធម្មជាតិខៀវស្រងាត់បានកំពុងតែអួតបង្ហាញដល់អ្នកធ្វើដំណើរឲ្យជាប់ចិត្តគយគន់នូវទេសភាពព្រៃភ្នំដ៏ស្រស់បំព្រងគួរជាទីមនោរម្យ ។

ប្រសិនបើយើងត្រឡប់ទៅអតីតកាល អន្លង់វែង ក៏ជាតំបន់មួយមិនខុសពីតំបន់នៅតាមព្រំដែនប្រទេសថៃដទៃទៀតឡើយ ខ្មែរក្រហមជាច្រើនបានរត់គេចមកលាក់ខ្លួនធ្វើការតស៊ូជាមួយនឹងរាជរដ្ឋាភិបាល ។ បន្ថែមពីនេះទៀត អន្លង់វែង ក៏ជាតំបន់ភ្នំ និងជាតំបន់ដែលគ្របដណ្ដប់ទៅដោយព្រៃឈើជាច្រើនសន្ធឹកសន្ធាប់ ។ ដូច្នេះមេដឹកនាំខ្មែរក្រហមជាច្រើនបានរត់មកតាំងមូលដ្ឋានទ័ពនៅលើភ្នំដងរែកចាប់តាំងពីឆ្នាំ១៩៧៩មក ។

ពេលនេះ អន្លង់វែង ហាក់បីដូចជាព្យាយាមបិទបាំងនូវប្រវត្តិពីអតីតកាលរបស់ខ្លួនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមអស់រយៈពេលជិតម្ភៃឆ្នាំ ។ អន្លង់វែង ជាអតីតតំបន់សម្បូរទៅដោយគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះជាច្រើនដែលកប់ក្នុងដីនៅអំឡុងសង្គ្រាម ។ ទោះបីជាសង្គ្រាមបានបញ្ចប់ក៏បងប្អូនដែលរស់នៅតំបន់នេះនៅជួបបញ្ហាប្រឈមជាច្រើនក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្លួន ។

ង៉ុំ ខិន អាយុ៦៣ឆ្នាំ ជាអតីតយោធាខ្មែរក្រហមដែលមកពីស្រុកសៀមរាប ខេត្តសៀមរាប បានរៀបរាប់ឲ្យដឹងថា គាត់



ផ្លូវទៅច្រកព្រំដែនអន្តរជាតិជាំស្រងាំ



ផ្ទះដែលមេដឹកនាំរបស់ចលនាខ្មែរក្រហមប្រើជាទីតាំងដើម្បីចរចាមុនធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាលក្នុងក្នុងអំឡុងទសវត្សរ៍៩០



ទីរួមស្រុកអន្លង់វែង

ជាកូនក្នុងត្រកូលគ្រួសារកសិករ ។ដោយសារតែជីវភាពគ្រួសារទីទ័លក្រខ្វាំងពេករកព្រឹកខ្វះល្ងាច រកល្ងាចខ្វះព្រឹក គាត់បានសម្រេចចិត្តបោះបង់ចោលការសិក្សាមកជួយធ្វើស្រែចម្ការឪពុកម្តាយវិញ ។ ខិន បន្តទៀតថា “ទោះជាខ្ញុំទៅសាលាក៏គ្មានគ្រូបង្រៀនដែរ ព្រោះសង្គ្រាមកាន់តែឆាបឆេះខ្លាំងឡើងៗរវាងទាហាន លន់ នល់ និងយោធាខ្មែរក្រហម” ។ និយាយពីព្រឹត្តិការណ៍ក្នុងឆ្នាំ១៩៧០ បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ វិញ ខិន ហាក់ដូចជាមានការស្ទាក់ស្ទើរក្នុងចិត្តបន្តិចនៅពេលដែលសួរថា “ពូចូលធ្វើទាហានខ្មែរក្រហមដំបូងនៅពេលណា?” ។ ប្រកបដោយទឹកមុខក្រៀមក្រំ ខិន បានរំឭកពីអតីតកាលរបស់គាត់ថា នៅក្នុងឆ្នាំ


ជុំ ខិន

១៩៧៣ ខណៈពេលគាត់កំពុងភ្ជួរស្រែ ស្រាប់តែយោធាខ្មែរក្រហមមួយក្រុមមកចាប់គាត់និងបញ្ជូនគាត់ទៅប្រាសាទអង្គរធំដើម្បីហ្វឹកហាត់ជាយោធា ។ បន្ទាប់ពីហាត់បានរយៈពេលបីខែ គាត់ត្រូវបានបញ្ជូនទៅសមរភូមិខាងខេត្តកំពង់ស្ពឺដើម្បីច្បាំងជាមួយទាហានលន់នល់ ។ ស្ថិតក្នុងវ័យជាយុវជនដែលមានបទពិសោធន៍ក្មេងខ្ចី ខិន មានអារម្មណ៍ភ័យខ្លាចជាពន់ពេកក្នុងចិត្តដោយចង់រត់ចោលសមរភូមិជាច្រើនដង ។ បន្ទាប់ពីរំដោះទីក្រុងភ្នំពេញបាននៅឆ្នាំ១៩៧៥ ខិន ត្រូវចាត់តាំងឲ្យធ្វើជាកម្មកររោងចក្រអុកស៊ីហ្សែននៅក្នុងទីក្រុងភ្នំពេញ ។ ជីវភាពរស់នៅជាកម្មករក្នុងទីក្រុងមិនសូវជាមានការខ្វះខាតទេគឺការហូបចុកបានគ្រប់គ្រាន់និងមានការកំសាន្តនៅចុងសប្តាហ៍ថែមទៀតផង ។ ប៉ុន្តែ ខិន ត្រូវរត់គេចពីកងទ័ពវៀតណាមពីភ្នំពេញមកដល់ភ្នំដងរែក បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានដួលរលំក្នុងឆ្នាំ១៩៧៩ ។ ពេលនិយាយពីស្ថានភាពបច្ចុប្បន្ន ខិន មានភាពរីករាយក្នុងចិត្តរហូតទឹកភ្នែកហូរចុះដោយមិនដឹងខ្លួនហើយគាត់បាននិយាយថា “ខ្ញុំមិនដែលនឹកស្មានថានឹងមានពេលវេលាអាចវិលមករកបងប្អូនវិញដូចច្នេះទេ ។


ផន់ គីមយ៉ន

ផន់ គីមយ៉ន អាយុ៦១ឆ្នាំ ។ គីមយ៉ន ជាអតីតយោធា ខ្មែរក្រហម និងមានស្រុកកំណើតនៅស្រុកស្រែអំបិល ខេត្តកោះកុង បានរំឭកថា បន្ទាប់ពីគាត់ចូលធ្វើយោធាខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៣ យ៉ន ត្រូវចាត់តាំងឲ្យមកឈរជើងនៅតាមបណ្តោយផ្លូវជាតិលេខ៤ ស្ថិតនៅក្នុងតំបន់វាលរេញ ។ យ៉ន មិនមានឱកាសអាចទៅសួរសុខទុក្ខឪពុកម្តាយ ឬបងប្អូនទេ ។ ក្រោយសង្គ្រាមចប់ យ៉ន ត្រូវចាត់តាំងឲ្យធ្វើជាកងអនុសេនាធំការពារនៅតាមបណ្តោយព្រំដែនប្រទេសកម្ពុជា-វៀតណាមដែលស្ថិតក្នុងភូមិភាគបូព៌ា ខេត្តកំពង់ចាម និងភៀសខ្លួនមកធ្វើការតស៊ូជាមួយនឹងរាជរដ្ឋាភិបាលបន្ទាប់ពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ១៩៧៩ ។ យ៉ន ឈប់ធ្វើជាយោធាខ្មែរក្រហមនៅក្នុងឆ្នាំ១៩៩៨ និងមកធ្វើជាគ្រូបង្រៀនក្មេងៗនៅលើភ្នំដងរែក ។ ការសិក្សារៀនសូត្ររបស់ក្មេងៗមិនមានថ្នាក់រៀនត្រឹមត្រូវទេគឺគ្រាន់តែរៀននៅក្រោមម្លប់ឈើ ហើយក្មេងៗត្រូវអង្គុយផ្ទាល់នឹងដី ។ ចំពោះកម្មវិធីសៀវភៅសិក្សាត្រូវបានទទួលជំនួយពីអង្គការសហប្រជាជាតិ ។ ចំពោះជីវភាពនៅលើភ្នំដងរែក ខ្មែរក្រហមធ្វើពាណិជ្ជកម្មដោះដូរជាមួយឈ្មួញថៃ ។ ការធ្វើពាណិជ្ជកម្មនេះ ខ្មែរក្រហមបានកាប់ដើមឈើមានតម្លៃជាច្រើនលក់ឲ្យឈ្មួញថៃដើម្បីដូរយកជាស្បៀងអាហារ និងសម្ភារប្រើប្រាស់យកមកផ្គត់ផ្គង់យោធា និងប្រជាជន ។ យ៉ន បានបន្តទៀតថា ប្រជាជនបានហូបចុកគ្រប់គ្រាន់ ហើយស្បៀងអាហារ

ទាំងនេះតែងតែទទួលបានមួយខែម្តង ឬពីរសប្តាហ៍ម្តង ។ ក្រោយពីសមាហរណកម្មក្នុងឆ្នាំ១៩៩៨ ទើប យ៉ន មានឱកាសបានទៅរកគ្រួសារនៅឯស្រុកស្រែអំបិល ខេត្តកោះកុង ។ ប៉ុន្តែពេលទៅដល់ទីនោះ ទើប យ៉ន ដឹងថា ឪពុកម្តាយរបស់គាត់បានស្លាប់អស់ទៅហើយ អំឡុងពេលដែលគាត់កំពុងធ្វើការតស៊ូនៅលើភ្នំដងរែក ។ គាត់គ្រាន់តែបានជួបពូមីងដែលរួចជីវិតពីរបបខ្មែរក្រហមប៉ុណ្ណោះ ។ សាច់ញាតិរបស់គាត់ស្ទើរតែចំណាំមុខ យ៉ន ពុំបានព្រោះបែកគ្នាយូរពេក ហើយម្នាក់ៗគិតថាគាត់ស្លាប់បាត់ទៅហើយ ។


អៀន ចិញ

នៅពេលរំពុកដល់ឈ្មោះ តាម៉ុក វិញ អៀន ចិញ អាយុ ៥០ឆ្នាំ បានរៀបរាប់ឲ្យដឹងថាក្រោយពេលខ្មែរក្រហមរត់មកតស៊ូក្នុងឆ្នាំ១៩៧៩ អន្លង់វែង ជាតំបន់មួយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក ។ តាម៉ុក ជាមេដឹកនាំមួយរូបដែលពិការជើងឆ្វេងម្ខាងដោយសារផ្ទុះគ្រាប់មីន នៅពេលដែលគាត់ឈរបញ្ជាកូនចៅឲ្យធ្វើការកសាងផ្លូវ ។ តាម៉ុក ជាមនុស្សមានចរិតចូលចិត្តនិយាយស្តីដោយប្រើពាក្យសម្តីមិនពិរោះចំពោះប្រជាជន ។ ចិញ នៅចាំថា មានពេលមួយគាត់ និងអ្នកក្នុងក្រុមជាមួយគ្នាបីនាក់បានទៅជញ្ជាត់ត្រីនៅទំនប់អូរដឹក ហើយត្រូវ តាម៉ុក ជេរស្តីដោយប្រើពាក្យអសុរោះមិនគួរឲ្យចង់ស្តាប់ ព្រោះតែក្រុមរបស់គាត់ទៅជញ្ជាត់ត្រីនៅលើទំនប់កសាងមិនទាន់ហើយ ។

ផ្ទុយពីអ្វីដែល ចិញ បាននិយាយ សុខ រិន អាយុ៤៩ឆ្នាំ បានបង្ហាញពីអារម្មណ៍របស់ខ្លួនដោយរៀបរាប់ថា តាម៉ុក ចូលចិត្តនិយាយស្តីប្រើពាក្យមិនពិរោះៗក៏ពិតមែន ប៉ុន្តែ តាម៉ុក ជាមនុស្សចិត្តល្អ ព្រោះនៅពេលគ្រួសារណាខ្វះខាតក្នុងជីវភាពគ្រួសារទាំង


សុខ រិន ជាមួយកូនស្រី

នោះតែងតែទៅសុំជាលុយឬអង្ករពី តាម៉ុក យកមកផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ ។ នៅចន្លោះឆ្នាំ១៩៧៩-១៩៩៨ ប្រជាជននៅតំបន់អន្លង់វែងអាចប្រកបរបរចិញ្ចឹមជីវិតបន្ថែមសម្រាប់គ្រាន់ដោះស្រាយជីវភាពដោយការធ្វើស្រែចម្ការនិងការទាញយកផលពីព្រៃឈើដើម្បីយកមកធ្វើការដោះដូរជាមួយអ្នកនៅជិតខាងឬឈ្មួញថៃ ។ រិន បានឲ្យដឹងថា ចំពោះការចាយវាយ និងការទិញរបស់របរផ្សេងៗគឺយកជាលុយបាតនៅពេលនោះ ។ គាត់ចាប់ផ្តើមស្គាល់លុយខ្មែរ ក្រោយពេលដែលតំបន់អន្លង់វែងធ្វើសមាហរណកម្មហើយនេះទេ ។


ឃឹម ខេង

ឃឹម ខេង អាយុ៧៣ឆ្នាំ ជាអតីតយោធាខ្មែរក្រហម និងមានស្រុកកំណើតនៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ ខេង ធ្វើជាយោធាខ្មែរក្រហម ព្រោះគាត់ជឿលើសម្តេចព្រះនរោត្តម សីហនុ ដើម្បីធ្វើការប្រឆាំងនឹងរបប លន់ នល់ ក្នុងគោលបំណងនាំយកអំណាចមកថ្វាយព្រះអង្គវិញ ។ ខេង បន្តទៀតថា ការទម្លាក់គ្រាប់

បែករបស់សហរដ្ឋអាមេរិកនិងរដ្ឋប្រហារគឺជាបុសគល់ធ្វើឲ្យកម្លាំងតស៊ូខ្មែរក្រហមកាន់តែរីកធំឡើងៗ នៅតាមតំបន់តស៊ូជាច្រើនពេញផ្ទៃប្រទេស ។

ឈួរ រីម អាយុ៥៥ឆ្នាំ ក៏ជាអតីតយោធាខ្មែរក្រហមដែរ ។ រីម ដែលមានស្រុកកំណើតនៅស្រុកកងមាស ខេត្តកំពង់ចាម បានរៀបរាប់ថាគាត់ស្ម័គ្រចិត្តចូលធ្វើជាយោធាខ្មែរក្រហមក្នុងឆ្នាំ១៩៧៣ ដោយមើលឃើញមិត្តភក្តិជាច្រើននៅក្នុងភូមិចូលរួមចលនាតស៊ូរបស់ខ្មែរក្រហម និងដោយសារស្ថានភាពច្របូលច្របល់របស់ប្រទេសជាតិ ។ រីម បានរៀបរាប់ពីបទពិសោធន៍ក្នុងការរត់គេចទៅរស់នៅលើភ្នំដងរែកថា "ជីវិតរបស់ខ្ញុំពិតជាមានការលំបាកខ្លាំង ព្រោះត្រូវធ្វើដំណើរកាត់ព្រៃកាត់ភ្នំ ហើយចំណាយរយៈពេលជាងពីរខែទើបមកដល់ភ្នំដងរែក" ។ រីម និងអ្នកផ្សេងៗទៀតត្រូវដេកនៅក្រោមដើមឈើផ្ទាល់នឹងដី ហើយការហូបចុកខ្វះខាតយ៉ាងខ្លាំងដោយត្រូវហូបផ្លែឈើព្រៃជំនួសបាយឬជួនកាលលួចសុំអង្ករពីប្រជាជននៅក្នុងភូមិពេលដែលខ្វះខ្លាំង ។ មានពេលខ្លះ យើងត្រូវធ្វើការប្រយុទ្ធជាមួយទាហានវៀតណាមដែលដេញតាមពីក្រោយឬធ្វើដំណើរប្រទះជួបគ្នាម្តងៗ ។


គង់ បុណ្យ

ជាមួយគ្នានេះដែរ គង់ បុណ្យ អាយុ៥២ឆ្នាំ រស់នៅក្នុងឃុំត្រពាំងតាវ ស្រុកអន្លង់វែង ក៏ជាអតីតជាយោធាខ្មែរក្រហមមួយរូបដែរ ។ គាត់មានស្រុកកំណើតនៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ បានឲ្យដឹងថាការចូលធ្វើយោធាខ្មែរក្រហមមិនមានអ្នកណាមកបង្ខំគាត់នោះទេ គាត់ចូលដោយមានការពេញចិត្តស្រឡាញ់ហើយគាត់ក៏ចង់ក្លាយជាយោធា ។ទោះជាយ៉ាងនេះក្តីក្នុងការចូលរួមតស៊ូរបស់ប្រជាជនខ្មែរគ្រប់រូបគឺសុទ្ធតែមានឆន្ទៈដូចគ្នាដោយស្មារតីស្រឡាញ់ជាតិ ស្រឡាញ់ទឹកដី និងចង់រំដោះប្រទេសជាតិឲ្យរួចផុតពីសង្គ្រាម ។

ប៉ុន្តែសេចក្តីប្រាថ្នារបស់ប្រជាជនខ្មែរគ្រប់រូបមិនបានដូចអ្វីដែលកើតចេញពីការខិតខំពុះពារទេ បន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហមនៅទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានអនុវត្តគោលនយោបាយកុម្មុយនីស្តផ្តាច់ការជ្រុលហួសហេតុ ។ រយៈពេលជិតបួនឆ្នាំ ខ្មែរក្រហមបានដឹកនាំប្រទេសឆ្ពោះទៅរកចំណុចសូន្យទាំងគ្រប់វិស័យ ជាពិសេសប្រជាជនខ្មែររាប់លាននាក់ត្រូវស្លាប់ដោយជំងឺ ការអត់ឃ្លាន និងការសម្លាប់ ។ មូលហេតុទាំងនេះ បានធ្វើឲ្យរបបខ្មែរក្រហមដួលរលំនៅក្នុងឆ្នាំ១៩៧៩ និងបានរត់ភៀសខ្លួនទៅតាមតំបន់បណ្តោយព្រំដែនប្រទេសថៃដើម្បីធ្វើការតស៊ូជាមួយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដែលគាំទ្រដោយវៀតណាម ។

ការចំណាយជីវិតចុងក្រោយរបស់អតីតខ្មែរក្រហមដែលធ្លាប់តស៊ូប្រឆាំងនឹងរាជរដ្ឋាភិបាលកម្ពុជានៅតាមបណ្តោយព្រំដែនប្រទេសថៃនៅលើភ្នំដងរែកនិងអន្លង់វែងម្នាក់ៗមិនប្រាថ្នាអ្វីក្រៅពីការរស់នៅមានសុភមង្គលនិងប្រទេសជាតិមានសន្តិភាពនោះទេ ។ រយៈពេលជិតពីរទសវត្សរ៍បានកន្លងផុត បន្ទាប់ពីការធ្វើសមាហរណកម្មនៅក្នុងឆ្នាំ១៩៩៨ ដោយយោធាខ្មែរក្រហមបានចុះចូលជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាដើម្បីកសាងជីវិតសាជាថ្មី ។ សេចក្តីភ័យខ្លាចដែលធ្លាប់តែតាមលងបន្លាចគ្រប់ពេលវេលាក្នុងអំឡុងសង្គ្រាមត្រូវប្រែទៅជាសេចក្តីសុខនៅក្នុងគ្រួសារជាមួយនឹងស្នាមញញឹមនៅលើផ្ទៃមុខ ។ ការពិភាក្សាដែលធ្លាប់តែលើកឡើងដោយក្តីព្រួយបារម្ភក្នុងចិត្តត្រូវប្រែក្លាយទៅជាការពិភាក្សាដោយសប្បាយរីករាយ ។

ទន្ទឹមការអភិវឌ្ឍប្រទេសជាតិតាមបែបសកលភាវូបនីយកម្ម កត្តាដែលជាផលលំបាកសំខាន់នាពេលបច្ចុប្បន្នសម្រាប់អតីតខ្មែរក្រហមមួយចំនួនតូចរស់នៅក្នុងស្រុកអន្លង់វែងគឺបញ្ហាដីធ្លីដែលក្រុមហ៊ុនឯកជនមួយចំនួនធ្វើការអភិវឌ្ឍនិងថាតើត្រូវចាប់ផ្តើមកសាងជីវិតរស់នៅថ្មីដោយរបៀបណា?

**ម៉ម សុខណ្ណ**

# ការពារការសម្ងាត់របស់ដំណើរការស៊ើបអង្កេត ឬមិនមាត់អ្នកសារព័ត៌មាន? សេរីភាពនៃការបញ្ចេញមតិ

*(តពីលេខមុន)*

***ក.១) ការទទួលបានព័ត៌មានរបស់អ្នកសារព័ត៌មាន និងការប្រើប្រាស់ទណ្ឌកម្មរបស់តុលាការខ្មែរក្រហម***

***១) សេរីភាពក្នុងការបញ្ចេញមតិយោបល់នៅក្នុងប្រទេសកម្ពុជា***

ការទទួលបានព័ត៌មានរបស់អ្នកសារព័ត៌មាននៅឯតុលាការខ្មែរក្រហមមិនត្រូវបានយល់ដឹងឲ្យបានពេញលេញទេបើខុសពីបរិបទនៃទស្សនៈយល់ឃើញរបស់ប្រទេសកម្ពុជាទៅលើអ្នកសារព័ត៌មាន និងកាតព្វកិច្ចរបស់អ្នកសារព័ត៌មានដូចដែលមានចែងក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិទាក់ទងនឹងសេរីភាពក្នុងការបញ្ចេញមតិយោបល់ ។

មាត្រា៤១នៃរដ្ឋធម្មនុញ្ញកម្ពុជាគូសបញ្ជាក់ថាសេរីភាពនៃការបញ្ចេញមតិយោបល់អ្នកសារព័ត៌មានការបោះពុម្ពផ្សាយនិងការប្រជុំរបស់ប្រជាពលរដ្ឋខ្មែរត្រូវបានធានាដោយច្បាប់កម្ពុជា ។ បន្ថែមលើនេះមាត្រា៣១នៃរដ្ឋធម្មនុញ្ញកម្ពុជាតម្រូវឲ្យប្រទេសកម្ពុជា "ធ្វើការទទួលស្គាល់និងគោរពសិទ្ធិមនុស្សដែលមានចែងនៅក្នុងសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្សនិងកតិកាសញ្ញានិងអនុសញ្ញាផ្សេងទៀតដែលទាក់ទងនឹងសិទ្ធិមនុស្ស" ។ ទាំងសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលជាកតិកាសញ្ញាស្ដីពីសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ បានធ្វើការការពារសេរីភាពក្នុងការបញ្ចេញមតិយោបល់ ។ ប៉ុន្តែបើទោះបីជាប្រទេសកម្ពុជាត្រូវបានតម្រូវឲ្យគោរពសេរីភាពក្នុងការបញ្ចេញមតិយោបល់ដូចដែលមានចែងក្នុងច្បាប់កម្ពុជានិងច្បាប់អន្តរជាតិក៏ដោយក៏ការរឹតត្បិតលើកិច្ចការរបស់អ្នកសារព័ត៌មាននៅតែបន្តចោទជាបញ្ហាដដែល ។

តុលាការខ្មែរក្រហមត្រូវបានបង្កើតឡើងដើម្បីធ្វើជាគំរូមួយសម្រាប់ប្រព័ន្ធច្បាប់កម្ពុជាក្នុងបុព្វហេតុល្អគឺថាៈ សេរីភាពក្នុងការបញ្ចេញមតិយោបល់គឺជាបញ្ហាដែលចាក់ឫសនៅក្នុងប្រទេសកម្ពុជាជាយូរលង់ណាស់មកហើយ ហើយរបាយការណ៍របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅឆ្នាំ២០១០នេះបានគូសបង្ហាញថាសេរីភាពក្នុងការបញ្ចេញមតិយោបល់គឺជាបញ្ហាព្រួយបារម្ភដ៏ចម្បងមួយនៅក្នុងប្រទេសកម្ពុជា ហើយក៏បានកត់សម្គាល់ថា "តុលាការកម្ពុជាទំនងមិនធ្វើការបកស្រាយលើច្បាប់និងការរឹតត្បិតលើសេរីភាពក្នុងការបញ្ចេញមតិយោបល់ឲ្យសមស្របទៅតាមច្បាប់កម្ពុជាដែលមិនមានលក្ខណៈស្រដៀងគ្នានឹងបទដ្ឋានអន្តរជាតិដែលដាក់បញ្ចូលនៅក្នុងប្រទេសកម្ពុជាទេ" ។

ការរឹតត្បិតលើសេរីភាពក្នុងការបញ្ចេញមតិយោបល់កាន់តែកើនឡើង ។ បើយោងតាមអង្គការសហប្រជាជាតិ បញ្ហាចម្បងគឺថាការអនុម័តលើច្បាប់កាលពីឆ្នាំ២០០៩ស្ដីពីការផ្សព្វផ្សាយព័ត៌មានមិនពិតនិងការប្រមាថមើលងាយកិត្តិយសរបស់ជនណាម្នាក់និងការអនុវត្តច្បាប់ទាំងអស់នេះមិនបានធ្វើឲ្យមានតុល្យភាពដ៏សមរម្យមួយរវាងការការពារកិត្តិយសជាឯកជននិងការផ្សព្វផ្សាយព័ត៌មានជាសាធារណៈទាក់ទងនឹងប្រយោជន៍របស់សាធារណជនឡើយ ។ ស្រដៀងគ្នាថ្មីៗនេះ អ្នកឃ្លាំមើលបញ្ហាសិទ្ធិមនុស្សបានគូសបញ្ជាក់ថាការគំរាមកំហែងពីសំណាក់រដ្ឋាភិបាលកម្ពុជាក្នុងការចាប់ខ្លួននិងចាត់វិធានការតាមផ្លូវច្បាប់ប្រឆាំងនឹងអ្នកសារព័ត៌មានបានចោទជាបញ្ហាចម្បងហើយបានណែនាំថាវិធានការបែបនេះត្រូវបានប្រើប្រាស់ជាញឹកញាប់ដើម្បីរឹតត្បិតការបញ្ចេញមតិយោបល់ដោយសេរី ។ គួរឲ្យកត់សម្គាល់អ្នកឃ្លាំមើលបញ្ហាសិទ្ធិមនុស្សក៏បានរាយការណ៍ថាអ្នកសារព័ត៌មានប្រាំមួយនាក់ត្រូវបានសម្លាប់នៅក្នុងប្រទេសកម្ពុជាក្នុងរយៈពេលដប់ប្រាំឆ្នាំកន្លងមកនេះ ។ ក្នុងការដើរតួជាគំរូមួយសម្រាប់ប្រព័ន្ធច្បាប់កម្ពុជាតុលាការខ្មែរក្រហមមានសក្ដានុពលភាពក្នុងការជួយដោះស្រាយបញ្ហាអនុវត្តច្បាប់កម្ពុជា ហើយក៏អាចចោទជាបញ្ហាបន្ថែមដែលប៉ះពាល់ដល់សេរីភាពក្នុងការបញ្ចេញមតិយោបល់នៅក្នុងប្រទេសកម្ពុជា ។

***២) ការទទួលបានព័ត៌មានរបស់អ្នកសារព័ត៌មានក្នុងអំឡុង***

## ដំណើរការស៊ើបអង្កេតរបស់ចៅក្រមនៅឯតុលាការខ្មែរក្រហម

សហចៅក្រមស៊ើបអង្កេតនិងចៅក្រមអង្គបុរេជំនុំជម្រះ បានចេញករណីលើកលែងមួយចំនួនទាក់ទងនឹងការសន្ទតពីការសម្ងាត់នៅក្នុងដំណើរការស៊ើបអង្កេតមុនអង្គជំនុំជម្រះក្តីចាប់ផ្តើម ។ ចៅក្រមបានព្រមានដល់អ្នកសារព័ត៌មានជាច្រើនលើកពីការដាក់ទណ្ឌកម្មសម្រាប់ការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងដំណើរនីតិវិធីសម្ងាត់របស់តុលាការ ។

នៅក្នុងដំណើរការស៊ើបអង្កេតលើសំណុំរឿង០០១របស់ ឌុច កាលពីឆ្នាំ២០០៨ គ្រាស៊ី ហេរ្យលគុន អ្នកសារព័ត៌មានរបស់កាសែតភ្នំពេញប៉ុស្តិ៍ត្រូវបានសួរចម្លើយដោយប៉ូលីសអស់រយៈពេលជាច្រើនម៉ោងនៅក្រៅបរិវេណសារមន្ទីរទួលស្លែងនៅពេលដែល ឌុច បានចូលគុកទួលស្លែងនេះម្តងទៀត ហើយរូបថតឌីជីថលរបស់គាត់ត្រូវលុបចោល ។ ជាមួយគ្នានេះកាសែតខេមបូឌាដេលី បានរាយការណ៍ថា នៅថ្ងៃដដែលនោះ ចនវ៉ិក អ្នកថតរូបរបស់ម៉ាហ្គណម ត្រូវបានព្រមានដោយមន្ត្រីតុលាការថា ប្រសិនបើគាត់បោះពុម្ពរូបថតរបស់ឌុចគាត់នឹងត្រូវចាត់ចូលក្នុងបញ្ជីខ្មៅរបស់តុលាការ ។ លោក គស្លែន ហ៊ែលហ្គេត ជាអ្នកចាត់ការទូទៅរបស់ប្រព័ន្ធទូរទស្សន៍កម្ពុជាក៏បានរាយការណ៍ថា ភីតទើហ្សឺ អតីតមន្ត្រីកិច្ចការសាធារណៈរបស់អង្គការសហប្រជាជាតិបានជម្រាបគាត់ថាមិនឲ្យចាក់ផ្សាយខ្សែវីឌីអូដែលថតនៅថ្ងៃនោះតាមបណ្តាញទូរទស្សន៍ឡើយ ។

នៅក្នុងពេលដែល ឌុច បានត្រឡប់មកកាន់គុកទួលស្លែងវិញបុគ្គលិករបស់តុលាការខ្មែរក្រហមបានចេញលិខិតក្រើនរំឭកយ៉ាងច្បាស់ថាអ្នកសារព័ត៌មានអាចនឹងត្រូវដាក់ទណ្ឌកម្មសម្រាប់ការកត់ត្រាកំណត់ហេតុនៃព្រឹត្តិការណ៍សម្ងាត់នេះ ។ ដូចដែលត្រូវបានរាយការណ៍ដោយកាសែតខេមបូឌាដេលី លោកស្រី ហេឡែន ចាវីស ប្រធានកិច្ចការសាធារណៈរបស់តុលាការខ្មែរក្រហមបានព្រមានថា «យោងតាមវិធានផ្ទៃក្នុងរបស់តុលាការជនទាំងឡាយណាទាំងបុគ្គលិករបស់តុលាការដែលបានផ្សព្វផ្សាយព័ត៌មានសម្ងាត់ដោយរំលោភលើបទបញ្ជារបស់តុលាការនឹងត្រូវបានតុលាការអាជ្ញាធរកម្ពុជាឬអង្គការសហប្រជាជាតិដាក់ទណ្ឌកម្ម» ។ កាសែតខេមបូឌាដេលី ក៏បានរាយការណ៍ថា មន្ត្រីតុលាការខ្មែរក្រហមបានព្រមានអ្នកសារព័ត៌មានថាអ្នកសារព័ត៌មានទាំងអស់អាចនឹងត្រូវបានកាត់ទោសសម្រាប់ការរំលោភលើគោលការណ៍សម្ងាត់របស់តុលាការ ។

បទពិសោធន៍របស់អ្នកសារព័ត៌មានក្នុងអំឡុងពេលស៊ើបអង្កេតលើសំណុំរឿង០០១បានជំរុញឲ្យមានការគិតពិចារណាទ្វេដងមុនពេលរាយការណ៍លើប្រធានបទដ៏ចម្រូងចម្រាសរបស់តុលាការ ។ លោក វ៉ុនស៊ុន ប្រូសសែល ប្រធានភ្នាក់ងារសារព័ត៌មានគ្មានព្រំដែនប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកបានបង្ហាញពីក្តីព្រួយបារម្ភដែលលោកចាត់ទុកថាជា «ភាពតានតឹងមួយរវាងអ្នកសារព័ត៌មាននិងមន្ត្រីតុលាការ» ។ ចំណែកឯអ្នកសារព័ត៌មានម្នាក់ទៀតគឺលោក អ៊ីកម៉ាគ្រោ ដែលត្រូវបានប្រាប់ឲ្យចាកចេញពីវាលពិឃាតជើងឯក នៅពេលដែល ឌុច បានធ្វើដំណើរទៅកាន់ទីនោះបានបង្ហាញពីអារម្មណ៍ខកចិត្តក្នុងការដែលគាត់ត្រូវតែពាំនាំយកព័ត៌មានដោយពឹងផ្អែកលើ «ប្រភពព័ត៌មានទីពីរ» ។

ចំណែកនៅក្នុងដំណើរការស៊ើបអង្កេតលើសំណុំរឿង០០២ ដែលធ្វើការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមចំនួនបួនរូបនេះវិញអង្គបុរេជំនុំជម្រះបានចេញលិខិតព្រមានជាច្រើនដែលគូសបញ្ជាក់ថាព័ត៌មានសម្ងាត់ដកស្រង់ចេញពីឯកសាររបស់អង្គបុរេជំនុំជម្រះជាច្រើនត្រូវបានបោះពុម្ពផ្សាយដោយក្រុមអ្នកសារព័ត៌មាន ។ កាលពីខែកក្កដាឆ្នាំ២០១០អង្គបុរេជំនុំជម្រះបានព្រមានថាអត្ថបទរបស់កាសែតខេមបូឌាដេលីចំនួនពីរដែលបានបកស្រាយពីបញ្ហាព្រួយបារម្ភរបស់សាធារណជនពីភាពលម្អៀងផ្នែកនយោបាយនៅឯតុលាការខ្មែរក្រហមបានរំលោភបំពានលើគោលការណ៍ស៊ើបអង្កេតដោយសម្ងាត់របស់ចៅក្រមពីព្រោះថាអង្គបុរេជំនុំជម្រះមិនបានអនុញ្ញាតឲ្យអ្នកសរសេរអត្ថបទនេះទទួលបានព័ត៌មានពាក់ព័ន្ធនឹងបញ្ហានោះទេ ។ ប៉ុន្តែអង្គបុរេជំនុំជម្រះមិនបានបកស្រាយពីមូលហេតុដែលបណ្តាលឲ្យមានការរំលោភបំពានលើគោលការណ៍សម្ងាត់របស់ចៅក្រមទេហើយបានត្រឹមតែចាត់ទុកថាព័ត៌មាននោះគឺជាព័ត៌មានដែលត្រូវបានការពារដែលបានចោទជា «បញ្ហា» ។

កាលពីខែកញ្ញា ឆ្នាំ២០១០អង្គបុរេជំនុំជម្រះបានព្រមានភាគីជាប់ពាក់ព័ន្ធម្តងទៀតពីផលប៉ះពាល់នៃការលេចធ្លាយព័ត៌មានសម្ងាត់ប៉ុន្តែអាក់ខានមិនបានពន្យល់បកស្រាយពីមូលហេតុដែល

ថាអត្ថបទទាំងនោះបានរំលោភបំពានគោលការណ៍សម្ងាត់របស់តុលាការឬថាព័ត៌មានណាដែលត្រូវបានការពារ ។ ដូចគ្នានឹងការព្រមានដែលធ្វើឡើងកាលពីខែកក្កដាឆ្នាំ២០១០អត្ថបទដែលទាក់ទងនឹងការចោទប្រកាន់ពីការជ្រៀតជ្រែកផ្នែកនយោបាយគឺជាប្រធានបទដ៏ចម្រូងចម្រាសមួយនៅឯតុលាការខ្មែរក្រហម ។

យ៉ាងហោចណាស់អត្ថបទមួយក្នុងចំណោមអត្ថបទទាំងអស់នោះបានដកស្រង់សេចក្ដីអះអាងរបស់ក្រុមមេធាវីការពារក្ដីជនជាប់ចោទហើយព័ត៌មាននោះមិនទាន់ត្រូវបានបង្ហាញលើគេហទំព័ររបស់តុលាការខ្មែរក្រហមទេដែលព័ត៌មាននេះបាន «ចោទប្រកាន់រដ្ឋាភិបាលពីបំណងបង្កើត» គោលការណ៍ដែលរៀបចំទុកមុន «ដើម្បីរារាំងដល់ការសួរចម្លើយលើមន្ត្រីរដ្ឋាភិបាល និងការស៊ើបអង្កេតលើអតីតកម្មាភិបាលខ្មែរក្រហមផ្សេងទៀត» ។

កង្វះខាតនូវការទទួលបានព័ត៌មានរបស់អ្នកសារព័ត៌មានកាន់តែមានបញ្ហាច្រើនទាក់ទងនឹងការស៊ើបអង្កេតលើសំណុំរឿង ០០៣ ដែលសហចៅក្រមស៊ើបអង្កេតអាក់ខានមិនបានផ្សព្វផ្សាយព័ត៌មានមុននឹងប្រកាសពីការបញ្ចប់ដំណើរការស៊ើបអង្កេតលើសំណុំរឿងនេះនៅខែមេសា ឆ្នាំ២០១១ ។ ហេតុការណ៍នេះបានរារាំងជនរងគ្រោះមិនឲ្យដាក់ពាក្យស្នើសុំធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណី ។ ជាការឆ្លើយតបនឹងបញ្ហាចោទនេះលោក អេនឌ្រូ ខេលី សហព្រះរាជអាជ្ញាអន្តរជាតិបានចេញសេចក្ដីថ្លែងការណ៍ជាសាធារណៈមួយក្នុងគោលបំណង «ធានាថាសាធារណជនបានដឹងពូពីដំណើរការនីតិវិធីជាបន្តបន្ទាប់របស់តុលាការខ្មែរក្រហម» ។ លោកបានពិភាក្សាពីខ្លឹមសារលម្អិតនៃសំណុំរឿង០០៣ ហើយក៏បានឆ្លុះបង្ហាញនូវភាពជឿជាក់របស់លោកដែលថា «ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងសេចក្ដីសន្និដ្ឋានបឋមមិនទាន់ត្រូវបានស៊ើបអង្កេតឲ្យបានពេញលេញនៅឡើយទេ» ។ សហចៅក្រមស៊ើបអង្កេតបានសម្រេចថាលោកសហព្រះរាជអាជ្ញា អេនឌ្រូ ខេលី បានរំលោភបំពានកាតព្វកិច្ចរក្សាការសម្ងាត់របស់តុលាការដោយបានផ្សព្វផ្សាយព័ត៌មានលម្អិតនៃសំណុំរឿង០០៣ ហើយបានបង្គាប់ឲ្យលោក អេនឌ្រូ ខេលី ធ្វើការកែប្រែព័ត៌មានទាំងអស់នោះវិញ ។

ប៉ុន្មានថ្ងៃក្រោយមកតុលាការខ្មែរក្រហមក៏បានព្រមានដល់អ្នកសារព័ត៌មាននៅពេលដែលអត្ថបទមួយចុះកាលពីខែមិថុនា ឆ្នាំ២០១១ដែលមានចំណងជើងថា «ឯកសារដែលធ្លាយចេញធ្វើឲ្យមានមន្ទិលសង្ស័យលើភាពមិនលម្អៀងរបស់ចៅក្រមនៃតុលាការខ្មែរក្រហម» ត្រូវបានបោះពុម្ពផ្សាយនៅក្នុងកាសែតគ្រីស្ទៀនសៃអ័នម៉ូនីទ័រ ។ ដោយសារតែអត្ថបទនេះបានស្រង់យកឯកសារសម្ងាត់របស់តុលាការចុះកាលពីឆ្នាំ២០០៨ដែល «ចោទសួរពីសមត្ថភាពរបស់តុលាការខ្មែរក្រហមដែលគាំទ្រដោយអង្គការសហប្រជាជាតិក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហម ដោយឯករាជ្យ «នោះអត្ថបទនេះក្លាយជាប្រធានបទដ៏សំខាន់ដែលចោទសួរពីសមត្ថភាពរបស់សហព្រះរាជអាជ្ញាស៊ើបអង្កេតក្នុងការស៊ើបអង្កេតដោយត្រឹមត្រូវមិនលម្អៀង ។ មួយថ្ងៃក្រោយមកទៀតចៅក្រមបានចេញសេចក្ដីប្រកាសមួយទៀតដែលបកស្រាយពី «បុគ្គលិកមិនសុចរិតរបស់តុលាការ» ដែលបានផ្សព្វផ្សាយព័ត៌មាន ។ សេចក្ដីប្រកាសនេះគឺសំដៅវាយប្រហារលើអ្នកសារព័ត៌មានហើយបានព្រមានថា «ជនណាម្នាក់ដែលបានផ្សព្វផ្សាយព័ត៌មានដែលដកស្រង់ចេញពីឯកសារសម្ងាត់របស់តុលាការគឺតម្រូវឲ្យប្រឈមមុខនឹងអង្គនីតិវិធីរបស់តុលាការសម្រាប់ការជ្រៀតជ្រែកការគ្រប់គ្រងលើវិស័យយុត្តិធម៌បើយោងតាមវិធានផ្ទៃក្នុង៣៥របស់តុលាការ» ។ ដោយសារតែដំណើរការដោយគ្មានបទដ្ឋានច្បាស់លាស់និងអាក់ខានមិនបានផ្ដល់មូលហេតុឲ្យបានច្បាស់លាស់ថាឯកសារជាក់លាក់ណាខ្លះដែលបានរំលោភលើគោលការណ៍ការស៊ើបអង្កេតសម្ងាត់នោះតុលាការខ្មែរក្រហមកំពុងតែបោះបង់ចោលការទទួលបានព័ត៌មានរបស់សាធារណជនដើម្បីដើរតាមគោលការណ៍សម្ងាត់របស់ខ្លួន ។ បើទោះបីជាការចោទប្រកាន់ពីបទជ្រៀតជ្រែកផ្នែកនយោបាយបង្កឲ្យមានការចោទសួរពីភាពត្រឹមត្រូវសុចរិតនៃការស៊ើបអង្កេតរបស់ចៅក្រមនិងមន្ត្រីតុលាការក៏ដោយក៏ព័ត៌មានទូទៅដែលទាក់ទងនឹងកោះហៅឲ្យមានការស៊ើបអង្កេតលើបញ្ហាពុករលួយទំនងជាមានឥទ្ធិពលតិចតួចណាស់លើគុណភាពនៃការស៊ើបអង្កេតរបស់ចៅក្រម ។

បន្ថែមលើនេះអ្នកសារព័ត៌មានដែលបានបោះពុម្ពផ្សាយព័ត៌មានសម្ងាត់មិនមានមធ្យោបាយណាមួយក្នុងការដឹងថាប្រភពដែលខ្លួនទទួលបានព័ត៌មាននោះអាចនឹងរំលោភបំពានលើគោលការណ៍ស៊ើបអង្កេតដោយសម្ងាត់ពីព្រោះថាអ្នកសារព័ត៌មានមិនតម្រូវឲ្យ

គោរពតាមបទបញ្ជាការពាររបស់តុលាការនោះទេ ។ ក្រុមអ្នកសារព័ត៌មានបានបង្ហាញពីការអន់ចិត្តដែលខ្លួនត្រូវតែពឹងផ្អែកលើប្រភពព័ត៌មានទីពីរហើយដោយសារតែអំពើពុករលួយដែលល្បីសុសសាយនៅក្នុងប្រព័ន្ធច្បាប់កម្ពុជានៅក្នុងប្រទេសកម្ពុជានោះការពឹងផ្អែកលើមន្ត្រីរដ្ឋាភិបាលដើម្បីធ្វើជាប្រភពព័ត៌មាននឹងប៉ះពាល់ដល់តួនាទីរបស់សារព័ត៌មានក្នុងសមាសភាពជាភ្នាក់ងារអង្កេត ។ ដូច្នេះដំណោះស្រាយដែលបានណែនាំដោយតុលាការខ្មែរក្រហមដែលតម្រូវឲ្យភ្នាក់ងារសារព័ត៌មានធ្វើការពិគ្រោះជាមួយនឹងតុលាការខ្មែរក្រហមដើម្បីធានាថាព័ត៌មាននោះមិនមែនជាព័ត៌មានសម្ងាត់មិនអាចយកជាការបានទេហើយក៏អាចក្លាយជាឧបសគ្គដ៏ធំមួយដល់សេរីភាពរបស់អ្នកសារព័ត៌មាននៅក្នុងប្រទេសកម្ពុជាដែរ ។

បើទោះបីជាតុលាការខ្មែរក្រហមឈរលើគោលជំហរធ្វើជាគំរូសម្រាប់តុលាការជាតិ និងមានគោលបំណងកែប្រែវប្បធម៌ពុករលួយដែលកើតមាននៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏តុលាការខ្មែរក្រហមនេះនៅតែបន្តប្រកាន់ខ្ជាប់នូវគោលការណ៍សន្មតការសម្ងាត់នៅក្នុងអំឡុងដំណើរការស៊ើបអង្កេត ។ ការព្រមានមកលើក្រុមអ្នកសារព័ត៌មានបានក្លាយជាឧបសគ្គមួយដែលមិនឲ្យធ្វើការរាយការណ៍ដល់សាធារណជនប៉ះពាល់ដល់ប្រយោជន៍របស់ប្រជាជនកម្ពុជាក្នុងការទទួលបាននូវព័ត៌មានទាក់ទងនឹងយុត្តិធម៌ និងការផ្សះផ្សា ។ ឧបសគ្គក្នុងការរាយការណ៍ព័ត៌មានរសើបទាំងអស់នេះដូចជាការចោទប្រកាន់ពីភាពលម្អៀងផ្នែកនយោបាយគឺកាន់តែចោទជាបញ្ហាជាងមុនដោយសារតែការគំរាមកំហែងដាក់ទណ្ឌកម្មលើអ្នកសារព័ត៌មានដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់តុលាការខ្មែរក្រហម ។

### ៣) ការដាក់ទណ្ឌកម្មលើមេធាវីនៅឯតុលាការខ្មែរក្រហម ៖ វិធាន៣៨

បើទោះបីជាសហព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេតនិងអង្គបុរេជំនុំជម្រះបានគំរាមដាក់ទណ្ឌកម្មជាច្រើនលើកជាច្រើនសាក៏ដោយ ក៏ការដាក់ទណ្ឌកម្មបែបនេះត្រូវបានអនុវត្តបានតែម្តងគត់ ។ កាលពីខែមីនាឆ្នាំ២០០៩សហចៅក្រមស៊ើបអង្កេតបានដាក់ទណ្ឌកម្មលើមេធាវីការពារក្តីអន្តរជាតិរបស់ អៀង សារី គឺលោក ម៉ៃឃើល ខាណាវ៉ាស ដោយយោងតាមវិធានផ្ទៃក្នុង៣៨របស់តុលាការខ្មែរក្រហមសម្រាប់ការផ្សព្វផ្សាយព័ត៌មានសម្ងាត់នៅលើគេហទំព័ររបស់លោក ។ ចៅក្រមបានបង្គាប់ឲ្យមេធាវីការពារក្តីដកខ្លឹមសារដែលរំលោភបំពានលើវិធានរបស់តុលាការចេញហើយបញ្ឈប់ការផ្សព្វផ្សាយព័ត៌មានឬឯកសារប្រភេទនេះដែលមានជាប់ពាក់ព័ន្ធនឹងការស៊ើបអង្កេតរបស់ចៅក្រមដែលមិនទាន់ត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់តុលាការខ្មែរក្រហមដាច់ខាត ។

ការដាក់ទណ្ឌកម្មលើក្រុមមេធាវីការពារក្តីរបស់ អៀង សារី បានបង្កឲ្យមានមតិរិះគន់យ៉ាងច្រើនពីតុលាការខ្មែរក្រហមពីព្រោះព័ត៌មានដែលបានផ្សព្វផ្សាយនៅលើគេហទំព័រនោះគឺភាគច្រើនពាក់ព័ន្ធនឹងសំណុំរឿងនិងស្ថានភាពសុខភាពទ្រុឌទ្រោមរបស់ អៀង សារី ។ សាធារណជនជាច្រើនបានព្រួយបារម្ភថាមូលហេតុពិតប្រាកដក្នុងការដាក់ទណ្ឌកម្មនេះគឺមិនមែនដើម្បីការពារគោលការណ៍ស៊ើបអង្កេតដោយសម្ងាត់របស់ចៅក្រមទេ ប៉ុន្តែគឺដើម្បីលាក់បាំងនូវភាពទន់ខ្សោយរបស់តុលាការខ្មែរក្រហមទៅវិញទេ ។ សំបុត្រដែលសរសេរដោយក្រុមមេធាវីការពារក្តី អៀង សារី ដើម្បីឆ្លើយតបនឹងការដាក់ទណ្ឌកម្មនេះបានចែងដោយផ្អែកថា ៖

ការអនុវត្តថ្មីៗនេះរបស់ចៅក្រមអង្គជំនុំជម្រះនិងសហចៅក្រមស៊ើបអង្កេតនៅឯតុលាការខ្មែរក្រហមដែលគាបសង្កត់លើការកត់ត្រាព័ត៌មានរបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទដែលអាចជារឿងអាម៉ាស់និងអាចចោទសួរពីភាពត្រឹមត្រូវតាមផ្លូវច្បាប់និងការវិនិច្ឆ័យត្រឹមត្រូវយុត្តិធម៌នៃសេចក្តីសម្រេចរបស់ចៅក្រមដែលទាំងអស់នេះគឺជាវិធានការលាក់បាំងកំហុសឆ្គងដ៏អាម៉ាស់របស់ខ្លួនដែលថាការអនុវត្តបែបនេះគឺជាវិធានការសំខាន់ក្នុងការការពារការសម្ងាត់និងភាពត្រឹមត្រូវសុចរិតរបស់ដំណើរការស៊ើបអង្កេតនិងដំណើរការចេញសេចក្តីសម្រេចតាមផ្លូវច្បាប់ត្រូវតែគ្មានជាប់ពាក់ព័ន្ធនឹងករណីដោយឡែកអ្វីឡើយ ។ ដើម្បីអនុញ្ញាតឲ្យបញ្ហាដែលមិនមានជាប់ពាក់ព័ន្ធនឹងបញ្ហាសម្ងាត់នោះត្រូវបានជជែកដេញដោលជាសាធារណៈបាននោះការអនុវត្តបែបនេះមិនត្រឹមតែដកហូតសិទ្ធិទទួលបាននូវការកាត់ទោសជាសាធារណៈនិងត្រឹមត្រូវយុត្តិធម៌របស់ជនជាប់ចោទ អៀង សារី

ប៉ុណ្ណោះទេ ថែមទាំងដកហូតសិទ្ធិរបស់ប្រទេសកម្ពុជាក្នុងការបង្ហាញពីវិធីសាស្ត្រថា តើអង្គជំនុំជម្រះក្តីពីបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតដ៏ស្មុគស្មាញទាំងអស់នេះអាចនឹងត្រូវបានដំណើរការឡើងដោយបើកចំហនិងដោយតម្លាភាពដោយរបៀបណា ។

សំបុត្ររបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី មិនត្រឹមតែលើកឡើងពីក្តីព្រួយបារម្ភពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានអង្គជំនុំជម្រះក្តីត្រឹមត្រូវយុត្តិធម៌ប៉ុណ្ណោះទេ សំបុត្រនេះក៏បានលើកឡើងនូវក្តីព្រួយបារម្ភជាក់ស្តែងមួយទៀតដែលថា គោលការណ៍សម្ងាត់មិនត្រូវបានប្រើប្រាស់ដើម្បីការពារការស៊ើបអង្កេតលើបញ្ហារសើបទេ ប៉ុន្តែបែរជាការពារកិច្ចការរបស់សហចៅក្រមស៊ើបអង្កេតនិងមន្ត្រីរបស់តុលាការខ្មែរក្រហមឲ្យរួចផុតពីការតាមដានរបស់សាធារណជនទៅវិញទេ ។ វិធានការបែបនេះគឺចោទជាបញ្ហាប្រាកដណាស់ដោយសារតែកង្វះខាតនូវមូលហេតុច្បាស់លាស់ដែលជំរុញឲ្យតុលាការប្រកាន់ខ្ជាប់នូវគោលការណ៍សន្ទតពីការសម្ងាត់ ព្រមទាំងដើម្បីសម្រេចគោលនយោបាយរបស់ខ្លួនក្នុងការធ្វើជាយានដើម្បីការផ្សះផ្សាជាតិនិងគំរូសម្រាប់ប្រព័ន្ធច្បាប់កម្ពុជាតុលាការខ្មែរក្រហមគួរតែបើកចំហដំណើរការនីតិវិធីរបស់ខ្លួនឲ្យសាធារណជនបានដឹងផង ។ ប្រសិនបើក្រុមមេធាវីការពារក្តីបានសម្រេចផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងជនជាប់ចោទ អៀង សារី ឲ្យសាធារណជនបានដឹងនោះវាទំនងជាគ្មានមូលហេតុអ្វីដែលបញ្ជាក់ថាការអនុវត្តបែបនេះគួរតែត្រូវបានហាមឃាត់នោះទេ ហើយចំណែកឯមូលហេតុរបស់សហចៅក្រមស៊ើបអង្កេតក៏មិនត្រូវបានដឹងផងដែរពីព្រោះថាសេចក្តីសម្រេចរបស់ចៅក្រមមានខ្វះខាតនូវហេតុផលច្បាស់លាស់ ។

### ៤) ការដាក់ទណ្ឌកម្មលើជនទាំងឡាយណាដែលជ្រៀតជ្រែកនឹងការគ្រប់គ្រងវិស័យយុត្តិធម៌ ៖ វិធាន៣៥

វិធានផ្ទៃក្នុងមួយរបស់តុលាការខ្មែរក្រហមធ្វើការគ្រប់គ្រងលើការជ្រៀតជ្រែកនឹងការគ្រប់គ្រងលើវិស័យយុត្តិធម៌ ពីព្រោះវិធាននេះត្រូវបានអនុវត្តលើជនទាំងអស់ ។ វិធានផ្ទៃក្នុង៣៥ ចែងដោយផ្នែកថា ១) តុលាការខ្មែរក្រហមអាចនឹងដាក់ទណ្ឌកម្មឬអនុញ្ញាតឲ្យអាជ្ញាធរណាមួយធ្វើការចាត់វិធានការចំពោះជនទាំងឡាយណាដែលជ្រៀតជ្រែកនឹងការគ្រប់គ្រងលើវិស័យយុត្តិធម៌ ដោយដឹងខ្លួននិងដោយចេតនាដែលក្នុងនោះរួមទាំងជនទាំងឡាយណាដែលផ្សព្វផ្សាយព័ត៌មានសម្ងាត់ដែលរំលោភសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតឬចៅក្រមអង្គជំនុំជម្រះ ២) និងទៅលើជនដែលធ្វើការគំរាមកំហែងប្រមាថមើលងាយបង្កគ្រោះថ្នាក់ឬផ្តល់សំណូកឬជ្រៀតជ្រែកសាក្សីឬសាក្សីសំខាន់ណាមួយដែលកំពុងបានផ្តល់ឬអាចផ្តល់ភ័ស្តុតាងនៅក្នុងអង្គនីតិវិធីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតឬចៅក្រមអង្គជំនុំជម្រះ គ្មានអ្នកសារព័ត៌មានណាមួយត្រូវបានដាក់ទណ្ឌកម្មដោយតុលាការខ្មែរក្រហមនោះទេ ប៉ុន្តែប្រសិនបើតុលាការខ្មែរក្រហមពិតជារងការគំរាមកំហែងពីក្រុមអ្នកសារព័ត៌មានមែននោះអ្នកសារព័ត៌មាននឹងត្រូវបានដាក់ទណ្ឌកម្មដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ៣៥(១)(ក) ។

បើទោះបីជាតុលាការខ្មែរក្រហមមិនទាន់បានអនុវត្តការដាក់ទណ្ឌកម្មតាមវិធានផ្ទៃក្នុង៣៥ក៏ដោយ ក៏គោលការណ៍របស់វិធាននេះត្រូវបានយកមកអនុវត្តនៅក្នុងសេចក្តីសម្រេចថ្មីរបស់តុលាការទាក់ទងនឹងការបដិសេធមិនចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការរបស់សាក្សីចំនួនប្រាំមួយនាក់ដែលអ្នកទាំងអស់នេះសុទ្ធតែជាអតីតមន្ត្រីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនិងជាមន្ត្រីរដ្ឋាភិបាលបច្ចុប្បន្ន ។ ស្របពេលដែលសេចក្តីសម្រេចទាំងនេះមានជាប់ពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្មរបស់វិធានផ្ទៃក្នុង៣៥(១)(ឃ) សម្រាប់ការប្រមាថមើលងាយសាក្សី នោះសេចក្តីសម្រេចទាំងអស់នេះក៏បានផ្តល់ជាសេចក្តីណែនាំដ៏មានប្រយោជន៍ទាក់ទងនឹងបទដ្ឋាននៃភ័ស្តុតាងសម្រាប់កិច្ចផ្តួចផ្តើមធ្វើការស៊ើបអង្កេតលើការជ្រៀតជ្រែកនឹងការគ្រប់គ្រងលើវិស័យយុត្តិធម៌ដែលត្រូវបានចោទប្រកាន់ ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនអង្គបុរេជំនុំជម្រះបានពឹងផ្អែកយ៉ាងខ្លាំងលើយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីដែលណែនាំថា ប្រសិនបើតុលាការខ្មែរក្រហមដាក់ទណ្ឌកម្មលើអ្នកសារព័ត៌មានដោយយោងតាមវិធានផ្ទៃក្នុង៣៥ នោះតុលាការខ្មែរក្រហមនឹងឲ្យតម្លៃខ្ពស់ទៅលើសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីស្តីពីបទចោទប្រកាន់ថ្មីទាក់ទងនឹងការប្រមាថមើលងាយតុលាការ ។

កាលពីខែកញ្ញាឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានអនុម័តបទដ្ឋានស្តីពីភ័ស្តុតាងទាំងបីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីដែលមានជាប់ពាក់ព័ន្ធនឹងវិធានផ្ទៃក្នុង៣៥ ដែលត្រូវបានលើកឡើងនៅក្នុងអង្គនីតិវិធីពីបទប្រមាថមើលងាយជាច្រើនប្រឆាំងនឹងអ្នកសារព័ត៌មានដែលមាននៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ ទីមួយ ដើម្បីចាប់ផ្តើមការស៊ើបអង្កេតដោយយោងតាមវិធានផ្ទៃក្នុង៣៥ វាទាមទារឲ្យមានហេតុផលមួយក្នុងការជឿថាជនណាម្នាក់បានជ្រៀតជ្រែកនឹងការគ្រប់គ្រងលើវិស័យយុត្តិធម៌ដែលអង្គបុរេជំនុំជម្រះបានគូសសម្គាល់ថាជា "ចំណុចចាប់ផ្តើមទាបបំផុត" មួយដែលមិនទាមទារឲ្យមានការស៊ើបអង្កេតឲ្យស៊ីជម្រៅទេក្រៅពីការស៊ើបអង្កេតដោយផ្អែកលើមូលដ្ឋានព័ត៌មាន ។ ទីពីរ ដើម្បីចាប់ផ្តើមអង្គជំនុំជម្រះដែលជាប់ទាក់ទងនឹងវិធានផ្ទៃក្នុង៣៥ វាទាមទារឲ្យមានភ័ស្តុតាងគ្រប់គ្រាន់ដោយបង្ហាញឲ្យឃើញពីការជ្រៀតជ្រែកនឹងការគ្រប់គ្រងលើវិស័យយុត្តិធម៌ ។ ចុងក្រោយ មុននឹងអនុវត្តការដាក់ទណ្ឌកម្មលើជនណាម្នាក់សម្រាប់ការរំលោភលើវិធានផ្ទៃក្នុង៣៥ បន្ទុកនៃការបង្ហាញភ័ស្តុតាងត្រូវតែបំពេញទៅតាមបទដ្ឋាន ។

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះមិនត្រឹមតែបង្ហាញឲ្យឃើញពីខ្លឹមសារនៃវិធានផ្ទៃក្នុង៣៥ប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងគូសបង្ហាញឲ្យឃើញពីតម្រូវការចាំបាច់សម្រាប់សេរីភាពនៃសារព័ត៌មានដែលទាក់ទងពីការវិវឌ្ឍន៍ទៅមុខរបស់តុលាការខ្មែរក្រហម ។ បញ្ហាដែលកើតមាននៅក្នុងអង្គនីតិវិធីដែលបណ្តាលឲ្យមានការចេញសេចក្តីសម្រេចកាលពីខែកញ្ញា ឆ្នាំ២០១០ គឺស្តីពីការចោទប្រកាន់ពីការជ្រៀតជ្រែកផ្នែកនយោបាយជួសមុខឲ្យមន្ត្រីរដ្ឋាភិបាលបច្ចុប្បន្នដែលបានជំរុញកុំឲ្យសាក្សីដែលត្រូវបានតុលាការកោះហៅផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ ។ បើទោះបីជាមានការថ្លែងសេចក្តីដោយអ្នកនាំពាក្យរដ្ឋាភិបាលគឺ ឯកឧត្តម ខៀវ កាញារីទ្ធ ដែលថា ខណៈពេលដែលសាក្សីដែលត្រូវបានកោះហៅទាំងប្រាំមួយនាក់នេះ "អាចបង្ហាញខ្លួននៅចំពោះមុខតុលាការដោយស្ម័គ្រចិត្តក៏ដោយ" ក៏គោលជំហររបស់រដ្ឋាភិបាលនៅតែសម្រេចថាសាក្សីទាំងប្រាំមួយនាក់នេះមិនគួរធ្វើសក្ខីកម្មយ៉ាងណាក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតបានបដិសេធសំណូមពរជាច្រើនដែលទាមទារឲ្យមានការស៊ើបអង្កេតនិងការស៊ើបអង្កេតតាមវិធានផ្ទៃក្នុង៣៥ ដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ ។

ក្នុងបណ្តឹងឧទ្ធរណ៍អង្គបុរេជំនុំជម្រះមិនបានចេញសេចក្តីសម្រេចដោយផ្អែកលើសំឡេងសម្លូហភាពថាតើសេចក្តីថ្លែងការណ៍របស់ឯកឧត្តម ខៀវ កាញារីទ្ធ បានជំរុញឲ្យមាន "ហេតុផលដើម្បីជឿ" ថាមានការជ្រៀតជ្រែកនឹងការគ្រប់គ្រងលើវិស័យយុត្តិធម៌ដែលយោងតាមវិធានផ្ទៃក្នុង៣៥ឬយ៉ាងណានោះទេ ។ អង្គបុរេជំនុំជម្រះបានប្រឈមមុខនឹងភាពទាស់ទែងគ្នា ។ ចៅក្រមអន្តរជាតិពីររូបបានអះអាងថា គ្មានព្រឹត្តិការណ៍ណាមួយដែលមិនត្រូវបានពិចារណាថា "ជាហេតុផលមួយដែលត្រូវបានកើតមានឡើងដើម្បីជឿថាមានការជ្រៀតជ្រែកនឹងការគ្រប់គ្រងលើវិស័យយុត្តិធម៌ដែលយោងតាមវិធាន៣៥(១)(ឃ) នោះទេ ។

ផ្ទុយទៅវិញចៅក្រមកម្ពុជាបានគូសសម្គាល់ពីភាពខុសគ្នានៃការប្រើប្រាស់ពាក្យ "មិនគួរ" ដែលឯកឧត្តម ខៀវ កាញារីទ្ធ បានប្រើជាមួយនឹងពាក្យ "ត្រូវតែ" ហើយបានសន្មតថាគ្មានសេចក្តីសម្រេចដាច់ខាតណាមួយត្រូវបានធ្វើឡើងដែលថែងថាជនណាម្នាក់មិនគួរធ្វើសក្ខីកម្មនោះទេ ។ ជាមួយគ្នានេះចៅក្រមកម្ពុជាក៏បានលើកហេតុផលថាសេចក្តីថ្លែងរបស់ឯកឧត្តម ខៀវ កាញារីទ្ធ ត្រូវបានរាយការណ៍ដោយកាសែតភ្នំពេញប៉ុស្តិ៍ដែលជាប្រភពព័ត៌មានដែលមិនគួរទុកចិត្តនិងផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ ។ បន្ថែមលើនេះ ចៅក្រមកម្ពុជាបានយល់ឃើញថាដោយសារតែឯកឧត្តម ខៀវ កាញារីទ្ធ មានមុខតំណែងនិងឋានន្តរស័ក្តិទាបជាងមន្ត្រីទាំងប្រាំមួយរូបដែលតុលាការបានកោះហៅនោះ "បើតាមគោលការណ៍" ឯកឧត្តម ខៀវ កាញារីទ្ធ គ្មានសិទ្ធិអំណាចអ្វីក្នុងការបង្គាប់ឬបង្ខំឲ្យមន្ត្រីជាន់ខ្ពស់ទាំងប្រាំមួយនាក់ធ្វើតាមសេចក្តីសម្រេចនោះទេ ។

ភាពមិនយល់ស្របគ្នារវាងចៅក្រមអង្គបុរេជំនុំជម្រះបង្កជាក្តីព្រួយបារម្ភយ៉ាងខ្លាំងទាក់ទងនឹងការជ្រៀតជ្រែកពីផ្នែកនយោបាយនៅឯតុលាការខ្មែរក្រហមជាពិសេសនៅពេលដែលយើងពិចារណាពីវប្បធម៌ពុករលួយនៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុករបស់កម្ពុជា ។ ជាក់ស្តែងភាពមិនយល់ស្របគ្នារវាងចៅក្រមជាតិនិងអន្តរជាតិនេះដែលតែងតែកើតឡើងជាញឹកញាប់នៅឯតុលាការខ្មែរក្រហមបណ្តាលឲ្យមានភាពមិនចុះសម្រុងគ្នា ហើយក៏បានឆ្លុះ

បញ្ចាំងពីសារៈសំខាន់នៃសេរីភាពសារព័ត៌មានដែលនិយាយពីដំណើរការនីតិវិធីរបស់តុលាការខ្មែរក្រហមក្នុងការសម្រេចគោលដៅរបស់ខ្លួនដើម្បីដើរតួជាគំរូដល់តុលាការកម្ពុជានិងធានាថាដំណើរការនីតិវិធីរបស់តុលាការខ្មែរក្រហមជាដំណើរការមួយដែលប្រកបដោយយុត្តិធម៌និងផ្អែកលើច្បាប់ ។ ប្រសិនបើគ្មានការតាមដានពីមជ្ឈដ្ឋានសាធារណៈទេនោះតុលាការខ្មែរក្រហមនឹងសម្រេចបាននូវការទទួលខុសត្រូវដ៏ពេញលេញមួយ នៅក្នុងដំណាក់កាលដ៏សំខាន់នេះទេហើយប្រជាជនកម្ពុជានឹងត្រូវបានដកហូតសិទ្ធិទទួលបានព័ត៌មានសំខាន់នៅក្នុងអំឡុងពេលដំណើរការស៊ើបអង្កេតសម្ងាត់ដែលត្រូវបានពន្យារពេលជាច្រើនខែកន្លងមកហើយដែរ ។

បើទោះបីជាអង្គបុរេជំនុំជម្រះបានបង្កើតលក្ខន្តិកស្ដីពីដំណើរការនីតិវិធីខ្លះៗទាក់ទងនឹងវិធានផ្ទៃក្នុង៣៥ក៏ដោយក៏អង្គបុរេជំនុំជម្រះមិនទាន់បានអនុវត្តបទដ្ឋានទាំងនោះសម្រាប់ការចោទប្រកាន់ពីការជ្រៀតជ្រែករបស់សារព័ត៌មានលើការគ្រប់គ្រងលើវិស័យយុត្តិធម៌ដែរ ។បើដាក់ទណ្ឌកម្មលើអ្នកសារព័ត៌មាននោះសហចៅក្រមស៊ើបអង្កេតនិងចៅក្រមអង្គបុរេជំនុំជម្រះអាចនឹងពឹងផ្អែកលើយុត្តិសាស្ត្រថ្មីៗរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីទាក់ទងនឹងរឿងក្ដីពីបទប្រមាថមើលងាយដោយសារតែច្បាប់ក្នុងស្រុកកម្ពុជាមិនមានបទបញ្ញត្តិស្រដៀងគ្នានេះដើម្បីដាក់ទណ្ឌកម្មលើអ្នកសារព័ត៌មានឡើយ ។ រឿងក្ដីថ្មីៗនេះរវាងព្រះរាជអាជ្ញានិង ហាម៉ាន់ អាចនឹងមានឥទ្ធិពលខ្លាំងសម្រាប់សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះហើយវាគឺជារឿងក្ដីដែលទាក់ទងពីបទប្រមាថមើលងាយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីក្នុងការធ្វើឲ្យមានតុល្យភាពរវាងបទបញ្ញាស្ដីពីការសម្ងាត់និងសេរីភាពក្នុងការបញ្ចេញមតិ ។

### ៣) បទប្រមាថមើលងាយនៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីៈការរំលោភបំពានដោយចេតនាលើដីការការពារ

ខុសពីតុលាការខ្មែរក្រហមតែដូចគ្នានឹងតុលាការអន្តរជាតិផ្សេងទៀតតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដំណើរការទៅដោយអនុវត្តតាមវិធាននីតិវិធីបែបអេតវីសារៀល ហើយយុត្តិសាស្ត្រស្ដីពីបទប្រមាថមើលងាយរបស់ខ្លួនគឺផ្អែកលើការរំលោភបំពានលើដីកាការពារដែលកើតមានឡើងនៅក្នុងអំឡុងដំណើរការនីតិវិធីរបស់តុលាការ ។ យ៉ាងណាមិញតុលាការខ្មែរក្រហមធ្វើការពឹងផ្អែកទាំងស្រុងលើយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីហើយដំណើរការនីតិវិធីស្ដីពីបទប្រមាថមើលងាយរបស់តុលាការនេះអាចនឹងជះឥទ្ធិពលខ្លាំងប្រសិនបើតុលាការខ្មែរក្រហមសម្រេចដាក់ទណ្ឌកម្ម ដោយយោងតាមវិធានផ្ទៃក្នុង៣៥ ។

ផ្នែក “ក” បកស្រាយពីខ្លឹមសារនៃព័ត៌មានដែលត្រូវបានការពារនៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ ចំណែកឯផ្នែក “ខ” វិញធ្វើការសង្ខេបពីបទដ្ឋានច្បាប់បច្ចុប្បន្ន ។ ផ្នែក “គ” វិភាគលើរឿងក្ដីរវាងព្រះរាជអាជ្ញានិងហាម៉ាន់ដែលស្ដីពីបទប្រមាថមើលងាយនៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីហើយសន្និដ្ឋានបញ្ចប់ដោយបង្ហាប់ថារឿងក្ដីរបស់ហាម៉ាន់គួរតែមានឥទ្ធិពលតិចលើអង្គនីតិវិធីរបស់តុលាការខ្មែរក្រហម ។ ***(នៅមានត)***

**គ្រីស្ដា ណោលសាន់**

## ដំណឹងស្វែងរកញាតិ

នាងខ្ញុំឈ្មោះ លីម ភានុវណ្ណរង្សីសីហៈ រស់នៅសង្កាត់សន្សំកុសល ខណ្ឌមានជ័យ ក្រុងភ្នំពេញ សូមប្រកាសរកពូឈ្មោះ ហាក់ អុល មកដល់បច្ចុប្បន្នមានអាយុ៧២ឆ្នាំ ។ កាលពីសម័យ លន់ នល់ ពូរបស់នាងខ្ញុំមានផ្ទះនៅទួលគោក ហើយគាត់ធ្វើជាប៉េអឹម ។ គាត់បានបែកពីគ្រួសារនៅម្ដុំវត្តលង្កា ពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីក្រុងឆ្នាំ១៩៧៥ ។ ចាប់តាំងពីពេលនោះមក គ្រួសារនាងខ្ញុំបាត់ដំណឹងគាត់រហូត ។

ប្រសិនបើ បងប្អូនណាបានដឹង ឬស្គាល់ឈ្មោះពូរបស់នាងខ្ញុំ សូមមេត្តាទាក់ទងមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ : ០១៥ ៥៥៥ ០០៧ ឬ ០១២ ៩៩៦ ៧៥០ ឬ មជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈអាសយដ្ឋាន ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ខណ្ឌចំការមន ក្រុងភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ **សូមអរគុណ!**



# ប្រាសាទព្រះវិហារ : ទីគោរពសក្ការៈ

ប្រាសាទព្រះវិហារដែលប្រជាជនថៃហៅថា“ខាវជ្រះវិហាន” មានទីតាំងស្ថិតនៅលើកំពូលភ្នំដងរែកតាមបណ្តោយព្រំដែនកម្ពុជា និងថៃ លាតសន្ធឹងពីអក្សជើងទៅត្បូង ។ ប្រាសាទនេះលាតសន្ធឹងចាប់តាំងពីជើងភ្នំក្បែរខ្ពង់រាបនៃប្រទេសថៃរហូតដល់កំពូលភ្នំជិតច្រាំងចោទដ៏ខ្ពស់ក្បែររូងភ្នំមួយមានឈ្មោះថា “រូងលោកតាឌី” ។ ពីទឹកដីប្រទេសកម្ពុជា ដើម្បីទៅដល់កំពូលប្រាសាទ ត្រូវឆ្លងកាត់ផ្លូវតាមជម្រាលដ៏ចោទ តែពីទឹកដីប្រទេសថៃវិញ ការធ្វើដំណើរមកប្រាសាទត្រូវធ្វើដំណើរតាមខ្ពង់រាបខូរ៉ាតដែលមានលក្ខណៈងាយស្រួលជាងពីខាងទឹកដីកម្ពុជា ។

ប្រទេសថៃ និងប្រទេសកម្ពុជាបានក្លាយជាម្ចាស់កម្មសិទ្ធិប្រាសាទព្រះវិហារនេះម្តងម្នាក់ ប៉ុន្តែរហូតមកដល់ឆ្នាំ១៩៦២ តុលាការយុត្តិធម៌អន្តរជាតិបានសម្រេចថា ប្រាសាទព្រះវិហារមានទីតាំងស្របច្បាប់នៅលើទឹកដីរបស់ប្រទេសកម្ពុជា ។ យ៉ាងណាមិញ ដោយសារតែសេចក្តីសម្រេចរបស់តុលាការយុត្តិធម៌នោះមិនបានបញ្ជាក់ពីតំបន់៤.៦គីឡូម៉ែត្រការ៉េជុំវិញប្រាសាទព្រះវិហារ ប្រទេសថៃ និងប្រទេសកម្ពុជា នៅតែបន្តអះអាងតំបន់នេះជាកម្មសិទ្ធិរបស់ខ្លួនរហូតមក ។ តំបន់៤.៦គីឡូម៉ែត្រការ៉េនេះហើយជាឫសគល់នៃជម្លោះ រវាងប្រទេសទាំងពីរទាក់ទងទៅនិងប្រាសាទព្រះវិហារ



រហូតមកដល់សព្វថ្ងៃនេះ ។ បើទោះបីជាដីមួយផ្នែកនេះត្រូវបានប្រទេសថៃចាត់ទុកថាជាតំបន់ជម្លោះក៏ដោយ តែប្រទេសកម្ពុជាបានរក្សាជំហរជាដរាបថា តំបន់៤.៦គីឡូម៉ែត្រការ៉េនេះគឺជាកម្មសិទ្ធិរបស់ខ្លួនជាយូរណាស់មកហើយ ពោលគឺមុននិងការកើតមានជម្លោះថ្មីៗនេះទៅទៀត ។ ពីទឹកដីប្រទេសកម្ពុជា ផ្លូវចម្បងដែលអាចធ្វើដំណើរទៅដល់ប្រាសាទព្រះវិហារបានគឺត្រូវឆ្លងកាត់តំបន់៤.៦គីឡូម៉ែត្រការ៉េនេះ ។

ប្រាសាទព្រះវិហារគឺជាទីកន្លែងដ៏សំខាន់មួយសម្រាប់ប្រជាជនថៃ និងប្រជាជនកម្ពុជា ។ មុននិងជម្លោះកើតមានឡើងក្នុងឆ្នាំ២០០៨ ប្រទេសទាំងពីរធ្លាប់ទទួលបានផលចំណេញផ្នែកសេដ្ឋកិច្ចយ៉ាងច្រើនពីវិស័យទេសចរណ៍ តាមរយៈភ្ញៀវមកទស្សនាប្រាសាទនេះ ។ ប្រាសាទព្រះវិហារធ្លាប់ជាទីតាំងប្រណិបត្តិសាសនា និងទីសក្ការបូជាមួយកន្លែងសម្រាប់ប្រទេសទាំងពីរ ដោយសារប្រទេសទាំងពីរមានវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី និងជំនឿផ្នែកសាសនាប្រហាក់ប្រហែលគ្នា ។ ប្រជាជនខ្មែរនិងថៃបានឲ្យតម្លៃប្រាសាទព្រះវិហារ និងតំបន់ជុំវិញប្រាសាទដោយសារសម្រស់ប្រវត្តិសាស្ត្រ និងស្ថាបត្យកម្មរបស់ប្រាសាទនេះ ។

រដ្ឋាភិបាលកម្ពុជា និងថៃបានយល់ស្របគ្នាថា ប្រាសាទព្រះវិហារមាន “តម្លៃដ៏ពិសិដ្ឋនៅលើសកលលោក” ហើយប្រាសាទនេះគួរតែត្រូវបានបញ្ចូលជាបេតិកភណ្ឌពិភពលោក ។ ប៉ុន្តែ ជម្លោះនយោបាយផ្ទៃក្នុងដោយសារតែក្រុមជាតិនិយមនៅប្រទេសថៃបានជម្រុញឲ្យរដ្ឋាភិបាលថៃកែប្រែទស្សនៈគាំទ្ររបស់ខ្លួនចំពោះការចុះបញ្ជីជាបេតិកភណ្ឌពិភពលោកនេះ ។ ទោះជាយ៉ាងនេះក្តី រដ្ឋាភិបាលកម្ពុជានៅតែបន្តដំណើរការស្នើសុំដាក់ប្រាសាទនេះជាបេតិកភណ្ឌពិភពលោកជានិច្ច ។ ទីបំផុតប្រាសាទព្រះវិហារត្រូវបានចុះបញ្ជីជាបេតិកភណ្ឌពិភពលោកនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៨ ដោយអង្គការសហប្រជាជាតិ ទទួលបន្ទុកកិច្ចការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌(យូនីស្កូ) ។ ការបញ្ចូលប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោកនេះបណ្តាលឲ្យមានការមិនពេញចិត្ត និងកំហឹងជាតិនិយមពីសំណាក់ប្រទេសថៃ ប៉ុន្តែប្រជាជនកម្ពុជាបានសម្តែងនូវមោទកភាពយ៉ាងខ្លាំង ។ ទីបំផុត គំនិតជាតិនិយមបានកើតឡើងទាក់ទងទៅនិងប្រាសាទព្រះវិហារនេះ ។

## ប្រវត្តិប្រាសាទព្រះវិហារ

ប្រាសាទព្រះវិហារមិនត្រូវបានសាងសង់ឡើក្នុងរយៈពេលជាក់លាក់ណាមួយដោយឯកឯងនោះទេ ។ ការសាងសង់ប្រាសាទនេះបានចាប់ផ្តើមនៅដើមសតវត្សរ៍ទី៩ក្នុងអំឡុងដំណាក់កាលដំបូងនៃសម័យអង្គរ ។ ព្រះមហាក្សត្រខ្មែរសម័យក្រោយៗមកទៀតបានបន្តគោរពបូជាផ្នែកសាសនានៅប្រាសាទព្រះវិហារនេះជាដរាប ។ ពីរជ្ជកាលមួយទៅរជ្ជកាលមួយមានការសាងសង់ប្រាសាទតូចៗជាច្រើនទៀតនៅលើភ្នំនេះ ហើយសំណង់ចុងក្រោយនៅលើប្រាសាទព្រះវិហារនេះត្រូវបានសង់ឡើងក្នុងសតវត្សរ៍ទី១២ក្នុងរជ្ជកាល

ព្រះបាទសូរ្យវរ្ម័នទី២ ដែលជាក្សត្រស្ថាបនិកប្រាសាទអង្គរវត្ត ។

អាណាចក្រខ្មែរបានធ្លាក់ចុះឥទ្ធិពលបន្តិចម្តង១ចាប់ពីសតវត្សរ៍ទី១៥មកមួយផ្នែកដោយសារការវាតត្បាតពីសំណាក់រដ្ឋជិតខាងជាពិសេស ចម្ប៉ា និង សៀម (សព្វថ្ងៃប្រទេសថៃ) ។ ចាប់តាំងពីពេលនោះមក រាជធានីរបស់ប្រទេសនិងរាជវាំងបានផ្លាស់ប្តូរជាញឹកញាប់រហូតដល់ទីបំផុតរាជធានីត្រូវបានជ្រើសរើសយកទីតាំងទន្លេបួនមុខដែលសព្វថ្ងៃមានឈ្មោះថា "ភ្នំពេញ" ។ សៀមបានគ្រប់គ្រងទឹកដីអាណាចក្រខ្មែរមួយផ្នែកនៅភាគខាងលិច ហើយបានបន្តវាយលុកបន្តទៀត ។ មកដល់សតវត្សរ៍ទី១៨ សៀម

ព្រមព្រៀងលើការកំណត់ព្រំដែនដោយចែងថា ខ្សែបន្ទាត់ព្រំដែនរបស់ប្រទេសទាំងពីរនឹងរត់នៅតាមបណ្តោយខ្សែទឹករបស់ជួរភ្នំដងរែក ។ បើអនុឡោមតាមតាមការកំណត់ព្រំដែននេះ ប្រាសាទព្រះវិហារគឺឋិតនៅក្នុងទឹកដីរបស់ប្រទេសថៃ ។

អនុសញ្ញានៃកិច្ចព្រមព្រៀងនេះបានបង្កើតជាគណៈកម្មាធិការរួមមួយរវាងប្រទេសបារាំង និងសៀម ដើម្បីបំពេញកិច្ចការកំណត់ខ្សែបន្ទាត់ព្រំដែន ។ គណៈកម្មាធិការរួមនេះបានវាស់ស្ទង់និងវាស់វែងសព្រំដែនក្បែរប្រាសាទព្រះវិហារ ។ នៅឆ្នាំ១៩០៧ បារាំងបានបង្កើតផែនទីមួយដោយកំណត់ថា ប្រាសាទព្រះវិហារ



ទីតាំងដែលយោធាថៃមកបោះទីតាំងកាលពីឆ្នាំ២០០៨ ។ សព្វថ្ងៃទីតាំងនេះមានចំណារលើថ្មជាច្រើនដែលត្រូវបានសរសេរឡើងដើម្បីទប់ស្កាត់ការឈ្លានពានពីសំណាក់យោធាបរទេស



ច្រកចូលប្រាសាទព្រះវិហារក្រោយពីព្រំដែនប្រទេ
សរសេរថា "យើងទាំងអស់គ្នាប្តេជ្ញាការ

បានគ្រប់គ្រងខេត្តមួយចំនួនរបស់ប្រទេសកម្ពុជាដូចជាខេត្តបាត់ដំបង សៀមរាប ស៊ីសុផុន រួមបញ្ចូលទាំងប្រាសាទព្រះវិហារផង ។

ក្នុងអំឡុងពេលសៀមគ្រប់គ្រងប្រាសាទព្រះវិហារ មិនមានការកត់ត្រាជាលាយលក្ខណ៍អក្សរច្រើនប៉ុន្មានទេ ។ នៅឆ្នាំ១៨៨៣ ព្រះមហាក្សត្រខ្មែរដែលកាលនោះប្រទេសមានភាពទន់ខ្សោយទៅហើយនោះ បានស្នើសុំឲ្យប្រទេសបារាំងធ្វើជាអាណាព្យាបាលដោយសារតែក្តីព្រួយបារម្ភពីបំណងចង់ក្តោបក្តាប់ប្រទេសកម្ពុជាពីសំណាក់សៀម ។

នៅឆ្នាំ១៩០៤ ប្រទេសបារាំង និងប្រទេសសៀមបាន

មានទីតាំងនៅលើទឹកដីប្រទេសកម្ពុជា ។ ខណៈពេលនោះ សៀមមិនបានយល់ព្រមទៅនិងផែនទីដែលបារាំងបានគូរដោយគណៈកម្មាធិការរួមនេះទេ ប៉ុន្តែសៀមមិនមានអំណះអំណាងច្បាស់លាស់ណាមួយដើម្បីច្រានចោលផែនទីរួមនេះដែរ ។ ចាប់តាំងពីគ្មានការប្រឆាំងតវ៉ាអ្វីបន្តទៀតពីសំណាក់សៀម ស្របជាមួយគ្នានោះដែរ ប្រទេសសៀមក៏ហាក់បីដូចជាទទួលស្គាល់ថា ប្រាសាទព្រះវិហារគឺជាកម្មសិទ្ធិរបស់ប្រទេសបារាំងដែរ ។ នៅដើមឆ្នាំ១៩២៩ ព្រះរាជបុត្រាមួយអង្គរបស់សៀមព្រះនាម ដាមរ៉ុង រ៉ាចាណូផាត បានធ្វើដំណើរមកទស្សនកិច្ចប្រាសាទព្រះវិហារដោយកាលនោះ ព្រះអង្គត្រូវ

បានទទួលបានការស្វាគមន៍ពីសំណាក់មន្ត្រីបារាំងជាន់ខ្ពស់ពីររូប ។ ជាមួយគ្នានោះដែរ ព្រះរាជបុត្រាសៀមបានទតឃើញទង់ជាតិរបស់បារាំងកំពុងបក់រវិកៗ នៅលើកំពូលភ្នំព្រះវិហារដែលតំណាងថា ប្រាសាទនេះជាកម្មសិទ្ធិរបស់ប្រទេសបារាំងដែលជាអាណាព្យាបាលរបស់កម្ពុជា ។

ទោះជាយ៉ាងណា ជម្លោះទាក់ទងទៅកម្មសិទ្ធិប្រាសាទព្រះវិញនេះនៅតែកើតមានដដែល ។ នៅពេលដែលប្រទេសបារាំងដកអាណានិគមរបស់ខ្លួនពីប្រទេសកម្ពុជាជាបណ្ដោះអាសន្ននៅដើមទសវត្សរ៍៤០ ប្រទេសជប៉ុនបានមកគ្រប់គ្រងប្រទេសកម្ពុជា ហើយបានអនុញ្ញាតឲ្យប្រទេសសៀមគ្រប់គ្រងប្រាសាទព្រះវិហារនោះម្ដងទៀត ។ នៅពេលដែលប្រទេសជប៉ុនទទួលបរាជ័យ បារាំងបានវិលត្រឡប់មកកម្ពុជាវិញ ហើយពេលនោះកម្ពុជាបានធ្វើជាម្ចាស់កម្មសិទ្ធិលើប្រាសាទព្រះវិហារវិញម្ដង ។

នៅឆ្នាំ១៩៥៣ ប្រទេសកម្ពុជាទទួលទានឯករាជ្យពីប្រទេសបារាំង ។ មួយឆ្នាំក្រោយមក កងទ័ពថៃបានវាយលុក ហើយកាន់កាប់ប្រាសាទព្រះវិហារ ។ នៅឆ្នាំ១៩៥៩ ប្រទេសកម្ពុជាបានដាក់ពាក្យបណ្ដឹងទៅតុលាការយុត្តិធម៌អន្តរជាតិដើម្បីទាមទាកម្មសិទ្ធិប្រាសាទព្រះវិហារនេះមកវិញ ។ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២ តុលាការយុត្តិធម៌អន្តរជាតិបានចេញសេចក្ដីសម្រេចថា"...ប្រាសាទព្រះវិហារស្ថិតមានទីតាំងឋិតក្នុងបូរណភាពដែនដីរបស់ប្រទេសកម្ពុជា" ។

## ភូមិពីរក្នុងទីតាំងមួយ

ប្រទេសថៃនិងកម្ពុជាអះអាងថា ប្រាសាទព្រះវិហារមានទីតាំងនៅលើទឹកដីរបស់ខ្លួន ។ នៅប្រទេសថៃ ប្រាសាទព្រះវិហារមានទីតាំងនៅក្នុងភូមិប៉ុមស្រុល ឃុំបឹងម៉ាឡូ ស្រុកខានថារ៉ាឡាក់ ខេត្តស៊ីសាកេត ។ ចំណែកនៅខាងប្រទេសកម្ពុជាវិញ ប្រាសាទព្រះវិហារមានទីតាំងនៅក្នុងភូមិស្វាយជ្រុំ ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ។



...ទេសថៃ នៅក្បែរជ្រោងទ្វារនេះមានផ្លាកតូចមួយដែល ...ពារប្រាសាទព្រះវិហារឲ្យបានស្ថិតស្ថេរ"


ទាហានកម្ពុជាម្នាក់កំពុងឈាមល្បាតដោយចាំឃ្លាំមើលសកម្មភាព...តាមបណ្ដោយព្រំដែនថៃ

## ការគោរពសក្ការបូជារួម

ប្រាសាទព្រះវិហារគឺជាសហគមន៍រួមដ៏ធំនិងមានតម្លៃជាប្រវត្តិសាស្ត្រមួយរបស់ប្រជាជនថៃ និងប្រជាជនកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ ប្រាសាទនេះត្រូវបានចាត់ទុកជាមជ្ឈមណ្ឌលសាសនា ពាណិជ្ជកម្ម និងជាសហគមន៍សេដ្ឋកិច្ចមួយរបស់ប្រទេសទាំងពីរ ។ ប្រាសាទនេះក៏គឺជាទីកន្លែងប្រារព្ធពិធីសាសនារួមមួយរវាងប្រទេសកម្ពុជា និងថៃ ។ នៅឆ្នាំ១៩៦៣ មួយឆ្នាំក្រោយពេលតុលាការយុត្តិធម៌អន្តរជាតិសម្រេចថា

ប្រាសាទព្រះវិហារជាកម្មសិទ្ធិរបស់ប្រទេសកម្ពុជា សម្តេច សីហនុ បានរៀបចំប្រារព្ធពិធីសាសនាមួយនៅលើកំពូលភ្នំនេះដើម្បីអបអរសាទរទៅនឹងសេចក្តីសម្រេចនេះ ។ នាពេលនោះ ព្រះអង្គបានលើកទឹកចិត្តឲ្យប្រជាជនថៃមកទស្សនាប្រាសាទព្រះវិហារនេះដោយមិនចាំបាច់សុំទិដ្ឋាការ ហើយព្រះអង្គក៏បានចេញអនុក្រិត្យដែរថា ប្រទេសថៃអាចរក្សាទុករាល់វត្ថុបុរាណ និងបដិមាដែលប្រទេសថៃបានយកចេញពីប្រាសាទនេះក្នុងអំឡុងរជ្ជកាលគ្រប់គ្រងរបស់ខ្លួននៅក្នុងប្រទេសថៃបន្តទៀត បើទោះបីជាតុលាការយុត្តិធម៌អន្តរជាតិបានសម្រេចថារាល់វត្ថុបុរាណទាំងអស់ដែលថៃយកចេញពីប្រាសាទនេះត្រូវតែប្រគល់មកឲ្យប្រទេសកម្ពុជាវិញក៏ដោយ ។

ក្នុងអំឡុងពេលមួយទសវត្សរ៍ចុងក្រោយនេះ ច្រកទ្វារព្រំដែនរវាងប្រទេសទាំងពីរត្រូវបានបិទជាញឹកញាប់ ។ ប៉ុន្តែ ប្រជាជនខ្មែរនិងថៃបានព្រមព្រៀងថា ប្រាសាទព្រះវិហារនេះមានតម្លៃខាងសាសនានិងជាកន្លែងសក្តិសិទ្ធដែលមានទីតាំងនៅលើភ្នំសក្តិសិទ្ធមួយ ។ នៅពេលដែលច្រកទ្វារព្រំដែនបានបើកនៅដើមឆ្នាំ២០០០ ប្រជាជនថៃជាច្រើននាក់បានមកទស្សនាប្រាសាទព្រះវិហារច្រើនជាងប្រជាជនកម្ពុជា ។ ជាក់ស្តែង ប្រាសាទព្រះវិហារបានធ្វើឲ្យដាច់ឆ្ងាយពីតំបន់ផ្សេងទៀតនៅក្នុងប្រទេសកម្ពុជាដោយសារតែបញ្ហាផ្លូវមិនបានផ្តល់ភាពងាយស្រួលនិងដោយសារបញ្ហាគ្រាប់មីន ។ ប្រជាជនកម្ពុជាដែលធ្លាប់រស់នៅប្រាសាទព្រះវិហារកាលពីពេលព្រំដែននៅបើកបានឲ្យដឹងថា ប្រជាជនខ្មែរនិងថៃមកទស្សនាប្រាសាទព្រះវិហារដើម្បីបួងសួង បន់ស្រន់ និងប្រារព្ធពិធីសាសនានៅប្រាសាទនេះដូចគ្នា ។ នគរបាលខ្មែរមួយចំនួនដែលប្រចាំការនៅប្រាសាទព្រះវិហារអស់រយៈពេលជាងដប់ឆ្នាំមកហើយនោះបាននិយាយថា «ប្រជាជនថៃចាស់ៗបានអង្គុយសំពះខ្លោងទ្វារមុខប្រាសាទមុននិងចូលក្នុងបរិវេណប្រាសាទ ។ ចំណែកឯប្រជាជនថៃ ក្មេងៗខ្លះបានសំពះខ្លោងទ្វារប្រាសាទមុននិងដើរចូលទៅក្នុងប្រាសាទ ។

ប្រជាជនថៃដែលរស់នៅជិតប្រាសាទព្រះវិហារបានចាត់ទុកប្រាសាទនេះជាទីតាំងប្រណិបត្តិសាសនាដ៏សំខាន់មួយ ។ អ្នកភូមិខ្លះបាននិយាយថា គាត់ធ្លាប់ទៅបែបន់នៅលើប្រាសាទព្រះវិហារនេះមុននឹងទ្វារព្រំដែនត្រូវបានបិទ ។ អ្នកភូមិម្នាក់ឈ្មោះ អាភីរ៉ាត់ ស៊ូកាផាត់តាណា អាយុ៥៧ឆ្នាំបាននិយាយថា នៅពេលដែលច្រកព្រំដែនបើក គាត់តែងតែមកលេងប្រាសាទព្រះវិហារជាញឹកញាប់ «ខ្ញុំបានទៅអុជធូប បែរបន់នៅទីនោះពីព្រោះខ្ញុំដឹងថាប្រាសាទនេះគឺជាទីសក្ការបូជាមួយតាមបែបពុទ្ធសាសនា ។» ស៊ុម៉ាលី ណាំវង្ស បានទៅលេងប្រាសាទព្រះវិហារជាមួយនឹងឪពុកម្តាយរបស់គាត់កាលពីទសវត្សរ៍៦០ ដោយសារប្រាសាទនោះមានទីតាំងនៅក្បែរភូមិរបស់គាត់ ។ គាត់ធ្លាប់មកប្រាសាទព្រះវិហារជាច្រើនលើកទៀតកាលពីជាងដប់ឆ្នាំមុន ។ ពេលនេះគាត់ចង់ទៅមើលប្រាសាទនេះម្តងទៀត ដូចកាលពីលើកមុន «តាមពិតទៅប្រាសាទនេះមានទីតាំងនៅក្បែរកន្លែងដែលយើងរស់នៅ ប៉ុន្តែឥឡូវនេះវាហាក់បីដូចជាឆ្ងាយណាស់» ។ ស៊ុម៉ាលី មិនបានទៅទស្សនាប្រាសាទព្រះវិហារម្តងទៀតទេ ក្រោយពេលដែលច្រកព្រំដែនត្រូវបានបិទ ។

## ជាតិនិយមចំពោះប្រាសាទព្រះវិហារ

ស្មារតីជាតិនិយមមកលើប្រាសាទព្រះវិហាររបស់ប្រជាជនកម្ពុជានិងថៃមានសន្ទុះខ្លាំងដូចគ្នា ។ ប៉ុន្តែ អត្ថន័យនៃស្មារតីជាតិនិយមនោះហាក់បីដូចជាមានលក្ខណៈខុសគ្នា ។ សម្រាប់ប្រទេសថៃ ជម្លោះដោយសារប្រាសាទព្រះវិហារទំនងជាមានលក្ខណៈនយោបាយច្រើន ។ ប៉ុន្តែ សម្រាប់ប្រទេសកម្ពុជាវិញ ជម្លោះប្រាសាទនេះហាក់បីដូចជាទាក់ទងទៅនឹងបញ្ហាកម្មសិទ្ធិផ្ទៃដីនៅបរិវេណវត្តកែវសិក្ខាគីរីស្វារៈច្រើនជាង ។ ជម្លោះទាក់ទងនឹងប្រាសាទនេះជំរុញឲ្យមានស្មារតីជាតិនិយមខ្ពស់ក្នុងការការពារបូរណភាពដែនដី ។ មានន័យថា ប្រជាជនកម្ពុជាដែលធ្លាប់បាត់បង់ទឹកដីទៅឲ្យប្រទេសថៃកាលពីអតីតកាល ពេលនេះបានប្តេជ្ញាចិត្តការពារមិនឲ្យមានការឈ្លានពានផ្នែកយោធាណាមួយទៀតឡើង ។ ការប្តេជ្ញាចិត្តក្នុងការការពារបូរណភាពដែនដីនេះបានជួយឲ្យប្រជាជនកម្ពុជាមានការផ្សះផ្សារមួយទូទាំងប្រទេស ។

## ស្មារតីជាតិនិយមខ្មែរជំរុញឲ្យមានការការពារនិងការផ្សះផ្សារ

ការដាក់បញ្ចូលប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោកនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៨ គឺជាមោទកភាពដ៏ធំធេងមួយសម្រាប់ប្រទេសកម្ពុជាទាំងមូល ។ រដ្ឋាភិបាលកម្ពុជាមានមោទកភាពយ៉ាងខ្លាំងចំពោះជោគជ័យដែលខ្លួនបានប្រឹងប្រែង

អស់រយៈពេលជាច្រើនឆ្នាំ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានចេញលិខិតមួយដើម្បីអបអរសាទរពីភាពជោគជ័យនេះហើយប្រជាជនកម្ពុជាក៏ស្វាគមន៍យ៉ាងរីករាយ ទៅនឹងការដាក់បញ្ចូលនេះដែរ ។ គណៈប្រតិភូកម្ពុជាដែលដឹកនាំដោយឧបនាយករដ្ឋមន្ត្រី សុខ អាន ត្រូវបានទទួលស្វាគមន៍យ៉ាងកក់ក្ដៅនៅឯអាកាសយានដ្ឋាន ខណៈពេលដែលគណៈប្រតិភូទាំងនោះវិលត្រឡប់ពីកិច្ចប្រជុំនៅប្រទេសកាណាដា ដែលជាកន្លែងដែលប្រាសាទព្រះវិហារត្រូវបានចុះជាបេតិកភណ្ឌពិភពលោក ។ ទូរទស្សន៍ក្នុងស្រុកបានចាក់ផ្សាយផ្ទាល់ទូទាំងប្រទេសចំពោះការវិលត្រឡប់មកវិញរបស់គណៈប្រតិភូខ្មែរនេះ ។ ដើម្បីអបអរសាទរទៅនិងការដាក់បញ្ចូលប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោកព្រះសង្ឃបានវាយស្គរបន្លឺសម្លេងនៅតាមវត្តអារ៉ាមនានាក្នុងរាជធានីភ្នំពេញ មន្ត្រីរដ្ឋាភិបាលតាមក្រសួងមន្ទីរបានអបអរសាទរនៅការិយាល័យ សិស្ស-និស្សិតហ៊ោកញ្ជ្រៀវនៅក្នុងបរិវេណសាលា ។ ក្រុមយុវជនជាច្រើនបាននាំគ្នាគ្រវីទង់ជាតិខ្មែរតាមផ្លូវ ។ ពលរដ្ឋកម្ពុជារាប់ម៉ឺននាក់បានចូលរួមទស្សនាការប្រគុំតន្ត្រីដោយច្រៀងរាំនិងទះដៃអបអរសាទរដោយក្ដីសោមនស្សរីករាយ ។ នៅតាមគេហដ្ឋាននីមួយៗមានដោតទង់ជាតិនៅមុខផ្ទះដើម្បីជាការបង្ហាញពីមោទកភាពនិងការអបអរ ។ ចំណែកនៅឯពហុកីឡាដ្ឋានជាតិអូឡាំពិកវិញមានការរៀបចំប្រគុំតន្ត្រីដ៏ធំមួយដែលមានការចូលរួមពីប្រជាជនមកពីគ្រប់ស្រទាប់រាប់ម៉ឺននាក់ ។ ការដាក់ប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោកគឺជាក្ដីសោមនស្សរីករាយ និងមោទកភាពយ៉ាងខ្លាំងរបស់ប្រជាជនកម្ពុជា ។ ចាប់តាំងពីថ្ងៃនោះមកថ្ងៃទី៧ ខែកក្កដាគឺជាទិវាដ៏សំខាន់មួយរបស់ជាតិ ហើយរាល់ឆ្នាំចាប់តាំងពីពេលនោះមក ពិធីនេះត្រូវបានប្រារព្ធអបអរជារៀងរាល់ឆ្នាំ ។

ប៉ុន្តែ ការដាក់ប្រាសាទព្រះវិហារជាបេតិកភណ្ឌនេះធ្វើឲ្យមានការមិនពេញចិត្តពីសំណាក់ប្រទេសថៃដែលពេលនោះស្ថានភាពនយោបាយនៅក្នុងប្រទេសកំពុងជ្រួលច្របល់ស្រាប់ ។ មួយសប្ដាហ៍ក្រោយមកគឺនៅថ្ងៃទី១៥ ខែកក្កដា កងទ័ពថៃបានមកបោះទីតាំងនៅបរិវេណវត្តកែវសិក្ខាគីរីស្វារៈដោយអះអាងថាវត្តនេះមានទីតាំងឋិតនៅក្នុងតំបន់ជម្លោះដែលមានទំហំ៤.៦គីឡូម៉ែត្រការ៉េ ។ ប្រទេសទាំងពីចាត់ទុកថា តំបន់ជម្លោះនេះគឺជាទឹកដីរបស់ខ្លួនបើទោះបីជាតំបន់នេះត្រូវបានប្រទេសកម្ពុជាចាត់ទុកថានៅក្នុងទឹក



ទាហានថៃកំពុងបោះទីតាំងនៅទីតាំងវត្តកែវសិក្ខាគីរីស្វារៈកាលពីខែកក្កដា ឆ្នាំ២០០៨

ដីរបស់ខ្លួនជាយូរមកហើយក៏ដោយ ។ វត្តកែវសិក្ខាគីរីស្វរៈគឺជាវត្តព្រះពុទ្ធសាសនាខ្មែរមួយដែលបានកសាងឡើងនាទសវត្សរ៍ ៩០ ។ ពីរថ្ងៃក្រោយមក នាយករដ្ឋមន្ត្រី ហ៊ុន សែន បានចាត់ទុកវត្តមានយោធាថៃនៅក្នុងបរិវេណវត្តនេះជាការឈ្លានពានទឹកដីខុសច្បាប់ ហើយព្រមជាមួយគ្នានោះដែរ ទាហានកម្ពុជាដែលធ្លាប់មានបទពិសោធន៍ច្បាំងនៅសមរភូមិត្រូវបានបញ្ជូនទៅតំបន់ប្រាសាទព្រះវិហារ ។

បើទោះបីជារដ្ឋាភិបាលថៃបានអះអាងថា វត្តកែវសិក្ខាគីរីស្វារៈស្ថិតនៅក្នុងតំបន់ជម្លោះយ៉ាងណាក្តី ប្រជាជនកម្ពុជាមានប្រតិកម្មនិងតិះទៀនយ៉ាងខ្លាំងចំពោះទាហានថៃក្នុងការមកបោះទីតាំងនៅបរិវេណទឹកដីរបស់ខ្លួនដូច្នេះ ។ ពេលមានយោធាថៃចូលមកបែបនេះ ប្រជាជនកម្ពុជាត្រូវបានរំលឹកឡើងវិញពីមហិច្ឆតាក្តោបក្តាប់របស់ថៃកាលពីអតីតកាល ។ ខណៈពេលដែលកងទ័ពថៃមិនព្រមចាកចេញពីតំបន់ព្រះវិហារតាមសំណូមពររបស់កម្ពុជា ស្មារតីជាតិនិយមរបស់ប្រជាជនកម្ពុជាមានសន្ទុះកាន់តែខ្លាំងជាងមុន ។

ប្រព័ន្ធសារព័ត៌មានបានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ស្មារតីជាតិនិយម និងសាមគ្គីភាពក្នុងចំណោមសាធារណជន ។ អំឡុងពេលជម្លោះប្រដាប់អាវុធនៅព្រំដែនរវាងយោធាថៃ និងកម្ពុជា ប្រព័ន្ធផ្សព្វផ្សាយដូចជា ទូរទស្សន៍ វិទ្យុ និងការសែតបានផ្សព្វផ្សាយព័ត៌មានអំពីប្រាសាទព្រះវិហារជារៀងរាល់ថ្ងៃ ដែលបង្ករឲ្យមានកំហឹង ភាពស្អប់ខ្ពើម ការបង្រួបបង្រួមជាតិក្នុងប្រទេសកម្ពុជា ។ សារព័ត៌មានកម្ពុជាបានប្រើប្រាស់ពាក្យ «សៀម» ជំនួសពាក្យ «ថៃ» វិញ ។ ការប៉ះទង្គិចដោយយោធាលើកដំបូងកើតឡើងនៅខែតុលា ឆ្នាំ២០០៨ ហើយបានបណ្តាលឲ្យប្រជាជនកម្ពុជាបាត់បង់ការជឿទុកចិត្តលើប្រទេសថៃ ហើយបានបញ្ចេញកំហឹងដោយហៅយោធាថៃនោះថា «ចោរសៀម» ។ សារព័ត៌មានក្នុងស្រុកបានផ្សព្វផ្សាយថា ទាហានថៃត្រូវបានសម្លាប់ច្រើនជាងចំនួនដែលសារព័ត៌មានថៃបានផ្សព្វផ្សាយក្នុងអំឡុងនៃជម្លោះប្រដាប់អាវុធនោះ ។ អ្នកយកព័ត៌មានកម្ពុជាមួយចំនួនបានអះអាងថា រដ្ឋាភិបាលថៃបានហាមឃាត់អ្នកយកព័ត៌មានថៃមិនឲ្យមានចូលទៅយកព័ត៌មាននៅក្នុងតំបន់ជម្លោះទេដែលខុសពីកម្ពុជាដែលអ្នកសារព័ត៌មានបាននៅកៀកនឹង



លេណដ្ឋានរបស់យោធាកម្ពុជានៅជិតព្រំដែនថៃនៅជិតប្រាសាទព្រះវិហារ

យោធាតែម្តង ។

ទាហានកម្ពុជាមួយចំនួនដែលត្រូវបានបញ្ជូនទៅតទល់នឹងទាហានថៃគឺជាអតីតយោធាខ្មែរក្រហម ដែលធ្លាប់ច្បាំងជាមួយរដ្ឋាភិបាលកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំមុននិងរចនាសម្ព័ន្ធនយោបាយ និង រដ្ឋបាលរបស់ចលនាខ្មែរក្រហមរលំរលាយក្នុងឆ្នាំ១៩៩៩ ។ ពេលកំពុងប្រយុទ្ធនៅសមរភូមិព្រះវិហារ អតីតយោធាខ្មែរក្រហមទាំងអស់មានឆន្ទះយ៉ាងមោះមុតនិងគាំទ្ររដ្ឋាភិបាលយ៉ាងពេញទំហឹងដើម្បីការពារទឹកដី ។ អតីតយោធាខ្មែរក្រហមដែលត្រូវបានបញ្ជូនទៅព្រះវិហារសុទ្ធតែស៊ាំនឹងស្ថានភាពប្រយុទ្ធកាលពីទសវត្សរ៍៨០ ។ ពេលនេះអតីតយោធាខ្មែរក្រហមទាំងនោះបានបង្វែរពីការប្រឆាំងនិងរដ្ឋាភិបាលមកគាំទ្ររដ្ឋាភិបាលវិញ ហើយស្មារតីនៃការប្តេជ្ញាចិត្តបម្រើរដ្ឋាភិបាលនៅពេលនេះក៏មានសន្ទុះខ្លាំងដែរ ។

ប្រជាជនកម្ពុជាទាំងឡាយបានផ្តល់ការគាំទ្រ ផ្នែកផ្លូវចិត្ត



និងបានឧបត្ថម្ភជាសម្ភារដល់កងទ័ពដែលប្រចាំការនៅប្រាសាទព្រះវិហារដើម្បីរួមចំណែកក្នុងកិច្ចការពារបូរណភាពដែនដីជាតិ ។ ជម្លោះនេះបានលើកកម្ពស់ស្មារតីជាតិនិយម និងយុទ្ធនាការរៃអង្គាសមូលនិធិចាប់ផ្តើមដំណើរការយ៉ាងគ្រឹកគគ្រេងនៅទីក្រុងភ្នំពេញដើម្បីយកមូលនិធិទាំងនោះទៅឧបត្ថម្ភកងទ័ពដែលឈរជើងនៅតាមព្រំដែន ។ ស្ថានីយ៍ទូរទស្សន៍និងវិទ្យុ និងយុទ្ធនាការផ្សេងទៀតបានរៃអង្គាសថវិការបានយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ចលនាប្រឆាំង និងថៃហាក់បីដូចជាកើតឡើងម្តងទៀត ចាប់តាំងពីការធ្វើបាតុកម្មប្រឆាំងនិងវត្តមានរបស់អ្នកជំនួញថៃនិងការដុតបំផ្លាញស្ថានទូតថៃកាលពីឆ្នាំ២០០៣មក ។ ជម្លោះនៅប្រាសាទព្រះវិហារនៅពេលនេះបានជម្រុញឲ្យមានការប្រឆាំងនិងថៃកាន់តែច្រើនជាងមុនដែលជាហេតុធ្វើឲ្យប្រជាជនកម្ពុជាបានបរិច្ចាកធនធានផ្ទាល់ខ្លួន ដើម្បីប្រឆាំងនិងអ្វីដែលហៅថាជាការឈ្លានពានរបស់ទាហានថៃមកលើទឹកដីកម្ពុជា ហើយការផ្តល់ធនធាននេះគឺដើម្បីជាការរួមចំណែកក្នុងការការពារទឹកដីកម្ពុជា ។ ក្រោយពេលដែលជម្លោះបានផ្ទុះឡើង ប្រជាជនកម្ពុជាកាន់តែច្រើនឡើងចាប់ផ្តើមទៅទស្សនាប្រាសាទព្រះវិហារ ហើយផ្តល់ជាធនធានឧបត្ថម្ភដោយផ្ទាល់ ដល់កងទ័ពកម្ពុជាដែលឈរជើងនៅទីនោះ ។ លោកសាស្ត្រាចារ្យ ចន ឆធីរអារី បាននិយាយថា បន្ទាប់ពីមានជម្លោះជាមួយប្រទេសថៃទាក់ទងពីប្រាសាទព្រះវិហារ ការផ្សះផ្សារ និងសាមគ្គីភាពថ្នាក់ជាតិបានចាប់ផ្តើមផុសចេញជារូបរាងឡើងក្នុងសង្គមកម្ពុជា ។ ជាការពិត ប្រជាជនកម្ពុជាបានរួមកម្លាំងគ្នាក្នុងកម្រិតទ្រង់ទ្រាយដ៏ធំក្នុងប្រទេសដើម្បីការការពារឈ្លានពានពីសំណាក់ប្រទេសជិតខាង ។

## ពេលវេលានិងទីកន្លែងត្រូវបានគូសថ្មចំណាំ

ទីកន្លែងនិងកាលបរិច្ឆេទដែលទាហានថៃចូលមកកាន់កាប់វត្តកែវសិក្ខាគីរីស្វារៈត្រូវបានគូសថ្មចំណាំ ។ ព្រឹត្តិការណ៍ដែលទាហានថៃចូលមកដំបូងកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨ ត្រូវបានចារនៅលើផ្ទាំងថ្មធំៗដែលចំណារទាំងនោះតិះទៀនអំពីការឈ្លានពានរបស់ទាហានថៃដែលបានមកកាន់កាប់ទឹកដីកម្ពុជាដោយខុសច្បាប់ ។ ចំណារទាំងអស់នោះគឺក្នុងន័យធ្វើឲ្យមានការចងចាំនិងមិនភ្លេចនូវអ្វីដែលធ្លាប់បានកើតឡើងនិងធ្វើយ៉ាងណាដើម្បីកុំឲ្យមានរឿងរ៉ាវបែបនេះជាថ្មីទៀត ។ ជាក់ស្តែងចំណារមួយដែលបានចានៅលើផ្ទាំងថ្មធំបានសរសេរថា «ហេតុការណ៍ម៉ោង១១:៣៥នាទី ថ្ងៃទី១៥-០៧-២០០៨ ទាហានសៀមបញ្ជូនកម្លាំងចំនួន៣៥០-៣៨០ក្បាល ដឹកនាំដោយផ្កាយមួយកាណុក មេបញ្ជាការកងកម្លាំង ស៊ុរះណារី មកឈ្លានពានទឹកដីខ្មែរនៅចំណុចវត្តកែវសិក្ខាគីរីស្វារៈ» ។ ចំណារនេះអាចធ្វើឲ្យឡើងក្នុងន័យឲ្យប្រជាជនកម្ពុជាចងចាំថៃដែលទាហានថៃចូលមកដល់ទឹកដីខ្មែរកាលពីថ្ងៃទី១៥ ខែកក្កដា នោះ ។ ចំណារមួយទៀតដែលរៀបចំឡើងក្នុងន័យប្តេជ្ញាការពារប្រាសាទព្រះវិហារបានរៀបរាប់ថា «យើងទាំងអស់គ្នាប្តេជ្ញា ការពារប្រាសាទព្រះវិហារឲ្យបានស្ថិតស្ថេរ» ។ ចំណែកឯចំណាមួយទៀតដែលដាក់នៅជិតក្លោងទ្វារវត្តស្រីសិក្ខាគីរីស្វារៈបានសរសេរថា «ខ្មែររួបរួមគ្នាការពារទឹកដីសុវណ្ណភូមិ» ។

រាជរដ្ឋាភិបាលកម្ពុជាក៏បានគាំទ្រកងប្រដាប់អាវុធដែល

ប្រចាំការនៅប្រាសាទព្រះវិហារជាបន្តបន្ទាប់មកដែរ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើទស្សនកិច្ចជាលើកដំបូងនៅលើភ្នំប្រាសាទកាលពីខែកុម្ភៈ ឆ្នាំ២០១០ ហើយបានប្រារព្ធពិធីសាសនាមួយនៅលើភ្នំនោះ ហើយឆ្លៀតឱកាសនោះ សម្តេចនាយករដ្ឋមន្ត្រីក៏បានបញ្ជាក់ពីជំហររបស់រដ្ឋាភិបាលដដែលដោយចោទថា ទាហានថៃជាអ្នកឈ្លានពានទឹកដីកម្ពុជា ។ ស្របជាមួយគ្នានេះដែរ សម្តេចបានលើកទឹកចិត្តឲ្យទាហានកម្ពុជាទាំងអស់ប្តេជ្ញាការពារទឹកដីឲ្យបានគង់វង្ស ។ នៅថ្ងៃតែមួយ សម្តេចបានអញ្ជើញមេបញ្ជាការថៃឈ្មោះ វ៉ាវ៉ារីត កាជូរីត និងមន្ត្រីថៃជាច្រើនរូបទៀតមកចូលរួមក្នុងការប្រារព្ធពិធីនៅលើប្រាសាទព្រះវិហារនិងបន់ស្រន់រួមគ្នាសុំសន្តិភាពនៅរវាងប្រទេសទាំងពីរ ។

## ស្មារតីជាតិនិយមថៃ និងនយោបាយបែកខ្ញែក

ការបញ្ចូលប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោកបានកើតឡើងស្របគ្នានឹងជម្លោះនយោបាយផ្ទៃក្នុងប្រទេសថៃកំពុងកើតមាន ។ ក្រុមជាតិនិយមប្តូរសម្ព័ន្ធប្រជាជនសម្រាប់លទ្ធិប្រជាធិបតេយ្យ កំពុងធ្វើបាតុកម្មប្រឆាំងនឹងរដ្ឋាភិបាលដែលគាំទ្រអតីតនាយករដ្ឋមន្ត្រី ថាក់ស៊ីន ស៊ីណាវ៉ាត់ត្រា ។ អតីតនាយករដ្ឋមន្ត្រីថៃ សាម៉ាក់ សាន់ដាវ៉ាវី ដែលធ្លាប់ព្រមព្រៀងជាមួយរដ្ឋាភិបាលកម្ពុជាក្នុងការចាត់បញ្ចូលប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោក បានកែប្រែមកប្រឆាំងនឹងការចាត់បញ្ចូលនេះវិញ ដោយសារតែបញ្ហានយោបាយ នៅក្នុងប្រទេសថៃនិងដោយសារក្តីបារម្ភដែលអាចបណ្តាលឲ្យមានការបាត់បង់ទឹកដីដែលរដ្ឋាភិបាលថៃអះអាងថាតំបន់៤.៦គីឡូម៉ែត្រការ៉េគឺជារបស់ខ្លួន ។

ក្រោយពីសេចក្តីសម្រេចចុះបញ្ជីប្រាសាទព្រះវិហារជាបេតិកភណ្ឌត្រូវបានធ្វើឡើង ក្រុមជាតិនិយមអាវលឿងបានចោទប្រកាន់រដ្ឋាភិបាលរបស់ សាម៉ាក់ សាន់ដាវ៉ាវី ថាបានគាំទ្រសំណើរបស់ប្រទេសកម្ពុជា ដោយធ្វើឲ្យប្រទេសថៃបាត់បង់ទឹកដីទៅឲ្យប្រទេសកម្ពុជា ។ នាពេលនោះ បាតុករជាតិនិយមអាវលឿងក៏បានបញ្ឆេះឲ្យមានការខឹងសម្បារមកលើរដ្ឋាភិបាលកម្ពុជានិងប្រទេសកម្ពុជាដែរ និងបំផុសឲ្យមានការចាត់វិធានការចំពោះការចុះប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោក ។ ម្យ៉ាងវិញទៀត ក្រុមអាវលឿងក៏បានប្រឆាំងនិងនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយសារតែភាពជិតស្និតជាលក្ខណៈបុគ្គលជាមួយអតីតនាយករដ្ឋមន្ត្រី ថាក់ស៊ីន ស៊ីណាវ៉ាត្រា ដែលក្រុមអាវលឿងកំពុងធ្វើបាតុកម្មប្រឆាំង ។

ជម្លោះបានផុសឡើងម្តងទៀតនៅពេលដែលនាយករដ្ឋមន្ត្រី ហ៊ុន សែន បានតែងតាំង ថាក់ស៊ីន ស៊ីណាវ៉ាត់ត្រា ជាទីប្រឹក្សាពិសេសផ្នែកសេដ្ឋកិច្ចរបស់រដ្ឋាភិបាលកម្ពុជា ។ ដោយសារតែហេតុផលនេះ ក្រុមជាតិនិយមអាវលឿងបានប្រឆាំងនិងកម្ពុជាព្រមទាំងនាយករដ្ឋមន្ត្រីហ៊ុន សែនកាន់តែខ្លាំងជាងមុន ហើយពេលនោះ ក្រុមអាវលឿងនេះបានទាមទារឲ្យផ្តាច់ទំនាក់ទំនងជាមួយកម្ពុជាទាំងស្រុង ដោយបិទច្រកព្រំដែនអន្តរជាតិជាមួយនឹងប្រទេសកម្ពុជាទាំងអស់ ឲ្យអ្នកជំនួញថៃចាកចេញពីប្រទេសកម្ពុជា និងបិទជើងយន្តហោះនៃប្រទេសទាំងពីរ ។ កំហឹងជាតិនិយមប្រឆាំងនឹងកម្ពុជាពីសំណាក់ក្រុមអាវលឿង និងប្រជាជនថៃមួយចំនួនក៏ផុសផុលកាន់តែខ្លាំងដែរ ហើយនិងបំផុសឲ្យមានការទាមទារតំបន់៤.៦គីឡូម៉ែត្រការ៉េនោះមកវិញ ។ អ្នកសារព័ត៌មានថៃមួយចំនួនមិនបានយល់ស្របទៅនិងអ្វីដែលក្រុមអាវលឿងបានទាមទារចង់បានទេ ហើយថា ការទាមទាររបស់ក្រុមជាតិនិយមនេះអាចជាការទាមទាលើសពីអ្វីដែលរដ្ឋាភិបាលថៃអាចធ្វើបាន ។ អ្នកសារព័ត៌មានថៃម្នាក់ឈ្មោះ ភើង គ្រូភូ បាននិយាយថា "ប្រសិនបើយើងមិនយល់ស្របតាមក្រុមអាវលឿង នោះយើងនឹងត្រូវបានចាត់ទុកជាជនក្បត់ជាតិ ដោយសារតែយើងមិនទាមទាទឹកដីពីកម្ពុជាមកវិញ" ។ ប៉ុន្តែ ភើង គ្រូភូ បានអះអាងថា ការទាមទាតំបន់៤.៦គីឡូម៉ែត្រការ៉េនេះគឺជារឿងនយោបាយប្រឆាំងនិងរដ្ឋាភិបាលថៃដែលគាំទ្រដោយអតីតនាយករដ្ឋមន្ត្រី ថាក់ស៊ីន ស៊ីណាវ៉ាត្រា និង នាយករដ្ឋមន្ត្រីកម្ពុជាច្រើនជាង ។

អ្នកយកព័ត៌មានថៃដែលរាយការណ៍ពីព្រឹត្តិការណ៍ជម្លោះនៅប្រាសាទព្រះវិហារត្រូវបានចាត់ទុកថាមិនមែនជាអ្នកស្នេហាជាតិ ប្រសិនបើអ្នកសារព័ត៌មាននោះមិនរាយការណ៍ថាប្រទេសកម្ពុជាបានឈ្លានពានយកដីថៃក្នុងតំបន់៤.៦គីឡូម៉ែត្រការ៉េដែលកម្ពុជាកំពុងកាន់កាប់ ។ ធូនថង ម៉ានីពុង អ្នកសារព័ត៌មានម្នាក់ដែលរាយការណ៍ពីជម្លោះនៅប្រាសាទព្រះវិហារបានអះអាងថា "មានការជម្រុញឲ្យមានការស្អប់គ្នាកាន់តែច្រើនពីសំណាក់ប្រជាជន

ថៃមកលើប្រជាជនកម្ពុជា» ។ ធូនថង ម៉ានីពុង ធ្លាប់បានរាយការណ៍ថា ប្រទេសកម្ពុជាមានសិទ្ធិស្របច្បាប់ក្នុងការដាក់ប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោកដោយសារតែប្រាសាទព្រះវិហារស្ថិតនៅក្នុងទឹកដីកម្ពុជា ប៉ុន្តែនៅពេលដែលគាត់បានរាយការណ៍ពីការពិតទាំងនេះ គាត់បានទទួលទូរសព្ទពីក្រុមជាតិនិយមថា កាន់ជើងប្រទេសកម្ពុជា ។

នៅពេលដែល អាប់ហ៊ីស៊ីត វីចាជីវ៉ា ដែលក្រុមជាតិនិយមអាវលឿងគាំទ្រ បានក្លាយជានាយករដ្ឋមន្ត្រីរបស់ប្រទេសថៃ គាត់បានបន្តប្រឆាំងនឹងប្រទេសកម្ពុជាចំពោះរឿងរ៉ាវប្រាសាទព្រះវិហារ និងនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ ស្របពេលដែលជម្លោះនៅប្រាសាទកំពុងកើតមាន នាយករដ្ឋមន្ត្រី អាប់ហ៊ីស៊ីត វីចាជីវ៉ា និងនាយករដ្ឋមន្ត្រីកម្ពុជាក៏មានបញ្ហាចរចារមិនសូវស៊ីសង្វាក់គ្នាដែរដែលបង្កើតឲ្យមានការលំបាកក្នុងការរកដំណោះស្រាយទាក់ទងទៅនឹងប្រាសាទព្រះវិហារ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្លាប់បានអះអាងថា នាយករដ្ឋមន្ត្រី អាប់ហ៊ីស៊ីត វីចាជីវ៉ា គឺជាមេដឹកនាំដែលពិបាកធ្វើការជាមួយជាងគេបំផុត ។ ស្របជាមួយគ្នានោះប្រជាជនកម្ពុជាមួយចំនួនក៏យល់ស្របតាមនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែរដោយចោទទៅនាយករដ្ឋមន្ត្រីថៃថាមិនមានឆន្ទះក្នុងការដោះស្រាយបញ្ហាព្រំដែន ។ ចំណែកក្រុមបាតុករអាវលឿងក៏ទាមទាកាន់តែខ្លាំងឲ្យនាយករដ្ឋមន្ត្រីរបស់ខ្លួនទាមទាយកដីជុំវិញប្រាសាទមកវិញឲ្យទាល់តែបានដែរ ។

អ្នកភូមិជនជាតិថៃដែលរស់នៅក្បែរប្រាសាទមានទស្សនៈខុសគ្នាពីក្រុមជាតិនិយមអាវលឿង ។ ក្នុងឆ្នាំ២០០៩ អ្នកភូមិនៅក្បែរប្រាសាទព្រះវិហារនិងនិងក្រុមអាវលឿងបានប៉ះទង្គិចគ្នាដោយសារតែក្រុមអាវលឿងទាំងនោះធ្វើដំណើរមកទស្សនាប្រាសាទក្នុងគោលបំណងឡើងទៅដើងភ្នំដើម្បីបណ្តេញប្រជាជនកម្ពុជាឲ្យចាកចេញពីតំបន់នោះ ។ ក្រុមអាវឡើងនេះត្រូវបានសមត្ថកិច្ចនិងអ្នកភូមិហាមឃាត់ពីព្រោះមិនចង់ឲ្យស្ថានភាពតានតឹងជាមួយប្រទេសកម្ពុជាកាន់តែយ៉ាប់យឺនទៅ ។

## សេចក្តីសន្និដ្ឋាន

អ្នកនយោបាយរបស់ប្រទេសទាំងពីរបានប្រើប្រាស់ស្មារតីជាតិនិយមដើម្បីទាញយកផលចំណេញផ្នែកនយោបាយពីបញ្ហាជម្លោះទាក់ទងនិងប្រាសាទព្រះវិហារ ។ នៅប្រទេសថៃបញ្ហាផ្ទៃក្នុងប្រទេសដែលក្រុមអាវលឿងប្រឆាំងនឹងរដ្ឋាភិបាលដែល



ស្ត្រីម្នាក់កំពុងអុចធូបនៅក្បែររូងលោកតាឪដោយមានការជួយគ្រោមជ្រែងពីទាហានកម្ពុជាដែលកំពុងឈរជើងនៅទីនោះ

គាំទ្រអតីតនាយករដ្ឋមន្ត្រី ថាក់ស៊ីន ស៊ីណាវ៉ាត្រា ហើយក្រុមនេះបានប្រឆាំងនិងការដាក់បញ្ចូលប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោក ទាមទារឲ្យមានការដកតំបន់ប្រាសាទព្រះវិហារពីបញ្ជីបេតិកភណ្ឌវិញ ។ សម្រាប់ប្រទេសកម្ពុជាការដែលកងទ័ពថៃមកបោះទីតាំងនៅលើវត្តកែវសិក្ខាគិរីស្វារៈគឺជាទង្វើមួយដែលកម្ពុជាចាត់ទុកថា "ការរំលោភឈ្លានពាន" លើបូរណភាពដែនដីរបស់ខ្លួន ។ ប្រជាជនកម្ពុជាខ្លះបានចាត់ទង្វើរបស់ទាហានថៃទាំងនោះថាជាការមិនព្រមបោះបង់ចោលនូវមហិច្ឆតាលួចយកទឹកដីកម្ពុជា ។ ទាហានកម្ពុជាម្នាក់ប្រចាំការនៅតាមព្រំដែនបាននិយាយថា គាត់មិនជឿទុកចិត្តលើទាហានថៃឡើយ ហើយថា ទាហានថៃពោរពេញដោយល្បិចកល ។ យោធានោះបាននិយាយថា "នៅពីមុខយើងទាហានថៃមានចរិកសុភាពរាបសារឥតខ្ចោះ ប៉ុន្តែនៅក្រោយខ្នងយើងវិញ ទាហានថៃតែងតែបាញ់សម្លាប់ខ្មែរដែលឆ្លងកាត់ព្រំដែន" ។

បើទោះបីជាមានបញ្ហានយោបាយ និងជម្លោះជាបន្តបន្ទាប់យ៉ាងណាក្តី ប្រាសាទព្រះវិហារ និងការដាក់បញ្ចូលប្រាសាទនេះជាបេតិកភណ្ឌពិភពលោកអាចផ្តល់ជាប្រយោជន៍រួមគ្នា ។ ទាំងប្រទេសថៃ និងកម្ពុជា មានជំនឿសាសនាស្រដៀងគ្នា ហើយប្រាសាទនេះអាចក្លាយជាទីកន្លែងប្រារព្ធពិធីសាសនារួមសម្រាប់ប្រទេសទាំងពីរ ។ បន្ថែមលើនេះ ប្រាសាទព្រះវិហារអាចក្លាយជាប្រភពនៃប្រាក់ចំណូលខាងសេដ្ឋកិច្ចមួយ ។ ប្រជាជនកម្ពុជា និងប្រជាជនថៃយល់ស្របថា ការសហការដ៏ល្អរវាងប្រទេសទាំងពីរគឺជាជំហានដ៏ ចម្បងមួយដើម្បីទទួលបានផលចំណេញទាំងសងខាងផ្នែកសេដ្ឋកិច្ច ។ ទាំងប្រជាជនកម្ពុជា និងប្រជាជនថៃដែលរស់នៅជុំវិញប្រាសាទព្រះវិហារចង់ឲ្យច្រកទ្វារព្រំដែនបើកសារជាថ្មីម្តងទៀតដើម្បីឲ្យភ្ញៀវទេសចរអាចមកទស្សនាប្រាសាទនេះម្តងទៀតដើម្បីជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនទាំងពីរ ។ ប្រសិនបើប្រទេសថៃនិងប្រទេសកម្ពុជាមើលឃើញអំពីសារសំខាន់រួមផ្នែកវប្បធម៌ សាសនា និងសេដ្ឋកិច្ច ប្រាសាទ ព្រះវិហារអាចដើរតួនាទីជាកម្លាំងរួមមួយរវាងប្រទេសជាតិទាំងពីរ ។ **ញាណ សុជាតិ**

# ដំណឹងស្វែងរកគ្រួសារ

*ខ្ញុំបាទឈ្មោះ វង្ស ទ្រង់ ហៅ អ៊ួង ដេង ភេទប្រុស អាយុ៤៧ឆ្នាំ ។ សព្វថ្ងៃរស់នៅផ្ទះ លេខ២៦៥A ផ្លូវ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ក្រុងភ្នំពេញ ។ ខ្ញុំបាទសូមប្រកាសរកសមាជិកគ្រួសារដែលបានបាត់ខ្លួនក្នុងសម័យខ្មែរក្រហមដែលមានឈ្មោះគឺ*

*១.ឪពុកឈ្មោះ វង្ស ត្រុងយ៉ុង កាលបែកគ្នាមានអាយុប្រហែល៤៣ឆ្នាំ*

*២.ម្តាយឈ្មោះ លឹម បូរី កាលបែកគ្នាមានអាយុប្រហែល៤០ឆ្នាំ*

*៣.បងប្រុសឈ្មោះ វង្ស បូឃី ហៅ អ៊ួង បូឃី កាលបែកគ្នាមានអាយុប្រហែល១៨ឆ្នាំ*

*៤.បងប្រុសទីបីឈ្មោះ វង្សម៉េង ហៅ អ៊ួង ម៉េង កាលបែកគ្នាមានអាយុប្រហែល១៤ឆ្នាំ*

*៥.ប្អូនប្រុសទីប្រាំឈ្មោះ វង្ស រឿន ហៅ អ៊ួង រឿន កាលបែកគ្នាមានអាយុប្រហែល៨ឆ្នាំ*

*មុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ អ្នកទាំងអស់គ្នារស់នៅសង្កាត់លេខ៣ ក្រុងភ្នំពេញ ត្រង់ផ្លូវសុខហុក កែងនឹងផ្លូវបត់ទៅផ្សារឌុយម៉ិច ។ នៅពេលជម្លៀសចេញពីក្រុងភ្នំពេញទៅតាមបណ្តោយផ្លូវជាតិលេខ៤ ទៅដល់ត្រង់ម្តុំពោធិចិនតុង ខ្ញុំបានបែកពីអ្នកទាំងអស់ខាងលើតាំងពីពេលនោះមក ។*

*អាស្រ័យហេតុនេះ ប្រសិនបើបងប្អូនណាស្គាល់អ្នកទាំងអស់ដូចបានរៀបរាប់ខាងលើ សូមទាក់ទងតាមទូរស័ព្ទលេខ ០៩២ ៨២៥ ៥៣៤ និង០៧៧ ៦០៦ ០៣០ឬតាមអាស័យដ្ឋានខាងលើ ។* ***សូមអរគុណ***

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺជាឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនិងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហមនិងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

«ការិយាល័យព័ត៌មានសាធារណៈ» មានផ្តល់ជូននូវសេវាចម្បងបីយ៉ាង ៖

**១) បណ្ណាល័យ ៖** នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ ៖** មជ្ឈមណ្ឌលមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃ ។

**៣) ក្រុមការងារផ្នែកតុលាការ ៖** ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ីវ សាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# សេវាថែទាំសុខភាពជាសំណងដ៏ប្រពៃ

នាងខ្ញុំមានឈ្មោះ នង គីមលាង អាយុ៦០ឆ្នាំរស់នៅសង្កាត់បឹងកេងកង ខណ្ឌចំការមន ទីក្រុងភ្នំពេញ ។ មុនឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំរស់នៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ នៅដើមឆ្នាំ១៩៧៥ យើងបានផ្លាស់ទីកន្លែងទៅរស់នៅប្រទេសវៀតណាម ដោយសារតែយើងភ័យខ្លាចនឹងសង្គ្រាមដែលកំពុងកើតឡើងនៅក្នុងប្រទេស ។ កាលណោះ យើងបានទៅនៅស្វាច ខេត្តតាយនិញ ប្រទេសវៀតណាម ក្បែរព្រំប្រទល់ខេត្តកំពង់ចាម ។

ខ្ញុំមិនចាំថាបងស្រីខ្ញុំ និងក្មួយប្រុស ខ្ញុំត្រូវបានចាប់ខ្លួននៅឆ្នាំណាទេ ។ ប៉ុន្តែ ខ្ញុំបានចាំថាបងស្រីខ្ញុំ និងកូនប្រុសពីរនាក់របស់គាត់ត្រូវបានចាប់ខ្លួនពេលដែលអ្នកទាំងអស់គ្នាទៅស្រែដើម្បីដកស្ទូង ។ អ្នកជិតខាងខ្ញុំក៏បានទៅស្រែដែរ ហើយគាត់បានប្រាប់ថាបងស្រីខ្ញុំនិងកូនប្រុសរបស់គាត់ត្រូវបានឈ្លបខ្មែរក្រហមចាប់ចង ។ យោធាខ្មែរក្រហមនោះចាប់ខ្លួនបងស្រីខ្ញុំនិងកូនប្រុសរបស់គាត់ទៅហើយ ខ្ញុំមិនបានទទួលដំណឹងអ្វីពីគាត់រហូត ។ តាមពិតស្រែនោះគឺឋិតនៅក្នុងទឹកដីប្រទេសវៀតណាមទេ ។ ខ្ញុំមិនដែលដឹងថាបងស្រីខ្ញុំ និងក្មួយប្រុសរបស់ខ្ញុំត្រូវបានឃុំខ្លួនគុកទួលស្លែងទេ ។ រហូតដល់ឆ្នាំ១៩៨០ ទើបខ្ញុំបានឃើញរូបថតបងស្រីខ្ញុំនៅទីនោះខណៈពេលដែលខ្ញុំបានទៅមើលគុកទួលស្លែង ។

ខ្ញុំមានអារម្មណ៍ឈឺចាប់ក្រៃលែងនៅពេលបានដឹងពីជោគវាសនារបស់បងស្រីខ្ញុំ និងក្មួយប្រុសជាទីស្រឡាញ់របស់ខ្ញុំ ។ ប៉ុន្តែ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៨ ដោយសារតែទទួលបានជំនួយពីបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាខ្ញុំក៏បានសម្រេចចិត្តដាក់ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ។ ខ្ញុំសង្ឃឹមថានឹងទទួលបានយុត្តិធម៌ពីតុលាការ ។ បើសិនជាអាចខ្ញុំសូមស្នើសុំឲ្យតុលាការផ្តល់សេវាថែទាំសុខភាពដោយមិនយកប្រាក់កម្រៃដើម្បីជាសំណងថ្លៃខូចខាត ។ **នង គីមលាង**



# ទស្សនាខ្សែភាពយន្តអំពីរបបខ្មែរក្រហមនៅ មជ្ឈមណ្ឌលឯកសារកម្ពុជា

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ផ្ទុកទៅដោយខ្សែភាពយន្តអំពីរបបខ្មែរក្រហមជាង២០០ នៅក្នុងបណ្ណសារ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានអាសយដ្ឋានដូចរៀបរាប់ខាងលើ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រមែប្រមូលឯកសារនានាដែលទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យដែលបានបង្កវិនាសកម្មដ៏ធំធេងទាំងផ្លូវកាយនិងផ្លូវចិត្តដល់ពលរដ្ឋកម្ពុជាជាទូទៅ ។ ដើម្បីផ្តល់ឱកាសដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម អ្នកស្រាវជ្រាវ សិស្ស និស្សិត មន្ត្រីរដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាលនានារៀនសូត្រ និងយល់ដឹងពីរបបខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជាបើកទទួលអ្នកដែលមានចំណាប់អារម្មណ៍ទាំងអស់ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពីម៉ោង ៨ៈ០០ ដល់ម៉ោង ៥ៈ០០ ល្ងាច ដើម្បីមើលខ្សែភាពយន្តទាក់ទងទៅនិងរបបខ្មែរ ។ បើសាធារណជនចង់ជ្រាបព័ត៌មានបន្ថែមទាក់ទងទៅនិងខ្សែភាពយន្តសូមទាក់ទង ឡេង រតនៈ ឬ សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។

មកដល់ពេលនេះមជ្ឈមណ្ឌលបានផលិតខ្សែភាពយន្តបានចំនួនបួនហើយ




**១) វាលស្រែខ្មែរក្រហមៈ រឿងរ៉ាវរបស់ស្ត្រីម្នាក់ឈ្មោះ តាំង គីម ដែលត្រូវបានរំលោភដោយយោធាខ្មែរក្រហមៈ** យប់មួយក្នុងឆ្នាំ១៩៧៥ នារីវ័យក្មេងម្នាក់ឈ្មោះ តាំង គីម ដែលទើបតែរៀបការរួចថ្មីៗ ត្រូវបានយោធាខ្មែរក្រហមមកហៅឲ្យទៅជួបប្តីរបស់ខ្លួនដែលជាទាហាន លន់ នល់ ។ តែតាមពិត តាំង គីម គឺជាស្ត្រីម្នាក់ក្នុងចំណោមស្ត្រីប្រាំបីនាក់ដែលត្រូវបានបញ្ជូនទៅកាន់វាលស្រែមួយនៅក្បែរភូមិដើម្បីសម្លាប់ចោល ។ ពេលដែលកំពុងយាមដោយយោធាខ្មែរក្រហមម្នាក់ តាំង គីម បានឮសំឡេងស្ត្រីដទៃទៀតស្រែកយំដោយក្តីឈឺចាប់ ពេលស្ត្រីទាំងនោះត្រូវយោធាខ្មែរក្រហមមួយក្រុមរំលោភ ។ ក្រោយមកយោធាខ្មែរក្រហមឯទៀតបានចូលមករំលោភគាត់ដែរ ។ ខ្សែភាពយន្តនេះរៀបរាប់អំពីរឿងរ៉ាវរបស់ស្ត្រី តាំង គីម ដែលក្រោយមកបានបួសជាដូនជីដែលបានតស៊ូជាមួយនិងបច្ចុប្បន្នកាលនិងអតីតកាល ។




**២) នៅគៀនជញ្ជាំងនៃមន្ទីរស-២១ៈ** ខ្សែភាពយន្តនេះបង្ហាញពីការរៀបរាប់ខ្សែជីវិតរបស់មនុស្សបីនាក់ ក្នុងនោះពីរនាក់គឺជាជនរងគ្រោះនិងម្នាក់ទៀតជាកម្មាភិបាលខ្មែរក្រហមនៅមន្ទីរស-២១ ដែលជាកន្លែងឃុំឃាំងអ្នកទោសដ៏ធំបំផុតក្នុងសម័យកាលរបបកម្ពុជាប្រជាធិតេយ្យ១៩៧៥-១៩៧៩ ។ ខ្សែភាពយន្តនេះរៀបរាប់ពីដំណើរជីវិតមនុស្សទាំងបីនាក់ដែលចាប់កំណើតក្នុងទីកន្លែងផ្សេងគ្នា តែទីបញ្ចប់ទទួលនូវជោគវាសនាដូចគ្នានៅទីកន្លែងតែមួយគឺមន្ទីរស-២១ ។ ម្ភៃប្រាំឆ្នាំក្រោយពីរបបខ្មែរក្រហមដួលរំលំ អ្នកទាំងបីបានរៀបរាប់ពីដំណើរជីវិតមុននិងក្លាយជាអ្នកទោស និងក្លាយជាកងការពារអ្នកទោសនៅមន្ទីរស-២១នេះ ។

**៣) ត្រៀមខ្លួនស្វែងរកយុត្តិធម៌ៈ** ទូទាំងឆ្នាំ២០០៦ មជ្ឈមណ្ឌលឯកសារកម្ពុជាបាន




អញ្ជើញអ្នកភូមិដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ហើយកំពុងរស់នៅតំបន់នានាទូទាំងប្រទេស ដើម្បីមកទស្សនាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីអប់រំប្រជាជនកម្ពុជាអំពីដំណើរកិច្ចការងារនៅអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា និងដើម្បីផ្តល់ឱកាសដល់អ្នករស់រានជីវិតពីរបបខ្មែរក្រហមចូលរួមចំណែកក្នុងដំណើរការយុត្តិធម៌ ។ ក្នុងដំណើរទស្សនកិច្ចនេះ អ្នកភូមិក៏បានទៅដល់ទីតាំងវាលពិឃាតនានា ដើម្បីឲ្យគាត់អាចវិនិច្ឆ័យដោយខ្លួនឯងចំពោះទង្វើបទឧក្រិដ្ឋដែលខ្មែរក្រហមបានប្រព្រឹត្ត ។ ដំណើរទស្សនកិច្ចនេះបានបញ្ចូលមនុស្សគ្រប់ស្រទាប់វណ្ណៈក្នុងសង្គមដូចជាដូនជី ជនជាតិខ្មែរឥស្លាម សិស្សនិស្សិត និងអ្នកភូមិដែលរស់នៅក្នុងតំបន់ក្រីក្រនានាទូទាំងប្រទេសដែលមិនមានលទ្ធភាពទទួលបានព័ត៌មានផ្សេងៗ ។ ដំណើរទស្សនៈកិច្ចនេះដើម្បីបង្ហាញថា តុលាការនិងមានប្រសិទ្ធភាពបើសិនជាមានការចូលរួមពីជនរងគ្រោះ ។ ខ្សែភាពយន្តនេះបង្ហាញពីដំណើរទស្សនកិច្ចនេះ និងអំពីទស្សនៈយល់ឃើញរបស់អ្នកភូមិជុំវិញរបបខ្មែរក្រហមនិងដំណើរក្តីខ្មែរក្រហម ។

**៤) រណ្តៅសាកសពក្បែរវត្ត ៖** ខ្សែភាពយន្តឯកសារនេះរៀបរាប់អំពីដំណើរជីវិតរបស់ស្រ្តីពីររូបគឺ លៀប និង វាំង ដែលប្រឈមមុខរាល់ថ្ងៃទៅនឹងហេតុការណ៍ពិតដែលថា ឪពុកនិងពូជាទីស្រឡាញ់របស់ខ្លួនត្រូវបានសម្លាប់ដោយស្នាដៃរបស់បុរសម្នាក់ឈ្មោះ គិន ដែលជាអតីតឈ្លបឃុំមួយរូបកាលពីជំនាន់ខ្មែរក្រហម ។




រណ្តៅសាកសពរបស់ឪពុក លៀប ដែលមានទីតាំងនៅក្បែរវត្តដែល គិន ធ្វើជាអាចារ្យនាពេលបច្ចុប្បន្ននេះគឺជារណ្តៅមួយក្នុងចំណោមរណ្តៅចំនួនជាងពីរម៉ឺនកន្លែងដែលបន្សល់ពីជំនាន់ខ្មែរក្រហម ។ អ្វីដែលដែលគួរឲ្យភ្ញាក់ផ្អើលនោះគឺថា ទោះបីជា គិន ទទួលខុសត្រូវចំពោះមរណភាពឪពុករបស់ លៀប និងពូរបស់ វាំង ក៏ដោយ ក៏ គិន នៅតែទទួលបាននូវការគោរពពីសំណាក់អ្នកភូមិរួមទាំង លៀប និង វាំង ផង ដោយសារតែគាត់ជាអាចារ្យវត្ត ។

ដូចអ្នករស់រានពីរបបខ្មែរក្រហមផ្សេងទៀតដែរ លៀប និង វាំង មិនបានសងសឹកជាមួយជនដៃដល់ទេ ។ ប៉ុន្តែនេះមិនប្រាកដថា អ្នកទាំងពីរអាចអត់ឱនទោសឲ្យ គិន បានទេ ។ លៀប និង វាំង នៅតែត្រងត្រាប់តាមឱវាទរបស់ព្រះពុទ្ធដោយ “ពៀររំងាប់ដោយការមិនចងពៀរ” ។

នៅក្នុងខ្សែភាពយន្តឯកសារនេះ លៀប បាននិយាយថា “ប្រហែលជាឪពុកខ្ញុំជំពាក់ តាគិន បានជា តាគិន មកសម្លាប់ឪពុកខ្ញុំ ។ ខ្ញុំមិនឲ្យប្អូនទៅសងសឹក (គិន) ទេ ព្រោះខ្លាចជំពាក់ឈាមគ្នា” ។

ព្រះពុទ្ធបានថែងថា អ្នកធ្វើអំពើអាក្រក់និងទទួលបានផលអាក្រក់ ទោះជាតិនេះក្តីឬជាតិក្រោយក្តី ។

ខុសពី គិន អតីតកម្មាភិបាលខ្មែរក្រហមផ្សេងទៀត មិនដែលសារភាពពីអ្វីដែលខ្លួនបានធ្វើកាលពីជំនាន់ខ្មែរក្រហមទេ ។ ប៉ុន្តែការអត់ឱនពិតជាអាចកើតឡើងបាន ហើយជនដៃដល់មួយចំនួនក៏ទទួលស្គាល់ពីកំហុសរបស់ខ្លួនដែរ ។ រឿងរ៉ាវរបស់ គិន លៀប និង វាំង គឺជាករណីមួយក្នុងចំណោមករណីជាច្រើនទៀតទូទាំងប្រទេស ដែលជនដៃដល់និងជនរងគ្រោះរស់នៅជាមួយគ្នាក្នុងភូមិ ឬសហគមន៍តែមួយ ។ “រណ្តៅសាកសពក្បែរវត្ត” អាចរកមើលបាននៅការិយាល័យមជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏តាមរយៈគេហទំព័រ *http://www.dccam.org/Archives/Films/Films.htm* ឬក៏តាមរយៈគេហទំព័រ youtube ។ **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ពូខ្ញុំត្រូវបានជុតចោលនៅមន្ទីរស-២១

ពូរបស់ខ្ញុំឈ្មោះ ដឹម វីល្យ៉ាមក្លាក ។ គាត់ត្រូវបានយោធាខ្មែរក្រហមចាប់ខ្លួននៅឆ្នេរសមុទ្រកម្ពុជា បន្ទាប់មកគាត់ត្រូវបានយកទៅឃុំឃាំងនិងសម្លាប់នៅមន្ទីរស-២១ ។ ខ្ញុំបានដឹងពីការស្លាប់របស់ពូខ្ញុំនៅខែមិនា ឆ្នាំ១៩៨០ ។ ម៉ាក់ខ្ញុំឈ្មោះ ស្សឺរី ក្លាក (Sherry A. Clark) ដែលត្រូវជាបងរបស់ ពូដឹម បានបង្ហាញទស្សនាវដ្ដីនិយាយពីជីវិតមួយក្បាលដែលចុះផ្សាយនៅខែមីនា ឆ្នាំ១៩៨០ ។ ក្នុងទស្សនាវដ្ដីនោះមានអត្ថបទមួយដែលនិយាយពីភាពឃោរឃៅរបស់ខ្មែរក្រហម ។ ក្នុងអត្ថបទនោះដែរក៏មានភ្ជាប់រូបថតដ៏គួរឲ្យខ្លាចមួយសន្លឹករបស់ពូខ្ញុំ ដែលរូបនោះមានសភាពញាក់ញី ហើយហាក់បីដូចជាឃ្លានស្ទើរតែដាច់ពោះស្លាប់នៅក្នុងបន្ទប់តូចមួយនៅគុកទួលស្លែង ។ អត្ថបទមួយនោះបានរៀបរាប់យ៉ាងលម្អិតពីការធ្វើទារុណកម្ម ដោយបង្ខំឲ្យពូរបស់ខ្ញុំសារភាពថាគាត់គឺជាភ្នាក់ងារស៊ើបការណ៍របស់សេ.អ៊ី.អា ។ នៅខែឧសភា ឆ្នាំ១៩៧៨ គាត់ត្រូវបានធ្វើទារុណ្ណកម្មដោយបង្អត់អាហារ វាយដំ បន្ទាប់មកយកទៅដុតសម្លាប់ចោលក្នុងកង់កៅស៊ូមួយ ។ គាត់បានចុះហត្ថលេខានៅលើចម្លើយសារភាពទាំងបង្ខំជាមួយនឹងស្នាមមេដៃដែលថ្មីៗនេះត្រូវបានគេដាក់បង្ហាញនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។

នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៨ ទូកក្ដោងរបស់ពូខ្ញុំបានរសាត់អណ្ដែតចូលមកក្នុងដែនទឹកកម្ពុជា ហើយក៏ត្រូវទូកឆ្មាំកាំភ្លើងរបស់ខ្មែរក្រហមបាញ់បំផ្លាញដោយប្រើកាំភ្លើងកាណុង ២០ មីលីម៉ែត្រ ។ បន្ទាប់មកទូកនោះក៏បានលិចបាត់ទៅ ។ ពូដឹមអាចរួចរស់ជីវិតពីការវាយប្រហារនោះបានក៏ដោយសារតែការរង់ចាំថតរូបដោយខ្មែរក្រហមសិនប៉ុណ្ណោះ ។ គាត់ត្រូវបានយោធាខ្មែរក្រហមដឹកយកទៅមន្ទីរស-២១នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៨ ហើយត្រូវបានសម្លាប់ចោលនៅទីនោះមួយខែក្រោយមក ។

ចាប់តាំងពីបានដឹងពីការស្លាប់របស់គាត់មក ខ្ញុំតែងតែសុបិនអាក្រក់និងមានអារម្មណ៍បាត់បង់គាត់ជារឿយៗ ។ ខ្ញុំមានអារម្មណ៍មិនអស់ចិត្តសោះដែលពូរបស់ខ្ញុំត្រូវបានចាប់ខ្លួននិងសម្លាប់ចោលដោយមិនមានឱកាសត្រឡប់ទៅជួបក្រុមគ្រួសាររបស់គាត់វិញបែបនេះ ។

មានអត្ថបទនិងគេហទំព័រជាច្រើនបាននិយាយរៀបរាប់ពីព្រឹត្តិការណ៍ដ៏រន្ធត់នោះ ។ ខ្ញុំសង្ឃឹមថា សាលាក្ដីខ្មែរក្រហមនឹងប្រកាន់ខ្ជាប់នូវទំនួលខុសត្រូវខ្ពស់ដើម្បីធានាអោយបាននូវយុត្តិធម៌និងដើម្បីអោយរូបខ្ញុំផ្ទាល់ក្រុមគ្រួសាររបស់ខ្ញុំក៏ដូចជាប្រជាជនកម្ពុជាទាំងអស់បានអស់ចិត្ត ។

**ចូហ្សូ វ៉ែហ្សឆាល**

## ដំណឹងស្វែរកពូ

នាងខ្ញុំឈ្មោះ លឹម ភានុវណ្ណរង្សីសីហៈ រស់នៅសង្កាត់សន្សំកុសល ខណ្ឌមានជ័យ ក្រុងភ្នំពេញ សូមប្រកាសរកពូឈ្មោះ ហាក់ អុល មកដល់បច្ចុប្បន្នមានអាយុ៧២ឆ្នាំ ។ កាលពីសម័យ លន់ នល់ ពូរបស់នាងខ្ញុំមានផ្ទះនៅទួលគោក ហើយគាត់ធ្វើជាប៉េអឹម ។ គាត់បានបែកពីគ្រួសារនៅមុំវត្តលង្កា ពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីក្រុងឆ្នាំ១៩៧៥ ។ ចាប់តាំងពីពេលនោះមក គ្រួសារនាងខ្ញុំបាត់ដំណឹងគាត់រហូត ។

ប្រសិនបើ បងប្អូនណាបានដឹង ឬស្គាល់ឈ្មោះពូរបស់នាងខ្ញុំ សូមមេត្តាទាក់ទងមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ ៖ ០១៥ ៥៥៥ ០០៧ ឬ ០១២ ៩៩៦ ៧៥០ ឬ មជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈអាសយដ្ឋាន ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ខណ្ឌចំការមន ក្រុងភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ **សូមអរគុណ!**

# សំណល់ជីវិត

ខ្ញុំឈ្មោះ មី មុនីរ័ត្ន ជាកូនច្បងក្នុងចំណោមកូនប្រាំមួយនាក់នៃគ្រួសារមួយដែលមានឪពុកជាគ្រូពេទ្យនៅមន្ទីរពេទ្យព្រះអង្គឌួង ។ ឪពុកខ្ញុំឈ្មោះ មី សំអុល ហើយម្តាយខ្ញុំឈ្មោះ ម៉ែន ម៉ាលីន ធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សាពោធិ៍ រាជធានីភ្នំពេញ ។

## ទីក្រុងភ្នំពេញ

នៅឆ្នាំ១៩៧៥ ខ្ញុំមានអាយុ១២ឆ្នាំ ជាសិស្សថ្នាក់ទី៦ ទំនើបជាតិនៃវិទ្យាល័យបឹងកក់ ដែលមាននាយកឈ្មោះ ឌិម បូរី ។ នៅពេលនោះ ខ្ញុំបានឃើញគ្រាប់ផ្លោងធ្លាក់ស្ទើររៀងរាល់ថ្ងៃក្នុងរាជធានីភ្នំពេញដែលបណ្តាលឲ្យមនុស្សស្លាប់ និងរងរបួសរណ្តូករណែលលើផ្លូវថ្នល់ ។ ចំណែក តាមវត្តអារាម និងទីធ្លាសាធារណៈពោរពេញទៅដោយជនភៀសខ្លួន ។ ក្រោយមក ដោយសារគ្រាប់ផ្លោងធ្លាក់ឥតឈប់ឈរ ឪពុកខ្ញុំបានបង្ខំចិត្តនាំក្រុមគ្រួសារចាកចេញពីផ្ទះនៅភូមិផ្សារដើមគ ទៅស្នាក់នៅបណ្តោះអាសន្នក្នុងមន្ទីរពេទ្យព្រះអង្គឌួង ។

## មន្ទីរពេទ្យពុកខ្ញុំ

នៅគ្រប់អគារក្នុងមន្ទីរពេទ្យពោរពេញទៅដោយអ្នករងរបួស លាយឡំជាមួយនឹងសម្រែកថ្ងូរ ទួញយំព្រោះសោកស្តាយជីវិតអ្នកដែលស្លាប់យ៉ាងអណោចអធ័ម ។ អ្វីដែលធ្វើឲ្យខ្ញុំដក់ជាប់មកទល់នឹងសព្វថ្ងៃនេះ គឺកូនង៉ែតដែលដេកយំក្បែរសពម្តាយទើបនឹងស្លាប់ថ្មីៗ និងកុមារតូចៗដែលឪពុកម្តាយស្លាប់ចោលអស់ ។ ពេលនោះ ខ្ញុំកើតជំងឺស្ពឹកដៃជើង បានដើរកាន់ឈើច្រត់ទៅមើលទិដ្ឋភាពរន្ធត់ទាំងនោះលាយឡំជាមួយអារម្មណ៍ខ្លោចផ្សា ។

នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មនុស្សកាន់តែកើនឡើងក្នុងមន្ទីរពេទ្យ ហើយស្នូរកាំភ្លើងដែលលាន់ឥតដាច់សូរតាំងពីប្រាំថ្ងៃមុននៅតែបន្តគំរាមកំហែងអ្នកទីក្រុងឲ្យភ័យតក់ស្លុត ។ ចំណែកតាមផ្លូវថ្នល់ ទាហាន លន់ នល់ រត់ប្រសេចប្រសាចដោយខ្លះដោះអាវ ហើយខ្លះទៀតបានប្តូរសម្លៀកបំពាក់មកជាស៊ីវិលវិញ ។ តែមួយប៉ព្រិចភ្នែក ឯកសណ្ឋានទាហានបានរាយប៉ាយគ្រប់ទីកន្លែងក្នុងបរិវេណមន្ទីរពេទ្យ ។ ខ្ញុំបានឃើញឪពុកខ្ញុំ និងមិត្តភក្តិគាត់ពីរនាក់នាំគ្នាហែកអាវពេទ្យធ្វើជាទង់ចងនឹងខ្សែបង្គោលដងទង់ជាតិ ហើយបង្ហូតឡើងទៅលើបញ្ជាក់ថាជាសញ្ញាសុំចុះចាញ់ ឬសង្គ្រាមចប់ហើយ ។

## ចប់សង្គ្រាម

ម៉ោងប្រមាណជាដប់ព្រឹក សន្ទឹករថយន្ត និងរថក្រោះសម្រុកចូលគ្រប់វិថីធំៗពាសពេញទីក្រុងជាមួយសម្រែកជ័យឃោសនិងអបអរសាទរចំពោះការមកដល់នៃយោធាខ្មែរក្រហម ។ ខ្ញុំបានទៅឈរនៅមុខមន្ទីរពេទ្យជាមួយប្រជាជនផ្សេងទៀត និងបានពួសម្រែកស្រែកថា “ជយោ សន្តិភាព! សង្គ្រាមចប់ហើយ!” និងពាក្យជាច្រើនទៀតដែលខ្ញុំចាំមិនអស់ ព្រោះរវល់ចាប់អារម្មណ៍មើលកងទ័ពជិះលើរថយន្ត ។ កំពុងតែភ្ញាក់អារម្មណ៍ ម្តាយខ្ញុំបានមកអូសដៃឲ្យចូលទៅក្នុងប្រាប់ថា “ញ៉ាំបាយឲ្យលឿន បន្តិចទៀតវីវរហើយ” ។ ពិតប្រាកដមែន មិនទាន់ទាំងបានហូបបាយផង ស្នូរប្រាវៗនិងគ្រាំងៗលាន់នៅឯជាន់ខាងក្រោមនៃអគារមន្ទីរពេទ្យ ។

អ៊ីចំណាស់ម្នាក់រត់ឡើងមកប្រាប់ឪពុកខ្ញុំថា យោធាខ្មែរក្រហមកំពុងវាយបំបែកបង្អួចតាមបន្ទប់ដែលចាក់សោដើម្បីរកទាហាន លន់ នល់ ថែមទាំងសួររកអ្នកទទួលខុសត្រូវតាមអគារ ។ ឪពុកខ្ញុំស្ថិតក្នុងសម្លៀកបំពាក់ពេទ្យនៅឡើយក៏ចុះទៅក្រោមភ្លាម ទោះបីជាម្តាយខ្ញុំឃាត់ក៏គាត់មិនស្តាប់ដែរ ដោយគាត់បានប្រាប់មកម្តាយខ្ញុំវិញថា បើគាត់មិនចុះទៅជួបទេ យោធាទាំងនោះនឹងវាយបំផ្លាញខ្ទេចខ្ទីអស់ហើយ ។

## បញ្ហាដាច់ខាត

គ្រាន់តែឃើញឪពុកខ្ញុំភ្លាម យោធាខ្មែរក្រហមម្នាក់បានលើកកាំភ្លើងភ្ជង់គាត់ រួចហើយសួររកទាហាន លន់ នល់ ដែលលាក់ខ្លួននៅក្នុងបន្ទប់ ។ ប៉ុន្តែឪពុកខ្ញុំបានឆ្លើយប្រាប់វិញថា មិនមានទាហាន លន់ នល់ លាក់ខ្លួនតាមបន្ទប់ទាំងនេះទេ ដោយគាត់យកជីវិតមកធានា ប្រសិនបើរកឃើញ ។ បន្ទាប់មក ឪពុកខ្ញុំបានបើកសោ

បន្ទប់ទាំងអស់ដើម្បីឲ្យយោធាទាំងនោះពិនិត្យមើល ។ ខ្ញុំចាំច្បាស់ណាស់ថា ពេលនោះ ទាហានអាវខ្មៅម្នាក់អាយុប្រហែលឪពុកខ្ញុំបានប្រាប់គាត់ថា "មិត្តត្រូវឆាប់នាំកូន ប្រពន្ធចេញពីភ្នំពេញបីបួនថ្ងៃសិន ព្រោះអាមេរិកនឹងមកទម្លាក់គ្រាប់បែក ហើយនេះជាបទបញ្ជា" ។ ពេលនោះ ឪពុកខ្ញុំបានឆ្លើយតបថា "បើលោកឲ្យខ្ញុំចាកចេញទៅ ចុះអ្នកជំងឺតើលោកគិតយ៉ាងម៉េច?" យោធានោះមើលមុខឪពុកខ្ញុំទំនងជាខឹង ហើយនិយាយគំហកដាក់គាត់ថា៖ "ឈប់ប្រើពាក្យលោកទៀតទៅ មិត្តឯងត្រូវប្រើពាក្យ "មិត្ត" វិញ ម៉េចស្តាប់បានទេ ចំពោះមិត្តណាដែលដើររួច ត្រូវតែចេញឥឡូវ ចំណែកមិត្តណាដែលដើរមិនរួច ចាំអង្គការបញ្ជូនទៅតាមក្រោយ តែកុំភ្លេចយកអង្ករ និងថ្នាំពេទ្យទៅជាមួយឲ្យបានច្រើនផង" ។ និយាយចប់ យោធារូបនោះបានដើរចេញទៅកាន់កន្លែងអ្នករងរបួសទៀត ។

មិនមាននរណាម្នាក់ហ៊ានដើរតាមមើលសកម្មភាពរបស់យោធាទាំងនោះទេ ហើយក្រោយមកទើបយើងដឹងថា យោធាទាំងនោះបានដើរទៅផ្តាច់សេរ៉ូមពីអ្នករបួស និងសម្លាប់អ្នកជំងឺនៅលើគ្រែយ៉ាងព្រៃផ្សៃ ។

## ថ្ងៃដំបូង

យើងធ្វើដំណើរចេញពីមន្ទីរពេទ្យដោយភិតភ័យតាមរថយន្តសង្គ្រោះបន្ទាន់មួយ ដែលបើកបរដោយឪពុកខ្ញុំផ្ទាល់ចេញទៅតាមច្រកពោធិចិនតុង ។ ខ្ញុំឃើញមនុស្សណែនណាន់តាន់តាប់ទូល រែក លី និង សែងទ្រព្យសម្បត្តិបន្តិចបន្តួចតាមលទ្ធភាពដែលអាចធ្វើបាន ។ ចំណែកកុមារ ដែលដើរតាមក្រោយឪពុកម្តាយសើចលេងសប្បាយតាមចរិតក្មេង ដោយមិនដឹងថាមនុស្សចាស់ៗកំពុងមានអារម្មណ៍យ៉ាងណានោះទេ ។

ចាប់ពីផ្លូវបំបែកនៃមន្ទីរពេទ្យលោកសង្ឃ រហូតមកដល់ពោធិចិនតុង មានសាកសពទាហានប៉ារ៉ាគួរឲ្យអាណោចអាធ័ម ។ រថយន្តបើកហួសចោមចៅបន្តិច យោធាខ្មែរក្រហមឈរបាំងផ្លូវជាតិលេខ៤ រួចបង្ខំឲ្យប្រជាជនចុះពីរថយន្ត រួចហើយបញ្ជាឲ្យដើរតាមផ្លូវលំទៅទិសខាងជើង ។ រថយន្តទាំងអស់មិនត្រូវបានអនុញ្ញាតឲ្យបើកបរកាត់តាមផ្លូវនោះទេ ដូច្នេះអ្នកជិះត្រូវចុះដើរទាំងអស់គ្នា ។

ពេលនោះ ក្រុមគ្រួសារខ្ញុំមិនមានដងរែកឬស្នែងសម្រាប់សែងអីវ៉ាន់ទេ គឺមានតែទូលអីវ៉ាន់ដែលអាចយកទៅជាមួយបានមានអង្ករ និងរបស់ដែលចាំបាច់ផ្សេងទៀត ។ ខ្ញុំមិនអាចជួយកាន់អ្វីបានឡើយ គឺកាន់តែឈើច្រត់ដើរពីក្រោយជីដូនជរាម្នាក់ ។ ដើរបានតែបន្តិច យប់ក៏បានមកដល់ យើងក៏នាំគ្នាឈប់សម្រាកដាំបាយហូប ។ យប់នោះ ខ្ញុំអស់កម្លាំងយ៉ាងខ្លាំង ហើយខ្ញុំក៏ដេកលង់លក់បន្ទាប់ពីឃើញផ្កាយ និងគ្រាប់កាំភ្លើងបញ្ចេញពន្លឺប្រជែងគ្នា ។

## ភូមិស្តុក

រយៈពេលប្រាំមួយថ្ងៃក្រោយពីធ្វើដំណើរដ៏លំបាក និងគ្មានទិសដៅច្បាស់លាស់ គ្រួសារខ្ញុំបានមកដល់ភូមិស្តុក ឃុំពាំងស្លា ស្រុកអមលាំង ខេត្តកំពង់ស្ពឺ ដែលទីស្នាក់អាស្រ័យរយៈពេលយូររបស់យើង ។ ប្រជាជនមូលដ្ឋាននៅទីនោះរួសរាយ និងមានសណ្តានចិត្តល្អណាស់ ព្រោះគាត់តែងតែចែករំលែកទឹកត្នោត ឬស្ករត្នោតឲ្យយើងហូបគ្រប់ៗគ្នា ។

នៅទីនោះ ឪពុកខ្ញុំបានប្រើខ្ញុំឲ្យដើររកជន្លេនយកមកធ្វើនុយសន្ទូច ព្រោះភូមិនោះមានបឹងធំមួយ ហើយសម្បូរត្រីណាស់ ។ សន្ទូចតែមួយសាង មានចំនួនប្រហែល៥០ផ្លែ ដាប់ត្រីយ៉ាងហោចណាស់ ពីដប់ទៅដប់ប្រាំក្បាលក្នុងមួយយប់ ដែលសុទ្ធតែត្រីផ្ទក់ និងត្រីអណ្តែង ។ ខ្ញុំនៅភូមិស្តុកបានតែបីខែ អង្គការក៏ជម្លៀសគ្រួសារខ្ញុំឲ្យទៅរស់នៅខេត្តពោធិ៍សាត់វិញ ។

## ព្រះម្លូភូមិថ្មី

ម៉ោងប្រាំភ្លឺ រទេះគោរាប់សិបគ្រឿងបានដឹកយើងចេញពីភូមិមកជួបជុំគ្នានៅចំណត ។ បន្ទាប់មក អង្គការបើកអង្ករដប់កំប៉ុង និងស្ករត្នោតបីរែកក្នុងមួយគ្រួសារ ហើយម៉ោងប្រហែលប្រាំមួយល្ងាចទើបរថយន្តមកដឹកបន្តទៅខេត្តពោធិ៍សាត់ ។

ភ្លឺស្រាងៗ យើងបានមកដល់ស្ថានីយ៍រថភ្លើងបឹងខ្នារ ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ។ អង្គការបានដឹកក្រុមគ្រួសារខ្ញុំយកទៅដាក់ក្នុងភូមិព្រះម្លូបានមួយខែ ទើបបញ្ជូនបន្តឲ្យមកនៅភូមិមួយទៀត ស្ថិតទល់មុខភូមិព្រះម្លូដោយមានស្ទឹងមួយខណ្ឌចែក ។

នៅទីនេះ មិនមាននរណាម្នាក់ទំនេរទេ គឺអង្គការបែងចែកការងារឲ្យយើងធ្វើគ្រប់ៗគ្នា ។ ឪពុកម្តាយខ្ញុំត្រូវចុះទៅធ្វើស្រែជាមួយចាស់ៗ យុវជននិងយុវនារីត្រូវទៅលើកទំនប់ យាយចាស់ៗ

នៅមើលក្មេងតូចៗក្នុងភូមិ ចំណែកឯកុមារត្រូវដើររើសអាចម៍គោនៅពេលព្រឹក ហើយត្រូវចេញទៅឃ្វាលគោវិញនៅពេលរសៀល ។

## អង្គការវ័យក្មេង

ពេលនោះ ខ្ញុំក៏ត្រូវទៅឃ្វាលគោ និងចូលរួមប្រជុំជីវភាពរៀងរាល់ថ្ងៃដែរ ហើយពេលខ្លះប្រជុំរហូតដល់យប់ជ្រៅទៀតផង ។ ខ្ញុំចាំមិនភ្លេចទេពាក្យស្លោកមួយឃ្លារបស់អង្គការ គឺ "កសាងដូចដាកសេះ ក អត់ តម្រិះ ក ដប" ។ នៅទីនោះ អង្គការដែលមានវ័យក្មេងៗ ហើយខ្លះមានអាយុលើសខ្ញុំតែបន្តិចបន្តួច បានមកអប់រំខ្ញុំឲ្យហៅមិត្តភក្តិថា "មិត្ត" ហៅឪពុកម្តាយ តាយាយថា មិត្តម៉ែ មិត្តពុក និងមិត្តតា មិត្តយាយ ។ ចំណែកពាក្យល្អៗផ្សេងទៀតដែលយើងធ្លាប់ប្រើត្រូវបានចាត់ទុកថា ជាពាក្យមូលធន ពាក្យនាយទុន ពាក្យប្រតិកិរិយា ដែលត្រូវតែជម្រុះចោល ។

យើងទាំងចាស់ទាំងក្មេងមិនមានសិទ្ធិមើលសៀវភៅទេ ប៉ុន្តែកាលនោះ ខ្ញុំបានលួចយកសៀវភៅរៀនភាសាអង់គ្លេស និងបារាំងមួយក្បាលដាក់ទៅជាមួយ ។ យូរៗខ្ញុំបានលួចបើកមើលសៀវភៅនេះ ព្រោះខ្ញុំតែងតែគិតថា ប្រសិនបើបានចូលរៀនវិញ ខ្ញុំខ្លាចភ្លេច ហើយរៀនមិនទាន់គេ ។

## បងជីដូនមួយអភ័ព្វ

ដើមឆ្នាំ១៩៧៦ បងស្រីជីដូនមួយខ្ញុំបីនាក់ដែលបែកពីឪពុកម្តាយ បានមករស់នៅជាមួយក្រុមគ្រួសារខ្ញុំ ។ ថ្ងៃមួយអង្គការស្នើសុំឲ្យបងស្រីជីដូនមួយខ្ញុំទាំងអស់រៀបការជាមួយយោធាពិការ ប៉ុន្តែគាត់បានប្រកែក ។ រំលងបានតែប៉ុន្មានយប់ប៉ុណ្ណោះ អង្គការបានហៅបងស្រីទាំងអស់ទៅរៀនសូត្រ ។

បន្ទាប់ពីបងស្រីខ្ញុំទាំងបីនាក់ចេញទៅរៀនសូត្របានមួយថ្ងៃ ខ្ញុំឮយោធាភូមិប្រាំបួននាក់ជជែកគ្នាថា កាលពីយប់មិញសប្បាយណាស់ ព្រោះបានដេកជាមួយស្រីក្រមុំភ្នំពេញបីនាក់ ។ បន្ទាប់មកយោធាទាំងនោះបាននិយាយពីការធ្វើទារុណកម្ម ដោយយកដងចបសឹកចូលទៅក្នុងរន្ធភេទបងស្រីរហូតស្លាប់ ។ យោធាទាំងនោះនិយាយដោយសើចក្អាកក្អាយ និងសប្បាយរីករាយចំពោះទង្វើដ៏ព្រៃផ្សៃដែលបានប្រព្រឹត្តកាលពីយប់មិញ ។ ខ្ញុំស្លុតចិត្ត និងស្ទើរតែគាំងបេះដូងពេលបានឮពាក្យនេះ ប៉ុន្តែខ្ញុំបានត្រឹមលាក់ទុកក្នុងចិត្តប៉ុណ្ណោះ ។ ក្រោយពីខ្ញុំយករឿងនេះប្រាប់ក្រុមគ្រួសារយាយខ្ញុំឃាំខ្លាំងគេ បន្ទាប់មកម្តាយធំ និងយាយខាងឪពុកខ្ញុំ ។

## មន្ទីរថ្គោល

មួយសប្តាហ៍ក្រោយមក អង្គការបានផ្លាស់ក្រុមគ្រួសារខ្ញុំឲ្យទៅរស់នៅថ្គោល ។ ថ្គោល ជាមន្ទីរឃុំឃាំង ដែលបែកចែកជាពីរផ្នែក គឺថ្គោលខាងជើងសម្រាប់ដាក់អ្នកទោសកម្រិតស្រាល ចំណែកថ្គោលខាងត្បូងសម្រាប់ដាក់អ្នកទោសកម្រិតធ្ងន់ ។ មន្ទីរទាំងពីរ ខណ្ឌចែកដោយអូរមួយដែលមានយោធាយាមការពារយ៉ាងតឹងរ៉ឹង ដោយមិនអនុញ្ញាតឲ្យអ្នកទោសដើរឆ្លងកាត់ទេ ។ ប្រសិនបើនរណាហ៊ានលួចឆ្លងកាត់ នឹងត្រូវចាប់ខ្លួន រួចហើយសម្លាប់ចោលភ្លាម ។

## អ្នកទោសគ្មានកំហុស

អង្គការបានបញ្ជូនឪពុកខ្ញុំទៅដាក់នៅថ្គោលខាងត្បូង ចំណែកខ្ញុំ ម្តាយ ម្តាយធំ និង យាយទៅថ្គោលខាងជើង ហើយក្មេងៗអង្គការប្រមូលយកទៅដាក់ក្នុងរោងវែង ដែលមានចម្ងាយពីក្រុមមនុស្សចាស់ប្រហែលមួយគីឡូម៉ែត្រ ។

អ្នកទោសទាំងអស់ត្រូវក្រោកពីព្រលឹម ហើយអង្គុយជាជួរៗរង់ចាំចេញដំណើរទៅធ្វើការតាមការដ្ឋានរៀងៗខ្លួន ។ ចំណែកការហូបចុកត្រូវហូបជាលក្ខណៈសមូហភាព ហើយត្រី ក្តាម ខ្យង បន្លែព្រៃ និងសូម្បីតែកណ្តុរដែលយើងដាក់អន្ទាក់បាន ឬដឹកបានតាមរន្ធនៅវាលស្រែ ក៏ត្រូវយកមកដាក់ជារបស់សមូហភាពដែរ ។ មិនត្រឹមតែប៉ុណ្ណោះ អង្គការបានស្នើយករបស់របរប្រើប្រាស់មានតម្លៃដូចជា ខោអាវ ខ្សែក ខ្សែដៃ ជាពិសេសនាឡិកា ហើយប្រសិនបើនរណាជំទាស់អង្គការនឹងចោទប្រកាន់ថាជាភ្នាក់ងារសេ.អ៊ី.អា កា.ហ្សេ.បេ ឬខ្មាំងប្រឆាំងបដិវត្តន៍ ហើយអ្នកនោះនឹងបាត់ខ្លួនភ្លាម ។

## ស្លាប់ទាំងអត់ឃ្លាន

ប្អូនស្រីរបស់ខ្ញុំម្នាក់ត្រូវអង្គការចាប់យកទៅសម្លាប់ គ្រាន់តែគាត់លួចពោតខ្ចីមួយផ្លែហូបប៉ុណ្ណោះ ។ ប្អូនស្រីខ្ញុំត្រូវអង្គការវាយនឹងត្បូងចប ហើយកប់ក្បែរចម្ការពោតតែម្តងដើម្បីព្រមានដល់កុមារដទៃទៀត ។ ខណៈនោះ ដោយសារតែម្តាយខ្ញុំពិបាកចិត្តខ្លាំងពេក ហើយអង្គការបង្ខំឲ្យគាត់ធ្វើការងារធ្ងន់ធ្ងរថែម

ទៀត ទើបធ្វើឲ្យគាត់ធ្លាក់ខ្លួនឈឺធ្ងន់ ។ ចំណែកខ្ញុំ ក្រោយមកទៀត អង្គការបានបញ្ឈប់ខ្ញុំលែងឲ្យធ្វើការនៅរោងបាយ ដោយចោទខ្ញុំថាជាប់ពាក់ព័ន្ធជាមួយខ្មាំងដែលអង្គការទើបសម្លាប់ ។

## សាកសពពុកខ្ញុំ

រសៀលថ្ងៃមួយ ពេលខ្ញុំកំពុងដេញគោ ស្រាប់តែធុំក្លិនស្អុយចេញពីព្រៃដើមត្រាចដែលមានចម្ងាយប្រហែលប្រាំរយម៉ែត្រពីផ្លូវជាតិលេខប្រាំ ។ ខ្ញុំខំដើររកមើលស្រាប់តែប្រទះឃើញសាកសពឪពុកខ្ញុំក្រោមដើមឈើមួយដើម ។ គាត់ត្រូវគេកាប់នឹងកាំបិតជិតដាច់កចេញពីស្មា ។ ខ្ញុំស្ទុះទៅឱបសពឪពុកខ្ញុំ ហើយយំខ្សឹបៗ ព្រោះខ្លាចអង្គការដឹង ។ នៅក្បែរសាកសពឪពុកខ្ញុំ ខ្ញុំឃើញមានសពមនុស្សប្រុសពីរនាក់ទៀតដែលត្រូវបានសម្លាប់ដោយកាត់កដែរ ។

យប់នោះ ខ្ញុំបានសុំមេកងមកជួបម្តាយនៅក្នុងភូមិ ។ ខ្ញុំបានយកបាយក្តាំងមួយបន្ទុះ និងដំឡូងជ្វាមួយដុំ (ដែលខ្ញុំយកខ្សងដែលរាវបានកាលពីថ្ងៃដូរជាមួយចុងភៅ) ទៅឲ្យម្តាយ ។ ខ្ញុំបានយកដំណឹងឪពុកទៅប្រាប់ម្តាយ ពេលនោះគាត់យំស្ទើរតែបាត់ស្មារតី ។ ខ្ញុំស្រវាឱបម្តាយខ្ញុំដែលមានតែស្បែកដណ្តប់ឆ្អឹងប៉ុណ្ណោះ ។ ម្តាយខ្ញុំបានផ្តាំខ្ញុំឲ្យចេះស្រឡាញ់ប្អូន និងថែទាំប្អូនព្រោះខ្ញុំជាបង ។ ចំណែកជីដូនខ្ញុំដែលអង្គុយនៅក្បែរម្តាយខ្ញុំដែរ បានយំខ្សឹកខ្សួលអាណិតឪពុកខ្ញុំ និងលើកដៃបួងសួងសូមឲ្យវិញ្ញាណក្ខន្ធកូនទៅកាន់សុគតិភព ។

ម៉ែបានជូនដំឡូងទៅយាយខ្ញុំ ចំណែកគាត់ពិសាបាយក្តាំងដែលខ្ញុំយកមកផ្ញើ ។ ម្តាយខ្ញុំ និង យាយមិនមានពាក្យអ្វីស្រដីរកគ្នាទេ គឺមានតែការឈឺចាប់ព្រាត់ប្រាស់កប់ក្នុងចិត្តប៉ុណ្ណោះ ។ យប់ជ្រៅបន្តិច ខ្ញុំបានលាម្តាយត្រឡប់ទៅកងកុមារវិញ ។ រាល់ថ្ងៃ នៅកងខ្ញុំរស់នៅមានកុមារស្លាប់ជាបន្តបន្ទាប់ដោយសារជំងឺហើម ។ ចំណែកកុមារណាដែលគេចវេះពីការងារអង្គការបានធ្វើទារុណកម្មយ៉ាងធ្ងន់ ។

## ជនក្បត់វ័យក្មេង

ថ្ងៃមួយ កុមារីឈ្មោះ ប៉ាគីស ជាអតីតកូនមន្ត្រីទូត បរទេសដែលអង្គការយកទៅសម្លាប់កាលពីឆ្នាំមុន បានឈឺគ្រុនញាក់ និងដេកដណ្តប់បាវក្រចៅដោយមិនបានចេញទៅធ្វើការទេ ។ រហូតដល់ពេលហូបបបរថ្ងៃត្រង់ ខ្ញុំឃើញយោធាខ្មែរក្រហមមកចាប់ ប៉ាគីសដែលដើរទាំងរញីរញ័រយកទៅវាយសម្លាប់ចោល ដោយចោទថា ជាភ្នាក់ងារ សេ.អ៊ី.អា ។ យោធាខ្មែរក្រហមនោះ បានយកស័យកាំភ្លើងអាកាវាយចំកញ្ចឹងកខាងក្រោយពីរដងទើប ប៉ាគីស ប្រកាច់ ដោយធ្វើឲ្យកុមារផ្សេងទៀតភ័យរន្ធត់គ្រប់គ្នា ។ ពេលនោះក្មេងប្រុសឈ្មោះ សុង ភិតភ័យរហូតដល់យំ ។ ឃើញដូច្នេះយោធានោះបានវាយ សុង ប្រាំខ្សែតី ដោយចោទប្រកាន់ថា សុង យំអាណិតខ្មាំង ។

នៅទីនោះ ទាំងកុមារ និងមនុស្សចាស់បានបាត់ខ្លួនជាបន្តបន្ទាប់ ព្រោះពេលដែលខ្ញុំមកដល់ដំបូងមានមនុស្សប្រហែលជាង ២.០០០នាក់ ប៉ុន្តែក្រោយៗមក ចំនួននេះបានថយចុះ ដោយនៅមិនដល់១.០០០នាក់ផង ។

## ដំណឹងអាក្រក់

រយៈពេលប្រហែលជាពីរខែក្រោយមក នៅពេលដើរទៅបើករបបថ្ងៃត្រង់ មិត្តភក្តិខ្ញុំម្នាក់បានមកប្រាប់ខ្ញុំថា ជីដូនខ្ញុំបានស្លាប់ហើយ ។ ខ្ញុំបានរត់មកសុំច្បាប់មេកង ប៉ុន្តែគាត់មិនអនុញ្ញាតឲ្យខ្ញុំទៅទេព្រោះខ្ញុំជិតដល់ម៉ោងចេញទៅដើររកជីហើយ ។ ដោយការនឹកអាល័យជីដូនខ្លាំងពេក ខ្ញុំបានលួចដើរទៅកាន់កន្លែងដាក់សពយាយខ្ញុំ ។ ពេលទៅដល់អ៊ីចាស់ៗដែលជាប្រជាជនថ្មីដូច ខ្ញុំដែរនោះ ក៏បានអនុញ្ញាតឲ្យខ្ញុំមើលសពយាយ ។ ខ្ញុំលុតជង្គង់គោរពសពគាត់ និងឧទ្ទិសផ្លានបួងសួងសូមឲ្យព្រលឹងគាត់ទៅកាន់សុគតិភព និងជួយថែរក្សាកូនចៅដែលនៅរស់ ។

## ម្តាយខ្ញុំចាកចោល

ចាប់តាំងពីយាយស្លាប់ ខ្ញុំបារម្ភយ៉ាងខ្លាំង ព្រោះខ្លាចបាត់បង់ម្តាយខ្ញុំទៀត ។ ក្រោយមក ខ្ញុំក៏ទទួលដំណឹងថា ម្តាយខ្ញុំកំពុងឈឺធ្ងន់ ។ ខ្ញុំស្រែកទ្រហោយំដោយមិនខ្លាចក្រែងនរណាទាំងអស់ ហើយកាន់ឈើច្រត់ដើរទៅសុំអនុញ្ញាតពីមេកង ។ មេកងបានឆ្លើយតបមកខ្ញុំវិញថា ខ្ញុំមិនមែនជាតាឥសីទៅជួយម្តាយបាន ទេ ។ ប៉ុន្តែដោយសារខ្ញុំអង្វរគាត់ ទើបគាត់យល់ព្រមឲ្យខ្ញុំទៅ ។

ខ្ញុំដើរយ៉ាងលឿនជាមួយឈើច្រត់សំដៅកូនខ្ទមមួយដែលមិនឆ្ងាយប៉ុន្មានពីជំរំកុមារ ។ ប៉ុន្តែ ពេលទៅដល់ខ្ទម ម្តាយខ្ញុំចាប់ផ្តើមដង្ហក់ខ្លាំង និងលែងដឹងខ្លួនទៅហើយ ។ ខ្ញុំឱបគាត់ជាមួយសម្រែងយំខ្សឹកខ្សួល ។ មួយរយៈខ្លីក្រោយមក គាត់នៅស្ងៀមលែងធ្វើចលនាអ្វីទាំងអស់ ។ ម្តាយខ្ញុំស្លាប់ដោយមិនបាននិយាយអ្វីជាមួយ

ខ្ញុំមួយម៉ាត់ទេ ។ អ្នកជិតខាងបានលើកសាកសពម្តាយខ្ញុំដាក់ក្នុងអង្រឹងធ្វើពីបាវក្រចៅ និងយកភួយដែលគាត់ធ្លាប់ដណ្តប់មកគ្របពីលើ រួចហើយសែងចេញពីខ្ទមដោយមានតែសំឡេងយំស្រែករបស់ខ្ញុំប៉ុណ្ណោះ ។

## ជីវិតចុងក្រោយ

ខ្ញុំប្រមែប្រមូលរបស់របរដែលសល់ក្នុងខ្ទមយកមកជំរំកុមារ ។ ពេលមកដល់ ប្អូនខ្ញុំទាំងបួននាក់ក៏ស្លាប់ទៀត ព្រោះប៉ុន្មានថ្ងៃមុននេះវាឈឺហើម ។ ខ្ញុំបានត្រឹមស្មាបអង្អែល និងយំអាលោះអាល័យប្អូនតូចៗដូចជាមនុស្សវង្វេងគ្មានផ្លូវទៅហើយ ។ នៅថ្ងៃនោះ មិនមែនតែក្រុមគ្រួសាររបស់ខ្ញុំទេ គឺមានឪពុកម្តាយ និងកុមារចំនួនប្រាំនាក់ទៀតបានស្លាប់ដែរ ។

មានគ្រួសារមួយបានលាក់ទុកកូនដែលស្លាប់នៅក្នុងមុងដោយមិនបានរាយការណ៍ជូនមេកងដើម្បីទុកបើករបបបបរកូនយកមកហូប ។ ប៉ុន្តែក្រោយមក រឿងនេះក៏បែកការណ៍ អង្គការក៏យកប្តីប្រពន្ធនោះទៅសម្លាប់ចោល ។ តមក មានគ្រួសារដែលអត់ឃ្លានខ្លាំងពេកក៏ដាច់ចិត្តវះខ្មោចកូនយកថ្លើមស្ងោរហូប ក៏អង្គការយកទៅសម្លាប់ចោលដោយអារ-កនឹងកាំបិតចិត្តត្នោតដែរ ។

ថ្ងៃមួយ អង្គការបានយកប្រុសស្រីមួយគូ ដែលធ្វើខុសសីលធម៌មកកាត់ទោសនៅកណ្តាលអង្គប្រជុំតែម្តង ដោយឈ្លបយកដង្កៀបកៀបផ្កាត្នោត មកកៀបពងបុរសនោះរហូតដល់ស្លាប់ ។ ចំណែកឯស្រ្តីនោះ កងឈ្លបយកដំបងរុកចូលប្រដាប់ភេទរហូតដល់ស្លាប់ដែរ ដើម្បីព្រមានដល់អ្នកដទៃទៀត ។

## សំណល់ជីវិត

នៅក្នុងជំរំថ្កោលនោះ ខ្ញុំឆ្លងកាត់ និងជួបប្រទះអំពើឃោរឃៅជាច្រើន ហើយមួយរយៈខ្លីប៉ុណ្ណោះ ខ្ញុំបានបាត់បង់គ្រួសារទាំងអស់ ។ របបនេះបានបន្សល់ទុកសម្រាប់ខ្ញុំនូវអនុស្សាវរីយ៍ឈឺចាប់ខ្លោចផ្សា ព្រាត់ប្រាស់ដែលខ្ញុំមិនអាចទទួលយកបាន និងមិនអាចបំភ្លេចបានក្នុងមួយជីវិតរបស់ខ្ញុំ ។ **ម៉ី មុនីរ័ត្ន**

# ស្វែងរកជនជាតិភាគតិចតំបន់ភ្នំដែលត្រូវបានបណ្តេញចេញពីស្ថានទូតបារាំងកាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥

*ពេលដែលយោធាខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យោធាទាំងនោះបានបណ្តេញប្រជាជនដែលរស់នៅក្នុងទីក្រុងទាំងអស់ឲ្យចាកចេញពីផ្ទះសម្បែងដើម្បីធ្វើដំណើរទៅជនបទនានាទូទាំងប្រទេស ។ ខណៈពេលនោះ អ្នកសារព័ត៌មានជាតិនិងអន្តរជាតិ ជនបរទេស ប្រជាជនកម្ពុជា និងជនជាតិភាគតិចមួយចំនួនបានទៅសុំកន្លែងជ្រកកោណនៅស្ថានទូតបារាំងដើម្បីសុវត្ថិភាពគេចពីការជម្លៀសរបស់ខ្មែរក្រហម និងដើម្បីគេចពីការចាប់ខ្លួនពីសំណាក់យោធាខ្មែរក្រហម ។ ពេលនោះ ប្រធានចលនា ហ្វុលរ៉ូ ឈ្មោះ បាម អេញ្ញូល និងជនជាតិភាគតិចតំបន់ភ្នំដែលមានចំនួនពី១៥០ទៅ៣០០នាក់ដែលពេលនោះរស់នៅក្នុងទីក្រុងស្រាប់ បានទៅជ្រកកោននៅស្ថានទូតបារាំង ។ បួនថ្ងៃក្រោយមក នៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានដាក់សម្ពាធឲ្យស្ថានទូតបារាំងបង្ខំជនជាតិភាគតិចទាំងអស់នោះចេញពីស្ថានទូត ។ បាម អេញ្ញូល បាននាំជនជាតិភាគតិចទាំងនោះចេញ ហើយភ្លាមនោះយោធាខ្មែរក្រហមបានចាប់ខ្លួន បាម អេញ្ញូល ។*

*នាពេលបច្ចុប្បន្ននេះ សមាជិកគ្រួសាររបស់ជនជាតិភាគតិចទាំងអស់ដែលនៅរស់ នៅតែទន្ទឹងរង់ចាំអ្នកទាំងនោះជានិច្ច ហើយរំពឹងថាអ្នកទាំងនោះអាចនៅមានជីវិត ។ ប្រសិនបើបងប្អូនជនជាតិភាគតិចទាំងនោះដឹងពីដំណឹងនេះ សូមទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរសព្ទ លេខ ០២៣ ២១១ ៨៧៥ ឬ ០១៦ ៨៧៦ ៦៩២ ។*

*ខាងក្រោមនេះគឺជាឈ្មោះមួយចំនួនដែលត្រូវបានបណ្តេញចេញពីស្ថានទូតបារាំងៈ*

*១) អ៊ី ហឿប្លួនយ៉ា (កាលនោះគឺជាក្មេងប្រុសម្នាក់ ហើយធ្លាប់រៀននៅសាលាលីសេដេកាត ។ មកដល់បច្ចុប្បន្ននេះ គាត់មាន*

អាយុប្រហែលជា៥៣ឆ្នាំ) ។

២) ហឡា ប៊ូនយ៉ា (ស្រី មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៤៨ឆ្នាំ) ។

៣) ហូ ប៊ូនយ៉ា (ស្រី មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៤៣ឆ្នាំ) ។

៤) អ៊ី វ៉ាន ប៊ូនយ៉ា (ប្រុស មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៤០ឆ្នាំ) ។

៥) ហដាក់ ប៊ូនយ៉ា (ត្រូវជាម្តាយរបស់អ្នកទាំងប៊ូនខាងលើ មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៦៨ឆ្នាំ) ។

៦) អ៊ី ធឹក ប៊ូនយ៉ា (ត្រូវជាពូរបស់អ្នកទាំងប៊ូនខាងលើ មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៦៨ឆ្នាំ) ។

៧) អ៊ី ណាំប៊ូនយ៉ា (ត្រូវជាពូរបស់អ្នកទាំងប៊ូនខាងលើ មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៦៨ឆ្នាំ) ។

៨) អ៊ី ជូ ប៊ូនយ៉ា (កាលនោះគឺជាក្មេងប្រុសម្នាក់ មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៥៣ឆ្នាំ) ។

៩) ហងៀម ប៊ូនយ៉ា (ស្រី មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៥០ឆ្នាំ) ។

១០) ហនុត ប៊ូនយ៉ា (ត្រូវជាម្តាយរបស់លេខ៧, ៨ និង ៩ មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៦៨ឆ្នាំ) ។

១១) ប៊ើណាត អ៊ីបាន (ប្រុស មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៤៨ឆ្នាំ) ។

១២) ហឌូ អ៊ីបាន (ត្រូវជាម្តាយរបស់ ប៊ើណាត អ៊ីបាន មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៦៣ ឆ្នាំ) ។

១៣) អ៊ី ឌុំក ប៊ូនយ៉ា (ប្រុស មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៤៦ឆ្នាំ) ។

១៤) ហ ងួម ប៊ូនយ៉ា (ត្រូវជាម្តាយរបស់ អ៊ី ឌុំក ប៊ូនយ៉ា មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៦៣ឆ្នាំ) ។

១៥) អ៊ី ដួល (ប្រុស មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៤៦ឆ្នាំ) ។

១៦) ហឌៀត (ត្រូវជាម្តាយ ដែលជាគិលានុបដ្ឋាយិការ មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៦៨ឆ្នាំ) ។

១៧) ហរ៉េក (ស្រី មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៥៨ឆ្នាំ) ។

១៨) ហនី (កូនស្រីរបស់ បាម អេញូល ដែលជាអតីតប្រធានចលនា ហ្វុលរ៉ូ មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៤៦ឆ្នាំ) ។

១៩) អ៊ី បេ និងកូនពីនាក់ទៀតតែមិនស្គាល់ឈ្មោះ ។

២០) ហរី ប៊ូនយ៉ា (ម្តាយរបស់ អ៊ី បេ និងក្មេងពីរនាក់ទៀតដែលមិនស្គាល់ឈ្មោះ មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៦៨ឆ្នាំ) ។

២១) អ៊ី ភុត (ប្រុស មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៤៨ឆ្នាំ) ។







# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 150, June 2012 ◆ Funded by Norway and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.